ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៩៥ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

348.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

១.ព្រះរាជក្រម

០៨-១២-២០០៧ -ព្រះរាជក្រម នស/រកម/១២០៧/០៣១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីក្ស័យធន ១០០៩

២.ព្រះរាជក្រឹត្យ

២០-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៣០ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជាកិច្ចបច្ឆាមរណៈជូនសពឯកឧត្តមឧត្តមសេនីយ៍ឯក **ឃើង ម៉ារឌី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១០០៥៥

២២-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៣៦ ស្តីពីការតែងតាំងលោកជំទាវ **ឈើន រ៉ែម** ជា ឧកញ៉ា ១០០៥៦

២២-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៣៧ ស្តីពីការតែងតាំងឯកឧត្តម **ឃឹម មុំនសុខ** ជាទីប្រឹក្សាឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១០០៥៧

២២-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៣៨ ស្តីពីការតែងតាំង ឯកឧត្តម **ហួត ហាក់** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១០០៥៨

២២-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៤១ ស្តីពីការតែងតាំង ឯកឧត្តម **ខួន នៅ** ជាទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលបន្ទុកការងារឧស្សាហកម្ម-សិប្បកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១០០៥៩

២២-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៤២ ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ១១ រូប ១០០៦០

២២-១២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១២០៧/៦៤៣ ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៨ រូប ១០០៦២

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៥-១២-២០០៧ -អនុក្រឹត្យ លេខ ២០១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១០០៦៣

២៦-១២-២០០៧ -អនុក្រឹត្យ លេខ ២០២ អនក្រ.បក ស្តីពីការធ្វើអនុបយោគទីតាំងសាលាស្រុកកំពង់ត្របែក ទីតាំងដីមួយផ្នែករបស់ស្នងការដ្ឋាននគរបាលខេត្តកំពត និង ទីតាំងការិយាល័យចរាចរជើងគោក របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ១០០៦៥

២៦-១២-២០០៧ -អនុក្រឹត្យ លេខ ២០៣ អនក្រ.បក ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨ ១០០៦៧

២១-១២-២០០៧ -អនុក្រឹត្យ លេខ ៩៩៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១០០៧៤

២១-១២-២០០៧ -អនុក្រឹត្យ លេខ ៩៩៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហាន ១០០៧៦

២១-១២-២០០៧ -អនុក្រឹត្យ លេខ ៩៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០០៧៨

២១-១២-២០០៧ -អនុក្រឹត្យ លេខ ៩៩៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១០០៧៩

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ១០០៨០

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០០៨២

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០០៨៥

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០០៨៨

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០០៩៣

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០០៩៤

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០០៩៥

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០០៩៦

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០០៩៧

២៤-១២-២០០៧ -អនុក្រឹត្យ លេខ ១០០៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១០០៩៨

២៥-១២-២០០៧ -អនុក្រឹត្យ លេខ ១០១០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហាន ១០០៩៩

២៥-១២-២០០៧ -អនុក្រឹត្យ លេខ ១០១១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ១០១០៣

២៥-១២-២០០៧ -អនុក្រឹត្យ លេខ ១០១២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០១០៤

III_ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីសំរេច

២៧-១២-២០០៧ -សេចក្តីសំរេច លេខ ១២១ សសរ ស្តីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិភាសាខ្មែរ ១០១២៣

គ

២៧-១២-២០០៧ -សេចក្តីសំរេច លេខ ១២៣ សសរ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេស នៃគណៈកម្មាធិការជាតិភាសាខ្មែរ ១០១២៦

២៧-១២-២០០៧ -សេចក្តីសំរេច លេខ ១២៤ សសរ ស្តីពីការបង្កើតគណៈកម្មការអាជញាកដើម្បីពិនិត្យ និងផ្តល់យោបល់លើសៀវភៅ វេយ្យាករណ៍ភាសាខ្មែរ របស់លោកសាស្ត្រាចារ្យបណ្ឌិត **ឃីន សុខ** ១០១៣២

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

២៦-១២-២០០៧ -ប្រកាសលេខ ១៤៤៧ សហវ.ប្រក ស្តីពីបញ្ញត្តិ និង នីតិវិធីប្រតិវេទនីគយ ១០១៣៤

៣. ធនាគារជាតិ នៃ កម្ពុជា

ប្រកាស

២៥-១២-២០០៧ -ប្រកាសលេខ ធ៤.០៧.១៧៦ ប្រក ស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ធនាគារជាតិ នៃកម្ពុជា ១០១៧៩

៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១. ប្រកាស

៣០-១១-២០០៧ -ប្រកាសលេខ ២៤៩ ពណ.ចបព.ប្រក ស្តីពីការធ្វើវិមជ្ឈការ ការចុះបញ្ជីពាណិជ្ជកម្ម នៅមណ្ឌលសាខា ខេត្ត-ក្រុង ១០១៨៥

២. សេចក្តីជូនដំណឹង

៣០-១១-២០០៧ -សេចក្តីជូនដំណឹង លេខ ២៨៦៨ ពណ.ចបព ស្តីពីបែបបទ និងនីតិវិធីសំរាប់ការចុះបញ្ជីពាណិជកម្ម នៅមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ខេត្ត-ក្រុង ១០១៨៨

ព្រះរាជក្រម

នស/រកម/១២០៧/០៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីក្ស័យធន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME du CAMBODGE

ច្បាប់

ស្តីពី

ក្រុំឯកជន

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL •

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់អំពី វិធាន លក្ខខណ្ឌ នីតិវិធី និងដំណើរការក្តីពីក្ស័យធននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ច្បាប់នេះមានគោលបំណងផ្តល់នូវការទូទាត់ ឬការសងជាសមូហភាពតាមលំដាប់ និងត្រឹមត្រូវតាមសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដោយយកទ្រព្យសម្បត្តិរបស់កូនបំណុលមកទូទាត់ ឬ សង និងផ្តល់នីតិសម្បទាដល់អាជីវកម្មរបស់កូនបំណុល កាលណាភាគីដែលមានផលប្រយោជន៍យល់ថាសមស្រប ។

មាត្រា ៣.-

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះពាណិជ្ជករ និងនីតិបុគ្គលដែលមានទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

ពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងច្បាប់នេះ មានន័យដូចខាងក្រោម :

១-ក្ស័យធន សំដៅដល់ស្ថានភាពរបស់ពាណិជ្ជករ ឬ នីតិបុគ្គលមិនអាចទូទាត់សងបំណុលបាន ហើយត្រូវបានប្រកាសបញ្ជាក់ដោយតុលាការ ។

២-សិទ្ធិលើបំណុល សំដៅដល់សិទ្ធិទទួលការទូទាត់សងពីកូនបំណុល ឬ ការទូទាត់ពីទ្រព្យសកម្មរបស់កូនបំណុលដែលកើតមានឡើងមុនពេលបើកសំណុំរឿងក្ស័យធនដោយមិនគិតថាសិទ្ធិលើបំណុលនោះមានលក្ខខណ្ឌមិនទាន់ទូទាត់បាន ឬ មានភាពបន្ទាន់ឡើយ លើកលែងតែច្បាប់ចែងច្បាស់ថាជាសិទ្ធិលើបំណុលខាងរដ្ឋបាល ។

៣-ក្រុមហ៊ុនមូលធន សំដៅដល់ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតរួមមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបង្កើតឡើងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

៤-ថ្លៃចំណាយក្នុងសំណុំរឿង និងថ្លៃចំណាយក្នុងការបន្តសំណុំរឿង សំដៅដល់ប្រាក់ប្រដាប់ក្តី ថ្លៃចំណាយ និងប្រាក់បំណាច់ថ្លៃឈ្នួលនិងការចំណាយរបស់អភិបាលបណ្តោះអាសន្ន ។

៥-តុលាការ សំដៅដល់តុលាការនៃព្រះរាជាណាចក្រកម្ពុជាហើយមានយុត្តាធិការលើសំណុំរឿងក្ស័យធនតាមអំណាចនៃច្បាប់នេះ ។

៦-ក្រុមហ៊ុនសហកម្មសិទ្ធិ សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែលបង្កើតឡើងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

៧-បុគ្គលដែលពាក់ព័ន្ធសំដៅដល់ៈ

ក-ម្ចាស់ភាគហ៊ុន អភិបាល សហកម្មសិទ្ធិករ ឬ អ្នកចាត់ចែងការរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលមិនមែនជារូបវន្តបុគ្គល

ខ-សហព័ទ្ធរបស់កូនបំណុល ឬ សហព័ទ្ធរបស់ម្ចាស់ភាគហ៊ុន អភិបាល សហកម្មសិទ្ធិករ ឬ អ្នកចាត់ការរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលមិនមែនជារូបវន្តបុគ្គល

គ-បុព្វញាតិ ឬ បច្ឆាញាតិរបស់កូនបំណុល ឬ របស់បុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក និងចំណុច ខ ខាងលើ

ឃ-សហព័ទ្ធរបស់បុគ្គលដូចបានរៀបរាប់ក្នុងចំណុច គ ខាងលើ

ង-កូនបង្កើតរបស់សហព័ទ្ធរបស់កូនបំណុល ឬ របស់បុគ្គលណាមួយដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ឃ ខាងលើ

ច-បុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ង នៃមាត្រានេះកាន់កាប់ភាគហ៊ុនច្រើនជាង ៥% (ប្រាំភាគរយ) នៃភាគហ៊ុន ឬ ជាអភិបាល ឬ ជាអ្នកចាត់ចែងការ

ឆ-ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលបុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ង នៃមាត្រានេះជាសហកម្មសិទ្ធិករ ឬ ជាអ្នកចាត់ចែងការ

ជ-នីតិបុគ្គលដែលបង្កើតឡើងតាមច្បាប់បរទេស ដែលបុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ង នៃមាត្រានេះ កាន់កាប់ដើមទុន លើសពី ៥% (ប្រាំភាគរយ) ឬ ជាអភិបាល ឬ ជាអ្នកចាត់ចែងការ ឬ ជាសហកម្មសិទ្ធិករ

ROYAUME DU CAMBODGE MINISTRE DU PALAIS

ឈ-ជនដែលរស់នៅក្នុងគ្រួសាររបស់កូនបំណុល ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល

ញ-រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលតាមមូលហេតុវិជ្ជាជីវៈ ឬ ទំនាក់ទំនងពាណិជ្ជកម្មជាមួយកូនបំណុល បុគ្គលនេះមានលទ្ធភាពប្រើព័ត៌មានសម្ងាត់ស្តីពីកិច្ចការពាណិជ្ជកម្ម ឬ ហិរញ្ញវត្ថុរបស់កូនបំណុល

ដ-ម្ចាស់បំណុលដែលទាមទារពីកូនបំណុល ដែលមានតម្លៃលើសពី ៥% (ប្រាំភាគរយ) នៃសិទ្ធិលើបំណុលសរុបរបស់ម្ចាស់បំណុលទាំងអស់ប្រឆាំងនឹងកូនបំណុល ។

៨-ម្ចាស់បំណុល សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសិទ្ធិទាមទារសំណងពីកូនបំណុល ឬ ពីទ្រព្យសម្បត្តិរបស់កូនបំណុល ។

៩-ម្ចាស់បំណុលមានកិច្ចធានា សំដៅដល់ម្ចាស់បំណុលដែលមានសិទ្ធិលើទ្រព្យដែលកូនបំណុលបានដាក់ធានាកាតព្វកិច្ច ។ ម្ចាស់បំណុលនេះ មានសិទ្ធិជាអាទិភាពក្នុងការទទួលសំណងមុនម្ចាស់បំណុលផ្សេងទៀត ។

១០-កូនបំណុល សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលក្ស័យធន ។

១១-ការទូទាត់ជម្រះ សំដៅដល់បើម្ចាស់បំណុលក្លាយជាកូនបំណុលវិញដោយឡែកភាគីទាំង២អាចធ្វើការទូទាត់ជម្រះកាតព្វកិច្ចរៀងៗខ្លួនដោយកាត់កងបំណុលទៅវិញទៅមក ។

១២-គណៈកម្មការម្ចាស់បំណុល សំដៅដល់គណៈកម្មការតែងតាំងដោយម្ចាស់បំណុលក្នុងចំណោមម្ចាស់បំណុល ដើម្បីបំពេញការងារតំណាងឱ្យផលប្រយោជន៍របស់ម្ចាស់បំណុលទាំងមូល ។

មាត្រា ៥.-

១-បណ្តឹងឧបាស្រ័យ ឬ បណ្តឹងជំទាស់ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់តុលាការលើបណ្តឹងសុំបើកសំណុំរឿងក្ស័យធនឡើយ ។

២-ក្នុងករណីដែលច្បាប់នេះមិនមានចែងពីបទប្បញ្ញត្តិពិសេសទេ បទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ។

ជំពូកទី ២
ការបើកសំណុំរឿងក្ស័យធន
កម្មវត្ថុ មូលហេតុ និងបណ្តឹង

មាត្រា ៦.-

១-ភាគីដែលមានផលប្រយោជន៍អាចប្តឹងសុំបើកសំណុំរឿងក្ស័យធនតាមច្បាប់នេះទល់នឹងកូនបំណុលដែលជាពាណិជ្ជករ និងជានីតិបុគ្គលដូចខាងក្រោម ៖

ក-ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គលដែលបង្កើតឡើង តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

ខ-រូបវន្តបុគ្គលដែលមានលំនៅឋាន និងទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា

គ-ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គល ដែលបង្កើតឡើងតាមច្បាប់បរទេស ដែលមានទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឃ-រូបវន្តបុគ្គលដែលមានលំនៅឋានក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-សំណុំរឿងក្ស័យធនដែលបើកតាមច្បាប់នេះទល់នឹងបុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិដែលបានកំណត់ក្នុងចំណុចទី ១.គ និង ១.ឃ នៃមាត្រានេះត្រូវអនុវត្តចំពោះតែទ្រព្យសម្បត្តិរបស់បុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានទីស្នាក់ការកណ្តាលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ទ្រព្យសម្បត្តិខាងក្រោមនេះត្រូវចាត់ទុកថាស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖

ក-រូបទ្រព្យដែលស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

ខ-ទ្រព្យសម្បត្តិ និងសិទ្ធិលើកម្មសិទ្ធិ ឬ សិទ្ធិផ្សេងៗទៀតដែលតម្រូវឱ្យចុះបញ្ជីតាមច្បាប់ ឬតាមបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា ។

៣-សំណុំរឿងក្ស័យធនមិនអាចត្រូវបានបើកតាមច្បាប់នេះ ទល់នឹងកូនបំណុល ឬ [illegible]ដែលជាបុគ្គលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ហិរញ្ញវត្ថុ ច្បាប់ស្តីពីការធានារ៉ាប់រង និងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លើកលែងតែមានបទប្បញ្ញត្តិចែងក្នុងច្បាប់ទាំងនោះ ។

មាត្រា ៧.-

១-សំណុំរឿងក្ស័យធនប្តឹងដោយកូនបំណុល ឬ ដោយម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ ក្នុងករណីដែលកូនបំណុលមិនបានបំពេញកាតព្វកិច្ចមួយ ឬ ច្រើនដែលមានសុពលភាព និងដល់កាលកំណត់សងដែលមានទឹកប្រាក់សរុបចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល គឺជាមូលហេតុនៃការបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុលនោះ លើកលែងតែកាតព្វកិច្ចទាំងឡាយដែលនាំឱ្យមានបណ្តឹងទាមទារដូចបានកំណត់ក្នុងមាត្រា ៣៦ ចំណុច ៣ រហូតដល់ចំណុច ៩ នៃច្បាប់នេះ ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចកែប្រែចំនួនប្រាក់កាតព្វកិច្ចអប្បបរមាដែលជាមូលហេតុនៃការបើកសំណុំរឿងក្ស័យធនដូចបានចែងក្នុងចំណុចទី ១ ខាងលើបាន ។

មាត្រា ៨.-

១-បណ្តឹងសុំបើកសំណុំរឿងក្ស័យធនអាចត្រូវបានធ្វើឡើងដោយកូនបំណុល ម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ ។

២-បណ្តឹងសុំបើកសំណុំរឿងក្ស័យធនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយអ្នកប្តឹង ។ បណ្តឹងសុំនេះត្រូវសរសេរបញ្ជាក់ពីព័ត៌មានដូចខាងក្រោម :

ក-ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល

ខ-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង

គ-មូលហេតុតាមមាត្រា ៧ នៃច្បាប់នេះ ដែលជាបង្អែកនៃបណ្តឹង

ឃ-សេចក្តីបញ្ជាក់អំពីកាលៈទេសៈដែលនាំឱ្យមានមូលហេតុនៃបណ្តឹង

ង-ភស្តុតាងជាបង្អែកនៃបណ្តឹង រាប់បញ្ចូលទាំងរាល់ឯកសារភ្ជាប់ដែលអាចផ្តល់ទម្ងន់ដល់បណ្តឹង

ច-បញ្ជីរាយនាមម្ចាស់បំណុលទាំងអស់របស់កូនបំណុលបញ្ជាក់ឱ្យបានច្បាស់នូវឈ្មោះ អាសយដ្ឋានរបស់ម្ចាស់បំណុល និងទឹកប្រាក់ដែលគេទាមទារ ក្នុងករណីដែលសំណុំរឿងប្តឹងដោយកូនបំណុល ។

៣-ការពិនិត្យពាក្យបណ្ដឹង ការបង់ប្រាក់ប្រដាប់ក្ដី ការដាក់ប្រតិភោគលើបណ្ដឹង ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

មាត្រា ៩.-

១-ក្នុងករណីដែលកូនបំណុលលែងមានលទ្ធភាពបំពេញកាតព្វកិច្ចបង់ប្រាក់ដូចបានចែងក្នុងមាត្រា ៧ ដែលដល់កាលកំណត់អនុវត្ត និងនៅមានសុពលភាពក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទត្រូវសង កូនបំណុលនោះត្រូវដាក់ពាក្យបណ្ដឹងបើកសំណុំរឿងក្ស័យធនទល់នឹងខ្លួនឯង ។

២-ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល កូនបំណុលនេះត្រូវមានកាតព្វកិច្ចធានាឱ្យបណ្ដឹងសុំបើកសំណុំរឿងក្ស័យធននេះ ស្របតាមចំណុចទី ១ ខាងលើ ។ ក្នុងករណីដែលកូនបំណុលជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ផ្អែកតាមករណីនីមួយៗ អភិបាល សហកម្មសិទ្ធិករ ឬ អ្នកចាត់ការគ្រប់រូប ត្រូវមានកាតព្វកិច្ចធានាឱ្យបណ្ដឹងសុំបើកសំណុំរឿងក្ស័យធននេះ ស្របតាមចំណុចទី ១ ខាងលើ ។

៣-បុគ្គលទាំងឡាយណាដែលមិនបានបំពេញកាតព្វកិច្ចដែលចែងក្នុងចំណុចទី ២ ខាងលើដោយចេតនា ឬ ដោយការធ្វេសប្រហែសក្ដី ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់របស់កូនបំណុលលើការខូចខាតដែលកើតឡើងដោយផ្ទាល់ពីការខកខាននោះ ។ បើកាតព្វកិច្ចធានាក្នុងចំណុចទី ២ ខាងលើធ្លាក់ទៅលើបុគ្គលច្រើននាក់ បុគ្គលដែលមានចេតនា ឬ មានការធ្វេសប្រហែសទាំងនេះត្រូវទទួលខុសត្រូវរួមគ្នាផង និងដាច់ដោយឡែកពីគ្នាផង ចំពោះការខូចខាតដែលកើតឡើងដោយផ្ទាល់ពីការមិនបានបំពេញកាតព្វកិច្ចនោះ ។ បើសំណុំរឿងក្ស័យធននេះត្រូវបានប្ដឹងទល់នឹងកូនបំណុល ការខូចខាតនេះ ត្រូវរាប់បញ្ចូលជាទ្រព្យសម្បត្តិ ហើយអភិបាលបណ្ដោះអាសន្នត្រូវចាត់វិធានការក្នុងនាមម្ចាស់បំណុលទាំងអស់ដើម្បីទារសំណងខូចខាតទាំងនេះ ។

មាត្រា ១០.-

តុលាការត្រូវផ្ញើពាក្យបណ្ដឹងសុំបើកសំណុំរឿងក្ស័យធនរបស់ម្ចាស់បំណុល ឬ របស់អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការឱ្យទៅកូនបំណុល មិនឱ្យលើសពីរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការចាប់ពីថ្ងៃបណ្ដឹងនោះ ចូលដល់តុលាការ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

3/47

មាត្រា ១១.-

១-ចាប់ពីពេលដាក់ពាក្យប្តឹងសុំបើកសំណុំរឿងក្ស័យធនរហូតដល់ពេលតុលាការចេញសេចក្តីសម្រេចឱ្យបើកសំណុំរឿងក្ស័យធន តុលាការត្រូវចេញសេចក្តីសម្រេចតែងតាំងអភិបាលបណ្តោះអាសន្ន តាមពាក្យសុំជាលាយលក្ខណ៍អក្សររបស់កូនបំណុល ម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ ។

២-អភិបាលបណ្តោះអាសន្នត្រូវចាត់រាល់វិធានការចាំបាច់ ឬ សមស្របដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល ។ ជាពិសេសបើយល់ឃើញថាចាំបាច់ អភិបាលបណ្តោះអាសន្នអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឃាត់ទុកទ្រព្យសម្បត្តិ ឬ ព្យួរបណ្តឹងទាមទាររបស់ម្ចាស់បំណុលមានកិច្ចធានា ឬ គ្មានកិច្ចធានា ដែលប្តឹងទល់នឹងកូនបំណុល ឬ ទ្រព្យសកម្ម ក្នុងទ្រព្យសម្បត្តិរបស់កូនបំណុល ។

៣-រាល់សេចក្តីសម្រេចរបស់តុលាការដែលសម្រេចតាមចំណុចទី ១ និងចំណុចទី ២ នៃមាត្រានេះ ត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធ និងផ្សព្វផ្សាយជាសាធារណៈតាមសារព័ត៌មានប្រចាំថ្ងៃ ។

ជំពូកទី ៣
សេចក្តីសម្រេចលើបណ្តឹងសុំបើកសំណុំរឿងក្ស័យធន

មាត្រា ១២.-

១-តុលាការត្រូវបើកសវនាការលើបណ្តឹងសុំបើកសំណុំរឿងក្ស័យធនរបស់កូនបំណុលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពីបានទទួលបណ្តឹងសុំ ហើយទោះជាក្នុងករណីណាក៏ត្រូវបើកសវនាការមិនឱ្យលើសពី ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

២-តុលាការត្រូវបើកសវនាការលើបណ្តឹងសុំ ដែលធ្វើឡើងដោយម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ មិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

៣-កូនបំណុល ម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការមានសិទ្ធិចូលរួមក្នុងសវនាការ ។

មាត្រា ១៣.-

១-បន្ទាប់ពីបើកសវនាការលើបណ្តឹងសុំ ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងសុំមានមូលហេតុសមស្របនោះ តុលាការត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដើម្បី :

ក-បើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល

ខ-តែងតាំងអភិបាលបណ្តោះអាសន្នតាមមាត្រា ១១ នៃច្បាប់នេះ

គ-កំណត់កាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុល ចាប់ពី ៣០ (សាមសិប) ថ្ងៃ តែមិនត្រូវលើសពី ៦០(ហុកសិប) ថ្ងៃ បន្ទាប់ពីបើកសំណុំរឿងក្ស័យធន

ឃ-បញ្ជាក់ពីកាលបរិច្ឆេទចុងក្រោយ កំណត់នៃការដាក់ជូនភស្តុតាងនៃបណ្តឹងទាមទារដែលត្រូវមានរយៈពេល៧(ប្រាំពីរ)ថ្ងៃ មុនកាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុល ។

២-ក្នុងការកំណត់កាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុលនេះ តុលាការត្រូវពិនិត្យថា តើកូនបំណុលបានដាក់ជូនសំណើផែនការសុំសម្របសម្រួលដែលកូនបំណុលអះអាងថា ផែនការនោះមាន ឬ គ្មានការគាំទ្រពីម្ចាស់បំណុល ។

៣-បន្ទាប់ពីបើកសវនាការលើបណ្តឹងសុំ ប្រសិនបើតុលាការយល់ថា គ្មានមូលហេតុសមស្របដែលជាមូលដ្ឋាននៃបណ្តឹងនេះ ឬ បើបណ្តឹងនេះធ្វើឡើងដោយកូនបំណុល ឬ ម្ចាស់បំណុល ដោយរួមជាមួយកូនបំណុលគឺជាឧបាយកល ឬ មានបំណងទុច្ចរិត តុលាការត្រូវសម្រេចលើកបណ្តឹងសុំនេះចោល ។

៤-តុលាការត្រូវចេញសេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន ឬ លើកបណ្តឹងសុំក្នុងរយៈពេលមិនលើសពី ១៤(ដប់បួន) ថ្ងៃ បន្ទាប់ពីបញ្ចប់សវនាការលើបណ្តឹងសុំ ។

៥-កូនបំណុល ឬ ម្ចាស់បំណុលអាចប្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់តុលាការក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចនោះ ។

មាត្រា ១៤.-

១-នៅពេលចេញសេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន ឬ នៅពេលណាមួយ បន្ទាប់ពីបានចេញសេចក្តីសម្រេចនេះ តុលាការត្រូវបង្គាប់ឱ្យជម្រះបញ្ជីលើអាជីវកម្ម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

11/4
-ទៀត

របស់កូនបំណុល ប្រសិនបើតុលាការយល់ថាអាជីវកម្មរបស់កូនបំណុលពីមុនមិនអាចនឹងមាននីតិសម្បទាឡើងវិញ ហើយមិនអាចមានការឯកភាពលើផែនការសម្របសម្រួល ។

២-តុលាការអាចចេញសេចក្តីសម្រេចបង្គាប់ឱ្យជម្រះបញ្ជីតាមចំណុចទី ១ ឬ តាមការស្នើសុំរបស់កូនបំណុល អភិបាលបណ្តោះអាសន្ន ម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ ។

មាត្រា ១៥.-

សំណុំរឿងក្ស័យធនត្រូវចាត់ទុកថាបានបើកនៅកាលបរិច្ឆេទដែលតុលាការចេញសេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន ។

មាត្រា ១៦.-

១-សំណុំរឿងក្ស័យធនមិនត្រូវបើកឡើយ ហើយបណ្តឹងសុំត្រូវបានលើកចោល បើទ្រព្យសកម្មរបស់កូនបំណុលមានចំនួនមិនគ្រប់គ្រាន់សម្រាប់ធានាការចំណាយក្នុងដំណើរការនៃនីតិវិធី ។

បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើមានបុគ្គលពាក់ព័ន្ធណាមួយផ្តល់ប្រាក់គ្រប់គ្រាន់ជាមុនសម្រាប់ធានាការចំណាយក្នុងការប្រព្រឹត្តទៅនៃនីតិវិធី ។

២-បុគ្គលដែលបានផ្តល់ប្រាក់ជាមុនតាមចំណុចទី ១ កថាខណ្ឌទី ២
អាចទាមទារ
យកប្រាក់នោះវិញពីរូបវន្តបុគ្គលដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនីតិវិធីបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល នៅពេលដែលមានបណ្តឹងសុំបើកសំណុំរឿងក្ស័យធន ។ ការទាមទារយកប្រាក់នោះវិញអាចធ្វើបានក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលបានផ្តល់ប្រាក់ទៅឱ្យរូបវន្តបុគ្គលនោះ ។ ក្នុងករណីដែលមានវិវាទទាក់ទិននឹងបញ្ហាដែលថារូបវន្តបុគ្គលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន រូបវន្តបុគ្គលនោះត្រូវផ្តល់ភស្តុតាងថាខ្លួនមិនបានខកខានក្នុងការបំពេញកាតព្វកិច្ចទេ ។

មាត្រា ១៧.-

១-នៅពេលបដិសេធបណ្ដឹងសុំបើកសំណុំរឿងក្ស័យធន ដោយសារបណ្ដឹងសុំនោះគ្មានមូលហេតុសមស្រប តុលាការត្រូវចេញសេចក្ដីសម្រេចបង្គាប់ឱ្យអ្នកប្ដឹងចេញសងកូនបំណុល ឬ ម្ចាស់បំណុលនូវថ្លៃចំណាយផ្លូវច្បាប់ទាំងអស់ដែលភាគីទាំងឡាយបានចំណាយក្នុងការចូលរួមក្នុងបណ្ដឹងសុំនេះ ។

២-បើតុលាការរកឃើញថា បណ្ដឹងសុំនេះធ្វើឡើងដោយមានឧបាយកល ឬ បំណងទុច្ចរិត ឬ ដោយចេតនាទំលាក់កំហុសទៅលើកូនបំណុល ឬ ម្ចាស់បំណុល តុលាការសម្រេចបង្គាប់ឱ្យអ្នកប្ដឹងទទួលខុសត្រូវចេញសំណងខូចខាត ដែលបង្កឡើងដោយបណ្ដឹងសុំនេះ ។

មាត្រា ១៨.-

១-សេចក្ដីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធនត្រូវចុះផ្សាយជាសាធារណៈក្នុងសារព័ត៌មានប្រចាំថ្ងៃ និងត្រូវជូនដំណឹងទៅការិយាល័យចុះបញ្ជី និងការិយាល័យតម្កល់ព័ត៌មានដែលគ្រប់គ្រងសិទ្ធិប្រាតិភោគឱ្យឆាប់បំផុតផងដែរ ។

២-ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន អភិបាលបណ្ដោះអាសន្នត្រូវធ្វើការជូនដំណឹងរួមទាំងការចុះផ្សាយក្នុងសារព័ត៌មានប្រចាំថ្ងៃ យ៉ាងហោចណាស់ពីរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រកាសពីព័ត៌មានដូចខាងក្រោមនេះ :

ក-បញ្ជាក់ថាសំណុំរឿងក្ស័យធនត្រូវបានបើកទល់នឹងកូនបំណុល

ខ-ថ្ងៃផុតកំណត់សម្រាប់ការដាក់ជូនភស្តុតាងនៃបណ្ដឹងទាមទារ ជាលាយលក្ខណ៍អក្សរ និងអាសយដ្ឋានដែលត្រូវបញ្ជូនភស្តុតាងនៃបណ្ដឹងទាមទារជាលាយលក្ខណ៍អក្សរនេះទៅឱ្យ

គ-ប្រកាសពីពេលវេលា និងទីកន្លែងបើកកិច្ចប្រជុំម្ចាស់បំណុល ។

៣-ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអភិបាលបណ្ដោះអាសន្នបានទទួលសេចក្ដីប្រកាសរបស់កូនបំណុលដែលបានធ្វើឡើងស្របតាមមាត្រា ២៩ នៃច្បាប់នេះ អភិបាលបណ្ដោះអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បំណុលទាំងអស់ដែលមានឈ្មោះក្នុងសេចក្ដីប្រកាសនោះ ដូចមានចែងក្នុងចំណុចទី ២-ក ដល់ចំណុចទី ២-គ នៃមាត្រានេះ ។

ជំពូកទី ៤
អានុភាពនៃការបើកសំណុំរឿងក្ស័យធន
ផ្នែកទី ១
អានុភាពទូទៅ

មាត្រា ១៩.-

១-បន្ទាប់ពីតុលាការសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន និង រហូតទាល់តែសំណុំរឿងក្ស័យធននេះត្រូវបានបញ្ចប់ តុលាការត្រូវព្យួរដំណើរការក្ដី ឬ នីតិវិធី ឬ បណ្ដឹងផ្សេងទៀតទោះក្នុងរូបភាពណាក៏ដោយ ដែលធ្វើឡើងដោយម្ចាស់បំណុល ឬ ក្នុងនាមម្ចាស់បំណុលទល់នឹងកូនបំណុល ឬ ទ្រព្យសកម្មរបស់កូនបំណុល ។

២-ក្នុងករណីដែលយល់ឃើញថាទ្រព្យសម្បត្តិរបស់កូនបំណុលនៅមានផលប្រយោជន៍ អភិបាលបណ្ដោះអាសន្នអាចអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យម្ចាស់បំណុលយកទ្រព្យដែលដាក់ធានាតាមហ៊ីប៉ូតែកទៅកាន់កាប់ និងលក់ទ្រព្យធានាដោយអនុវត្តតាមច្បាប់ជាធរមាន ឬ អនុញ្ញាតឱ្យម្ចាស់បំណុលនេះ ប្រើប្រាស់ទ្រព្យធានាតាមមធ្យោបាយផ្សេង ដោយតម្រូវឱ្យម្ចាស់បំណុលទទួលការទូទាត់រំលោះបំណុលពីការប្រើប្រាស់នោះ ។

៣-ក្នុងករណីសំណុំរឿងក្ស័យធនត្រូវបានបើកទល់នឹងកូនបំណុល ដែលជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ការព្យួរពាក្យបណ្ដឹងក្នុងចំណុចទី ១ នៃមាត្រានេះ
ក៏ត្រូវអនុវត្តចំពោះ រាល់បណ្ដឹង ដំណើរការក្ដី ឬ
នីតិវិធីអនុវត្តលើបំណុលរបស់កូនបំណុលព្រមទាំងទ្រព្យសម្បត្តិ
រៀងៗខ្លួនរបស់សហកម្មសិទ្ធិករ ។

ក្នុងករណីសំណុំរឿងក្ស័យធនទល់នឹងកូនបំណុលដែលជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ការព្យួរពាក្យបណ្ដឹងក្នុងចំណុចទី ១ នៃមាត្រានេះក៏ត្រូវអនុវត្តចំពោះរាល់បណ្ដឹងដំណើរការក្ដី ឬ នីតិវិធីអនុវត្តលើបំណុលរបស់កូនបំណុលព្រមទាំងទ្រព្យសម្បត្តិរៀងៗខ្លួនរបស់សហកម្មសិទ្ធិករទូទៅ ។

មិនមានអភិបាលបណ្ដោះអាសន្នទេ ដែលអាចទាមទារឱ្យសហកម្មសិទ្ធិករទទួលខុសត្រូវផ្ទាល់ខ្លួនលើបំណុលនៃកូនបំណុល ក្នុងកំឡុងពេលដំណើរការសំណុំរឿងក្ស័យធន ។

ROYAUME DU CAMBODGE ... ROYAL

៤-ការព្យួរបណ្តឹងតាមចំណុចទី ១ នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះបណ្តឹងទាមទារចំណាយខាងរដ្ឋបាលទាក់ទិននឹងប្រាក់បំណាច់ថ្លៃឈ្នួល និងថ្លៃចំណាយរបស់អភិបាលបណ្តោះអាសន្ន និងបណ្តឹងទាមទារចំណាយខាងរដ្ឋបាលផ្សេងទៀត ដែលធ្វើឡើងដោយអភិបាលបណ្តោះអាសន្នឡើយ ។

មាត្រា ២០.-

១-ការបើកសំណុំរឿងក្ស័យធន ត្រូវកំណត់ពីទ្រព្យនៃកូនបំណុល ។

២-ទ្រព្យនៃកូនបំណុលត្រូវរាប់បញ្ចូលទាំងរាល់ទ្រព្យសកម្ម សិទ្ធិ និងសិទ្ធិលើបំណុលគ្រប់ប្រភេទ ដែលកូនបំណុលមានផលប្រយោជន៍ពីកម្មសិទ្ធិ ឬ ផលប្រយោជន៍ផ្សេងទៀត ដែលកូនបំណុលមានសិទ្ធិទទួលនៅកាលបរិច្ឆេទបើកសំណុំរឿងក្ស័យធន ឬ បន្ទាប់ពីកាលបរិច្ឆេទនោះ ។

៣-ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល ទ្រព្យសម្បត្តិដូចខាងក្រោមមិនត្រូវរាប់បញ្ចូលជាទ្រព្យនៃកូនបំណុលទេ ៖

ក-ទីកន្លែងដែលជាលំនៅឋានចម្បងរបស់កូនបំណុល ដែលមានតម្លៃមិនលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀល តាមតម្លៃទីផ្សារ

ខ-ទ្រព្យសកម្ម សិទ្ធិ ឬ សិទ្ធិលើបំណុលដែលក្រមនីតិវិធីរដ្ឋប្បវេណីលើកលែងមិនឱ្យអនុវត្តប្រឆាំងនឹងកូនបំណុល ។

មាត្រា ២១.-

ទ្រព្យនៃកូនបំណុលត្រូវស្ថិតនៅក្រោមការចាត់ចែង និងសិទ្ធិអំណាចរបស់អភិបាលបណ្តោះអាសន្ន ។

មាត្រា ២២.-

កូនបំណុលត្រូវសហការជាមួយអភិបាលបណ្តោះអាសន្នឱ្យអស់ពីសមត្ថភាព និងត្រូវផ្តល់ជូនអភិបាលបណ្តោះអាសន្ននូវព័ត៌មានចាំបាច់ទាំងអស់ ដែលទាក់ទិននឹងអាជីវកម្មរបស់ខ្លួន

មាត្រា ២៣.-

១-ដើម្បីបំពេញភារកិច្ចរបស់ខ្លួន និងកិច្ចការផ្សេងទៀត អភិបាលបណ្តោះអាសន្ន ត្រូវមានសិទ្ធិអំណាចដូចខាងក្រោមនេះ :

ក-ធ្វើជាតំណាងកូនបំណុល និងចាត់ចែងអាជីវកម្មរបស់កូនបំណុលក្នុង សំណុំរឿងក្ស័យធន

ខ-ទទួលសំណុំលិខិតរបស់កូនបំណុលតាមប្រៃសណីយ៍ និងតាមប្រព័ន្ធអេឡិចត្រូនិកដែលផ្ញើជូនកូនបំណុល លើកលែងតែសំបុត្រ និងលិខិតទាក់ទងដែលមានលក្ខណៈ ឯកជនទាំងស្រុង

គ-អនុវត្តបន្តអាជីវកម្មរបស់កូនបំណុល ប៉ុន្តែចំពោះតែវិសាលភាពដែលចាំបាច់ដើម្បីសម្រេចគោលបំណងនៃសំណុំរឿងក្ស័យធន

ឃ-ទទួលទ្រព្យសកម្មរបស់កូនបំណុល រាប់បញ្ចូលទាំងបញ្ជីគណនេយ្យ និង ឯកសាររបស់កូនបំណុល

ង-ប្រមូល និងបញ្ចូលក្នុងទ្រព្យរបស់កូនបំណុលនូវទឹកប្រាក់ ដែលនៅជំពាក់ពីការលក់ភាគហ៊ុនរបស់កូនបំណុល ឬ ការផ្ទេរភាគទុនដែលសហកម្មសិទ្ធិករមិនទាន់បង់ជូនកូនបំណុល

ច-ប្រើប្រាស់ និងយកទ្រព្យសកម្មរបស់កូនបំណុលធ្វើពាណិជ្ជកម្ម រាប់បញ្ចូលទាំងការលក់ទ្រព្យសកម្ម ដែលគ្មានជាប់សិទ្ធិពីទ្រព្យធានា និងការចញ្ចាំ

ឆ-ទទួលបន្ទុកជាតំណាងកូនបំណុលដែលជាភាគីក្នុងការដោះស្រាយសំណុំរឿងក្នុងតុលាការ

ជ-រៀបចំបញ្ជីនៃការទាមទារបំណុល

ឈ-អនុញ្ញាតឱ្យម្ចាស់បំណុលលក់ទ្រព្យសកម្មដែលជាកម្មវត្ថុនៃសិទ្ធិលើទ្រព្យធានារបស់ម្ចាស់បំណុលដោយអនុវត្តតាមច្បាប់ជាធរមាន ហើយយកថ្លៃលក់ទ្រព្យសកម្មនោះមកទូទាត់បណ្តឹងទាមទាររបស់ម្ចាស់បំណុល

ញ-រក្សាទុកដោយឡែកនូវទ្រព្យសកម្មដែលបង្កការស្មុគស្មាញដល់ទ្រព្យរបស់

ដ-ស្នើសុំឱ្យតុលាការពិនិត្យរាល់បញ្ហារបស់បុគ្គល ដែលទាក់ទិននឹងអាជីវកម្មរបស់កូនបំណុល

ឋ-បញ្ឈប់ លុបចោល ឬ ប្រកាសមោឃភាព នូវប្រតិបត្តិការអាជីវកម្ម កិច្ចសន្យា កិច្ចព្រមព្រៀង ឬ លិខិតផ្ទេរកម្មសិទ្ធិ ដែលកូនបំណុលជាភាគី ដោយអនុលោមតាមច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត

ឌ-កោះប្រជុំ និងរៀបចំកិច្ចប្រជុំម្ចាស់បំណុល ដូចមានចែងក្នុងច្បាប់នេះ

ឍ-រៀបចំនិងលើកសំណើផែនការសម្របសម្រួល បើមានការចាំបាច់

ណ-ជួលភ្នាក់ងារ និងអ្នកមានវិជ្ជាជីវៈ ដើម្បីបម្រើកិច្ចការជាជំនួយការក្នុងភារកិច្ចរបស់ខ្លួន

ត-ធ្វើគ្រប់សកម្មភាពផ្សេងទៀត ដែលចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដែលស្របតាមគោលបំណងនៃសំណុំរឿងក្ស័យធន ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចេញប្រកាសដើម្បីបំពេញបន្ថែមបទប្បញ្ញត្តិស្តីពីសិទ្ធិអំណាចរបស់អភិបាលបណ្តោះអាសន្នក្នុងចំណុចទី ១ នៃមាត្រានេះ ។

មាត្រា ២៥.-

១-ចាប់ពីថ្ងៃដែលត្រូវបានតែងតាំងរហូតដល់ពេលបើកកិច្ចប្រជុំម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវ ៖

ក-បន្តអាជីវកម្មរបស់កូនបំណុល ប្រសិនបើអាជីវកម្មនេះអាចបន្តបានហើយនៅមានផលប្រយោជន៍សេដ្ឋកិច្ច

ខ-សិក្សា និងវិភាគពីស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់កូនបំណុល និងលទ្ធភាពនៃការស្តារនីតិសម្បទាឡើងវិញរបស់កូនបំណុល និង រៀបចំរបាយការណ៍ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

២-ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អភិបាលបណ្តោះអាសន្នត្រូវប្រើប្រាស់ បទពិសោធន៍ [illegible] គ្រប់គ្រងរបស់កូនបំណុលតាមដែលអាចធ្វើទៅបាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
17/47k

មាត្រា ២៥.-

១-អភិបាលបណ្តោះអាសន្ន ត្រូវមានការយល់ព្រមពីម្ចាស់បំណុល តាមរយៈកិច្ចប្រជុំម្ចាស់បំណុលមុននឹងធ្វើសកម្មភាពដូចខាងក្រោម ៖

ក-លក់អចលនទ្រព្យរបស់កូនបំណុលតាមកិច្ចសន្យាឯកជន

ខ-លក់ ឬ ផ្ទេរទ្រព្យសម្បត្តិណាមួយរបស់កូនបំណុលទៅឱ្យបុគ្គលដែលពាក់ព័ន្ធ ទោះជាតាមមធ្យោបាយណាក្តី

គ-អនុវត្តប្រតិបត្តិការណាមួយដែលអាចប៉ះពាល់ដល់ការអនុម័ត ឬ ការអនុវត្តផែនការសម្របសម្រួល ។

២-រាល់ប្រតិបត្តិការដែលបានអនុវត្តផ្ទុយពីចំណុចទី១ ក និង ខ នៃមាត្រានេះ ត្រូវចាត់ទុកជាការរំលោភលើភារកិច្ចរបស់អភិបាលបណ្តោះអាសន្ន ហើយនាំឱ្យអភិបាលបណ្តោះអាសន្ននេះមានការទទួលខុសត្រូវផ្ទាល់ខ្លួន ចំពោះការខូចខាតដល់ទ្រព្យសម្បត្តិរបស់កូនបំណុល ឬ ដល់ភាគីណាមួយក្នុងរឿងក្តីនេះ ។

មាត្រា ២៦.-

១-ក្នុងរយៈពេលមិនលើសពី ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន អភិបាលបណ្តោះអាសន្នត្រូវកំណត់តម្លៃលើទ្រព្យធានាដែលកាន់កាប់ដោយម្ចាស់បំណុល ដែលកូនបំណុលបានដាក់បញ្ចាំតាមគោលការណ៍សុចរិត ។ ការវាយតម្លៃរបស់អភិបាលបណ្តោះអាសន្ន ត្រូវចាត់ទុកជាការកំណត់តម្លៃត្រឹមត្រូវលើផ្នែកដែលមានកិច្ចធានានៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល លើកលែងតែមានការតវ៉ាពីកូនបំណុល ឬ ម្ចាស់បំណុល ។

២-សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលលើសពីតម្លៃ ដែលបានកំណត់ក្នុងចំណុចទី ១ នៃមាត្រានេះ ឬ មិនទាន់ទូទាត់គ្រប់បន្ទាប់ពីការយកថ្លៃលក់ទ្រព្យធានាមកសង ត្រូវមានសិទ្ធិទទួលការទូទាត់ពីសំណុំរឿងក្ស័យធនដូចគ្នានឹងសិទ្ធិលើបំណុលដែលគ្មានកិច្ចធានាដែរ ។ បញ្ញត្តិនេះមិនអនុវត្តទេបើទ្រព្យធានាត្រូវបានកូនបំណុលផ្តល់សម្រាប់ធានាបំណុលរបស់បុគ្គលណាមួយដែលមិនមែនជាកូនបំណុល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

៣-មុនពេលផុតរយៈពេល ៣០(សាមសិប)ថ្ងៃ ដែលបានកំណត់តាមចំណុចទី ១នៃមាត្រានេះ ការវាយតម្លៃមិនត្រូវអនុវត្តទេប្រសិនបើ ៖

ក-តុលាការបានបង្គាប់ឱ្យចាប់ផ្តើមជម្រះបញ្ជីលើអាជីវកម្មរបស់កូនបំណុល ឬ

ខ-អភិបាលបណ្តោះអាសន្នបានលក់ ឬ បានអនុញ្ញាតឱ្យម្ចាស់បំណុលលក់ទ្រព្យសកម្មតាមច្បាប់ជាធរមានដែលបានដាក់ធានា ឬ អនុញ្ញាតឱ្យអនុវត្តសិទ្ធិលើទ្រព្យធានា និងយកថ្លៃលក់ទ្រព្យនោះមកទូទាត់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ។

មាត្រា ២៧.-

១-អភិបាលបណ្តោះអាសន្ន ត្រូវបង់ជូនម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិរបស់កូនបំណុលនូវការប្រាក់ទាំងអស់ដែលកើតឡើង គិតតាមអត្រាការប្រាក់នៃកិច្ចសន្យាលើទ្រព្យធានា ។ បើសិទ្ធិលើទ្រព្យធានាត្រូវបានផ្តល់ដើម្បីធានាបំណុលរបស់បុគ្គលណាមួយក្រៅពីកូនបំណុល អភិបាលបណ្តោះអាសន្នត្រូវបង់តែការប្រាក់ដែលកើតពីការដាក់ទ្រព្យធានា ប្រសិនបើបុគ្គលនោះគ្មានលទ្ធភាពទូទាត់ប្រាក់ដែលជំពាក់ម្ចាស់បំណុល ។

២-ក្នុងករណីគ្មានអត្រាការប្រាក់កំណត់ក្នុងកិច្ចសន្យា អត្រាការប្រាក់ត្រូវគណនាតាមអត្រាការប្រាក់ទីផ្សារ ។

៣-អត្រាការប្រាក់តាមចំណុចទី ១ នៃមាត្រានេះដែលត្រូវបង់ប្រចាំខែត្រូវអនុវត្តតែនៅពេលផុតរយៈពេល ៣០(សាមសិប) ថ្ងៃ ក្រោយពេលបើកសំណុំរឿងក្ស័យធន ហើយបន្តបង់ក្នុងរយៈពេលដែលអភិបាលបណ្តោះអាសន្នមិនបានលក់ទ្រព្យនោះ ។ ប្រាក់បានពីការលក់ត្រូវបានយកមកទូទាត់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ។

មាត្រា ២៨.-

១-តុលាការអាចសម្រេចថាកូនបំណុលជារូបវន្តបុគ្គល និងគ្រួសាររបស់កូនបំណុលអាចទទួល ឬ មិនអាចទទួលចំណែកពីការថែរក្សាទ្រព្យរបស់កូនបំណុល ។

២-មុនពេលមានសេចក្តីសម្រេចពីតុលាការតាមចំណុចទី ១ ខាងលើ អភិបាលបណ្តោះអាសន្នដោយមានការយល់ព្រមពីគណៈកម្មការម្ចាស់បំណុល អាចដកថ្លៃថែរក្សា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទ្រព្យកូនបំណុលទៅឱ្យកូនបំណុលដែលជារូបវន្តបុគ្គល និងទៅឱ្យគ្រួសាររបស់កូនបំណុល តាមកម្រិតចាំបាច់សម្រាប់ទ្រទ្រង់ការរស់នៅ ។

មាត្រា ២៩.-

១-យ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយពេលបើកសំណុំរឿងក្ស័យធន កូនបំណុល ត្រូវដាក់ជូនតុលាការ និងអភិបាលបណ្តោះអាសន្ននូវសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដែលចែងលំអិតអំពី :

ក-ទ្រព្យរបស់កូនបំណុល និង

ខ-ម្ចាស់បំណុលទាំងអស់របស់កូនបំណុល ដោយបញ្ជាក់ពីឈ្មោះម្ចាស់បំណុល អាសយដ្ឋាន និងសេចក្តីបញ្ជាក់សង្ខេបអំពីបំណុលដែលជំពាក់ម្ចាស់បំណុលនីមួយៗ ។

២-កូនបំណុលត្រូវយល់ព្រមឱ្យមានការត្រួតពិនិត្យលើទ្រព្យសម្បត្តិនិងកិច្ចការអាជីវកម្មរបស់ខ្លួន នៅពេលដែលមានសំណើពីអភិបាលបណ្តោះអាសន្ន ឬ តុលាការ ។

ផ្នែកទី ២

ការថែរក្សាការពារ និងការពង្រីកទ្រព្យសម្បត្តិរបស់កូនបំណុល

មាត្រា ៣០.-

១-នៅពេលបើកសំណុំរឿងក្ស័យធន បើកិច្ចសន្យារវាងកូនបំណុល និង ភាគីនៃកិច្ចសន្យាមិនទាន់បានអនុវត្តចប់សព្វគ្រប់ដោយកូនបំណុល ឬ ដោយភាគីនៃកិច្ចសន្យា អភិបាលបណ្តោះអាសន្នអាចសម្រេចឱ្យបន្តអនុវត្តកិច្ចសន្យាស្របតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

២-អភិបាលបណ្តោះអាសន្នដែលសម្រេចឱ្យបន្តអនុវត្តកិច្ចសន្យាត្រូវតែប្រកាសពីសេចក្តីសម្រេចនេះជាលាយលក្ខណ៍អក្សរជូនភាគីនៃកិច្ចសន្យា ក្នុងរយៈពេល ៣០ (សាម សិប)ថ្ងៃ គិតចាប់ពីពេលបើកសំណុំរឿងក្ស័យធន ។

ក្នុងករណីគ្មានសេចក្តីប្រកាសជាលាយ

លក្ខណ៍អក្សរដែលចេញដោយអភិបាលបណ្តោះអាសន្នទេ កិច្ចសន្យានឹងត្រូវចាត់ទុកថាបានរំលាយ ហើយភាគីនៃកិច្ចសន្យាអាចដាក់បណ្តឹងសុំទាមទារសំណងខូចខាតក្នុងឋានៈជាម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធន ។ នៅពេលទទួលពាក្យសុំពន្យារពេលជាលាយលក្ខណ៍

អក្សរពីអភិបាលបណ្តោះអាសន្ន តុលាការអាចពន្យារពេលដែលក្នុងរយៈពេលនេះ អភិ-បាលបណ្តោះអាសន្នត្រូវតែប្រកាសសេចក្តីសម្រេចថាត្រូវបន្ត ឬ មិនត្រូវបន្តកិច្ចសន្យា ។ រាល់ការពន្យារពេលបែបនេះ មិនត្រូវមានរយៈពេលលើសពី ១៤(ដប់បួន)ថ្ងៃឡើយ ។

៣-ភាគីនៃកិច្ចសន្យាក៏អាចធ្វើសំណើជាលាយលក្ខណ៍អក្សរ ជូនអភិបាលបណ្តោះអាសន្នគ្រប់ពេលវេលាបានដែរ ដោយសុំឱ្យអភិបាលបណ្តោះអាសន្នគោរពតាមកិច្ចសន្យានេះ ។ ក្នុងករណីគ្មានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរពីអភិបាលបណ្តោះអាសន្នក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីនៃកិច្ចសន្យាបានដាក់សំណើនោះ កិច្ចសន្យានឹងត្រូវចាត់ទុកថាបានបញ្ចប់ ហើយភាគីនៃកិច្ចសន្យាអាចប្តឹងទាមទារសំណងខូចខាតក្នុងឋានៈជាម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធន ។ នៅពេលទទួលពាក្យសុំពន្យារពេលជាលាយលក្ខណ៍អក្សរពីអភិបាលបណ្តោះអាសន្ន តុលាការអាចពន្យារអំឡុងពេលមួយដែលក្នុងរយៈពេលនេះ អភិបាលបណ្តោះអាសន្នត្រូវតែប្រកាសសេចក្តីសម្រេចថា ខ្លួនត្រូវគោរពតាម ឬ មិនគោរពតាមកិច្ចសន្យា ។ រាល់ការពន្យារពេលបែបនេះមិនត្រូវមានរយៈពេលលើសពី ១៤(ដប់បួន) ថ្ងៃឡើយ ។

៤-ក្នុងករណីដែលកិច្ចសន្យាជាកិច្ចសន្យាទិញ-លក់មូលបត្រ សិទ្ធិ ឬ ទំនិញឯទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះនៅក្នុងទីផ្សារ ឬ ទីផ្សារមូលបត្រជាផ្នែកមួយនៃកិច្ចព្រមព្រៀងក្របខណ្ឌទូលំទូលាយដែលរួមបញ្ចូលនូវកិច្ចសន្យាជាច្រើន ការសម្រេចរបស់អភិបាលបណ្តោះអាសន្នថាត្រូវបន្តកិច្ចសន្យា ត្រូវតែធ្វើឡើងសម្រាប់ជាអត្ថប្រយោជន៍ដល់កិច្ចសន្យាទាំងអស់តាមកិច្ចព្រមព្រៀងក្របខណ្ឌរួម ។

អភិបាលបណ្តោះអាសន្នមិនអាច

សម្រេចបន្តអនុវត្តតែកិច្ចសន្យាមួយចំនួនដែលមានក្នុងកិច្ចព្រមព្រៀងក្របខណ្ឌនេះឡើយ ។

៥-ចំពោះការសម្រេចរបស់អភិបាលបណ្តោះអាសន្នក្នុងការបន្តអនុវត្តកិច្ចសន្យាដែលតម្រូវឱ្យមានការបង់ប្រាក់ជាទៀងទាត់ចំពោះភាគីនៃកិច្ចសន្យា ការសម្រេចនេះមិនមានអានុភាពកំណត់ការបង់ប្រាក់ដែលមិនទាន់បានបង់មុនពេលបើកសំណុំរឿងក្ស័យធនឡើយ ។

៦-រាល់សិទ្ធិលើបំណុលដែលកើតចេញពីកិច្ចសន្យា ដែលអភិបាលបណ្តោះអាសន្នបានសម្រេចឱ្យបន្តអនុវត្ត ត្រូវចាត់ទុកជាបណ្តឹងទាមទារចំណាយខាងរដ្ឋបាលដែលធ្វើ

ឡើង ដោយអភិបាលបណ្តោះអាសន្នក្នុងដំណើរការសំណុំរឿងក្ស័យធន ហើយត្រូវអនុលោមតាមលំដាប់អាទិភាពដែលមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះ ។

មាត្រា ៣១.-

១-សេវាប្រើប្រាស់ចាំបាច់មិនត្រូវបញ្ចប់ កែប្រែ ឬ កាត់ផ្តាច់ពីអភិបាលបណ្តោះអាសន្ន ឬ កូនបំណុល ដោយផ្អែកតែលើមូលហេតុនៃការបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល ឬ មូលហេតុដែលកូនបំណុលនៅជំពាក់ថ្លៃសេវាប្រើប្រាស់ចាំបាច់ដែលបានប្រើប្រាស់ មុនពេលបើកសំណុំរឿងក្ស័យធននេះឡើយ ។

២-ដោយគ្មានប៉ះពាល់ដល់សិទ្ធិរបស់អភិបាលបណ្តោះអាសន្នក្នុងការសម្រេចបន្តអនុវត្តកិច្ចសន្យាដោយអនុលោមតាមមាត្រា ៣០ នៃច្បាប់នេះ អ្នកផ្តល់សេវាប្រើប្រាស់ចាំបាច់អាចបដិសេធការបន្តកិច្ចសន្យាក្នុងការផ្តល់សេវាជូនកូនបំណុល បើអភិបាលបណ្តោះអាសន្នមិនបានផ្តល់កិច្ចធានាបង់ប្រាក់គ្រប់គ្រាន់ ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបើកសំណុំរឿងក្ស័យធនក្នុងរូបភាពជាប្រាក់កក់ ឬ ប្រាក់ធានាសម្រាប់សេវាដែលត្រូវផ្តល់តាមការបន្តកិច្ចសន្យា បន្ទាប់ពីថ្ងៃបើកសំណុំរឿងក្ស័យធន ។

មាត្រា ៣២.-

តាមបណ្តឹងរបស់អភិបាលបណ្តោះអាសន្ន និងក្រោយពេលស្តាប់សវនាការរបស់ភាគីម្ខាងទៀត តុលាការអាចសម្រេចចាត់ទុកជាមោឃៈនូវប្រតិបត្តិការមួយចំនួន ហើយអាចប្រកាសវិធានការសមស្របតាមមាត្រា ៣៣ នៃច្បាប់នេះ ។ ប្រតិបត្តិការជាក់លាក់ទាំងនោះមានដូចខាងក្រោម ៖

១-ប្រតិបត្តិការដែលធ្វើឡើងដោយកូនបំណុលក្នុងគោលបំណងបន្លំ ម្ចាស់បំណុលដោយលាក់បាំងទ្រព្យរបស់ខ្លួនមិនឱ្យម្ចាស់បំណុលរកឃើញ ។

២-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ៣(បី) ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលមិនបានទទួលតម្លៃតបស្នងអ្វីពីប្រតិបត្តិការនោះ លើកលែងតែប្រតិបត្តិការ[illegible]ណាដែលជាប្រយោជន៍របស់សហព័ទ្ធ របស់កូនបំណុល ឬ ញាតិខ្សែផ្ទាល់របស់[illegible] ញាតិ ឬ បុព្វញាតិ ។

៣-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកាតព្វកិច្ចរបស់កូនបំណុលមានតម្លៃច្រើនជាងតម្លៃកាតព្វកិច្ចភាគីម្ខាងទៀត ។

៤-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលបានទូទាត់បំណុលដែលមិនទាន់ដល់កាលកំណត់សង ឬ ផ្តល់វត្ថុធានាថ្មី ឬ វត្ថុធានាបន្ថែមលើបំណុលហើយ ដែលភាគីម្ខាងទៀតនៃប្រតិបត្តិការជាបុគ្គលមានការពាក់ព័ន្ធ ។

៥-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល៦ (ប្រាំមួយ)ខែមុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលបានទូទាត់បំណុលដែលមិនទាន់ដល់កាលកំណត់សង ឬ ផ្តល់វត្ថុធានាថ្មី ឬវត្ថុធានាបន្ថែមលើបំណុលហើយដែលភាគីម្ខាងទៀតមិនមែនជាបុគ្គលមានការពាក់ព័ន្ធ ។

៦-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលបានទូទាត់បំណុលដែលមិនទាន់ដល់កាលកំណត់សង ឬ ផ្តល់វត្ថុធានាថ្មី ឬ ផ្តល់សិទ្ធិលើទ្រព្យធានាសម្រាប់បំណុលដែលមានប្រភេទដូចបានរៀបរាប់ នៅក្នុងមាត្រា ៣៦ ចំណុចទី ៥ នៃច្បាប់នេះ ។

មាត្រា ៣៣.-

១-នៅពេលដែលប្រតិបត្តិការ ឬ ការផ្ទេរត្រូវបានប្រកាសមោឃភាពក្នុងមាត្រា ៣២ នៃច្បាប់នេះ រាល់សាច់ប្រាក់ទ្រព្យសម្បត្តិដែលបានផ្ទេរ ឬ ថ្លៃលក់ទ្រព្យសម្បត្តិដែលបានផ្ទេរនឹងត្រូវទាមទារយកវិញ និងត្រូវដាក់បញ្ចូលក្នុងទ្រព្យកូនបំណុល ។

២-បុគ្គលដែលត្រូវគេប្តឹងទារប្រាក់ ឬ ទ្រព្យសម្បត្តិដោយសារមោឃភាពនៃប្រតិបត្តិការមានសិទ្ធិទទួលតម្លៃតបស្នងចំពោះតម្លៃដែលខ្លួនបានផ្តល់សម្រាប់ប្រតិបត្តិការនោះ ។ ការសងមកវិញត្រូវដកចេញពីទ្រព្យកូនបំណុលត្រឹមកម្រិត ដែលទ្រព្យប្រតិបត្តិការនៅមានក្នុងចំណោមទ្រព្យកូនបំណុល ។ បុគ្គលនេះក៏ត្រូវមានសិទ្ធិប្តឹងទាមទារសំណងក្នុងឋានៈជាម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធនដែរ ។

១-នៅថ្ងៃបើកសំណុំរឿងក្ស័យធន តាមអានុភាពច្បាប់ ឬ តាមអានុភាពនៃកិច្ចសន្យា ប្រសិនបើម្ចាស់បំណុលមានសិទ្ធិធ្វើការទូទាត់ជម្រះការទាមទារសំណងជាមួយនឹងកាតព្វកិច្ចដែលខ្លួនជំពាក់កូនបំណុល ការបើកសំណុំរឿងក្ស័យធនមិនមានអានុភាពលើសិទ្ធិទូទាត់ជម្រះនេះទេ ។

២-ក្នុងករណីដែលមានបណ្តឹងតវ៉ាពីកូនបំណុល ការយកទ្រព្យកូនបំណុលមកទូទាត់ជម្រះដោយម្ចាស់បំណុល ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើ ៖

ក-ម្ចាស់បំណុលបានក្លាយទៅជាកូនបំណុលនៃទ្រព្យ បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន

ខ-ម្ចាស់បំណុលទទួលបានបណ្តឹងទាមទារពីម្ចាស់បំណុលម្នាក់ផ្សេងទៀត បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន

គ-ម្ចាស់បំណុលទទួលបានសិទ្ធិធ្វើការទូទាត់ជម្រះ តាមរយៈប្រតិបត្តិការពាណិជ្ជកម្មដែលជាកម្មវត្ថុនៃការតវ៉ា ឬ មោឃភាពតាមច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត

ឃ-បណ្តឹងទាមទាររបស់ម្ចាស់បំណុលស្ថិតនៅក្នុងប្រភេទដែលមានចែងក្នុងមាត្រា ៣៦ នៃច្បាប់នេះ ។

ផ្នែកទី ៣
សិទ្ធិលើបំណុល

មាត្រា ៣៥.-

១-ទ្រព្យកូនបំណុលត្រូវបានយកមកទូទាត់សងការទាមទារបំណុលសមស្របទល់នឹងកូនបំណុល និងការទាមទារចំណាយខាងរដ្ឋបាល ។ បណ្តឹងទាមទារចំណាយខាងរដ្ឋបាលត្រូវរួមបញ្ចូលនូវប្រាក់បំណាច់ថ្លៃសេវា និងការចំណាយនានារបស់អភិបាលបណ្តោះអាសន្នក្នុងដំណើរការរឿងក្តី ។

២-សិទ្ធិលើបំណុលដែលមិនទាន់ដល់កាលកំណត់សងនាកាលបរិច្ឆេទ ជម្រះបញ្ជី ត្រូវចាត់ទុកដូចជាដល់កាលកំណត់សង នៅកាលបរិច្ឆេទជម្រះបញ្ជី ។

៣-សិទ្ធិលើបំណុលដែលស្ថិតនៅក្រោមលក្ខខណ្ឌដោះស្រាយ ត្រូវចាត់ទុកថាជាសិទ្ធិលើបំណុលគ្មានលក្ខខណ្ឌ ដរាបណាលក្ខខណ្ឌនោះមិនទាន់ត្រូវបានបំពេញទេ ។

មាត្រា ៣៦.-

បណ្តឹងទាមទារបំណុលដូចខាងក្រោមនេះ មិនអាចទទួលយកបានទេក្នុងសំណុំរឿងក្ស័យធន :

១-ការប្រាក់ដែលកើនលើសិទ្ធិលើបំណុល ចាប់ពីកាលបរិច្ឆេទនៃការបើកសំណុំរឿងក្ស័យធន ។

២-ថ្លៃចំណាយរបស់ម្ចាស់បំណុលក្នុងការចូលរួមក្នុងសំណុំរឿងក្ស័យធន ។

៣-ប្រាក់ពិន័យ និងផលវិបាកដែលកើតជាយថាហេតុពីបទល្មើសព្រហ្មទណ្ឌ ប្រាក់ពិន័យរដ្ឋបាល និងផលវិបាកដែលកើតជាយថាហេតុពីបទល្មើសរដ្ឋបាលដែលតម្រូវឱ្យកូនបំណុលបង់ប្រាក់ ។

៤-បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ចដែលគ្មានតម្លៃតបស្នង ។

៥-បណ្តឹងទាមទារឱ្យ សងប្រាក់ផ្ញើឡើងដោយបុគ្គលណាមួយដែលកាន់កាប់ផ្ទាល់ ឬ ដោយប្រយោលលើដើមទុនរបស់កូនបំណុលលើសពី ១០ (ដប់ភាគរយ) ដែលបានឱ្យខ្ចី ឬ បណ្តាលឱ្យមានបំណុលនោះដោយចៃដន្យ ឬ បានធ្វើកិច្ចធានា ឬ បានដាក់ទ្រព្យធានាឱ្យកូនបំណុល ។ ប្រសិនបើកូនបំណុលជាក្រុមហ៊ុនសហកម្មសិទ្ធិ បណ្តឹងទាមទារក្នុង កថាខណ្ឌនេះ ត្រូវអនុវត្តតែក្នុងករណីដែលសហកម្មសិទ្ធិករទូទៅរបស់កូនបំណុលជាក្រុម ហ៊ុនមូលធន ។

៦-បណ្តឹងទាមទារដែលកូនបំណុលរួមគ្នា ឬ អ្នកធានាអាចប្រឆាំងនឹងកូនបំណុល ប្រសិនបើកូនបំណុលរួមគ្នានេះបានទូទាត់តាមការទាមទាររបស់ម្ចាស់បំណុល ។

៧-សិទ្ធិលើបំណុលដែលភស្តុតាងនៃបណ្តឹងទាមទារ ត្រូវបានដាក់ជូនក្រោយកាលកំណត់ឱ្យដាក់ជូនភស្តុតាងនោះ ។

៨-បណ្តឹងទាមទារបំណុលបន្ទាប់បន្សំដែលគ្មានអានុភាពក្នុងសំណុំរឿងក្ស័យធនដែលបានព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ។

៩-ផលប្រយោជន៍នៃសិទ្ធិលើបំណុលដែលមានប្រភេទដូចពោលខាងលើ ។

មាត្រា ៣៧.-

បំណុលដែលមិនមែនជាសាច់ប្រាក់ ត្រូវចូលទាត់ជាតម្លៃប៉ាន់ស្មានជាប្រាក់រៀល នៅកាលបរិច្ឆេទបើកសំណុំរឿងក្ស័យធន ។ បណ្តឹងទាមទារបំណុលដែលកំណត់ប្រាក់ជារូបិយប័ណ្ណបរទេស ឬ កំណត់ឯកតាប្តូរប្រាក់ផ្សេងទៀតនឹងត្រូវប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា នៅកាលបរិច្ឆេទបើកសំណុំរឿងក្ស័យធន ។

មាត្រា ៣៨.-

១-ម្ចាស់បំណុលត្រូវដាក់រាល់ភស្តុតាងនៃសិទ្ធិលើបំណុលជូនអភិបាលបណ្តោះអាសន្នជាលាយលក្ខណ៍អក្សរនៅកាលបរិច្ឆេទដែលបានកំណត់ ។

២-ភស្តុតាងនៃសិទ្ធិលើបំណុលនីមួយៗ ត្រូវមានព័ត៌មានដូចខាងក្រោមនេះ :

ក-មូលដ្ឋានគតិយុត្ត និងមូលហេតុនៃបណ្តឹងទាមទារ

ខ-ពេលវេលាដែលបណ្តឹងទាមទារកើតឡើង

គ-ទឹកប្រាក់នៃបណ្តឹងទាមទារ

ឃ-រាល់សិទ្ធិអាទិភាពដែលអាចមានភ្ជាប់ជាមួយបណ្តឹងទាមទារ តាមមាត្រា ៥៧ នៃច្បាប់នេះ

ង-លក្ខណៈ និងលំដាប់ថ្នាក់នៃទ្រព្យធានាដែលបញ្ជាក់ក្នុងទ្រព្យសម្បត្តិនៃកូនបំណុល និងសេចក្តីបញ្ជាក់លម្អិតអំពីទ្រព្យដែលដាក់ធានា

ច-ឯកសារទាំងឡាយ និងភស្តុតាងដទៃទៀតប្រសិនបើមាន ។

៣-អភិបាលបណ្តោះអាសន្នត្រូវតែជួយម្ចាស់បំណុលក្នុងការបំពេញទម្រង់បែបបទច្បាប់ ។

មាត្រា ៣៩.-

១-អភិបាលបណ្តោះអាសន្នត្រូវរៀបចំបញ្ជីនៃបណ្តឹងទាមទារ ដោយបញ្ជាក់លម្អិតពីបណ្តឹងទាមទារទាំងអស់ដែលម្ចាស់បំណុលបានដាក់ជូន ដោយអនុលោមតាមមាត្រា ៣៨ នៃច្បាប់នេះ ។ បញ្ជីនៃបណ្តឹងទាមទារត្រូវដាក់ជូនតុលាការមិនឱ្យលើសពី ៥ (ប្រាំ) ថ្ងៃមុន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

កាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុលឡើយ ។ បញ្ជីនៃបណ្តឹងទាមទារត្រូវផ្តល់លទ្ធភាពឱ្យបុគ្គលគ្រប់រូបអាចពិនិត្យមើលបានដោយឥតគិតថ្លៃ ។

២-បញ្ជីនៃបណ្តឹងទាមទារ ត្រូវមានព័ត៌មានសង្ខេបតាមបែបបទងាយយល់ ដោយអនុលោមតាមមាត្រា ៣៨ ចំណុចទី ២ ក ដល់ចំណុចទី ២ ង ។ លើសពីនេះទៀតក្នុងករណីដែលទ្រព្យធានាស្ថិតក្នុងបណ្តឹងទាមទារ ការវាយតម្លៃលើផ្នែកដែលមានកិច្ចធានានៃបណ្តឹងទាមទារត្រូវកំណត់តាមមាត្រា ២៦ នៃច្បាប់នេះ ។

៣-បញ្ជីនៃបណ្តឹងទាមទារ នឹងត្រូវបានពិនិត្យផ្ទៀងផ្ទាត់នៅពេលបើកកិច្ចប្រជុំម្ចាស់បំណុល អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី ៦ នៃច្បាប់នេះ ។

ជំពូកទី ៥
ផែនការសម្របសម្រួល
ផ្នែកទី ១
ការរៀបចំផែនការ

មាត្រា ៤០.-

រាល់សំណើផែនការសម្របសម្រួល ត្រូវដាក់ជូនតុលាការមិនឱ្យលើសពី ៧ (ប្រាំពីរ) ថ្ងៃមុនកាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុល ។ សំណើផែនការសម្របសម្រួលដែលបានដាក់ជូនតុលាការ ត្រូវផ្តល់លទ្ធភាពឱ្យសាធារណជនអាចពិនិត្យមើលបានដោយឥតគិតថ្លៃ ។

មាត្រា ៤១.-

១-ផែនការសម្របសម្រួល ត្រូវចែងពីរយៈពេលសម្រាប់អនុវត្ត និងអាចចែងពីវិធីដោះស្រាយអសាធនភាពរបស់កូនបំណុលដោយរាប់បញ្ចូលទាំង :

ក-ការលុបចោល ឬ ការកាត់បន្ថយទឹកប្រាក់ក្នុងសិទ្ធិលើបំណុលណាមួយ ដូចជាការប្តូរយកជាភាគហ៊ុន ឬ ទ្រព្យសម្បត្តិក្នុងអាជីវកម្មរបស់កូនបំណុល

ខ-ការកំណត់កាលវិភាគសម្រាប់ទូទាត់ប្រាក់ក្នុងបណ្តឹងទាមទារ

គ-ការបន្តអាជីវកម្មរបស់កូនបំណុល ឬ ផ្នែកណាមួយនៃអាជីវកម្មនេះដោយកូនបំណុលផ្ទាល់ ឬ បុគ្គលផ្សេងទៀត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឃ-ការលក់ ការជម្រះនូវទ្រព្យសម្បត្តិរបស់កូនបំណុល ទោះស្ថិតក្នុងការដាក់ធានា ឬ មិនស្ថិតក្នុងការដាក់ធានា ឬ សិទ្ធិឃាត់ទុករបស់តតិយជនក៏ដោយ ឬ ការបែងចែកទ្រព្យកូនបំណុលមួយផ្នែក ឬ ទាំងអស់ឱ្យទៅបុគ្គលដែលមានសិទ្ធិលើទ្រព្យទាំងនោះក៏ដោយ ។

២-ផែនការសម្របសម្រួល ត្រូវតែចែងពីការទូទាត់គ្រប់ចំនួននូវថ្លៃចំណាយក្នុងសំណុំរឿង និងបណ្តឹងទាមទារចំណាយខាងរដ្ឋបាលផ្សេងទៀត និង បណ្តឹងទាមទារដែលបានធ្វើឡើងដោយអភិបាលបណ្តោះអាសន្នក្នុងរយៈពេលដំណើរការសំណុំរឿងក្ស័យធន ។

មាត្រា ៤២.-

សិទ្ធិលើបំណុលដែលគ្មានការទទួលស្គាល់ មិនត្រូវបានដាក់ចូលក្នុងផែនការសម្របសម្រួលទេ លើកលែងតែសិទ្ធិលើបំណុលដែលធ្វើឡើងតាមមាត្រា ៣៩ ចំណុចទី ៣ នៃច្បាប់នេះ ។

មាត្រា ៤៣.-

ថ្លៃចំណាយដែលកើតឡើងពីការរៀបចំសំណើផែនការសម្របសម្រួលរបស់កូនបំណុល ឬ អភិបាលបណ្តោះអាសន្ន ត្រូវចាត់ទុកជាបន្ទុកចំណាយខាងរដ្ឋបាល ដែលត្រូវទូទាត់ដោយទ្រព្យរបស់កូនបំណុល ។ ឯថ្លៃចំណាយដែលកើតចេញពីសំណើផែនការផ្សេងៗទៀត ត្រូវចាត់ទុកជាបន្ទុកចំណាយរបស់ភាគីដែលលើកសំណើនោះ ។

ផ្នែកទី ២

ការឯកភាពលើផែនការសម្របសម្រួល

មាត្រា ៤៤.-

ផែនការសម្របសម្រួលត្រូវដាក់សុំការពិនិត្យ និងឯកភាពពីម្ចាស់បំណុលក្នុងពេលបើកកិច្ចប្រជុំម្ចាស់បំណុល ឬ កិច្ចប្រជុំផ្សេងទៀតដែលកោះប្រជុំសម្រាប់គោលបំណងនេះ ។

មាត្រា ៤៥.-

១-ក្នុងការអនុម័តផែនការសម្របសម្រួល ម្ចាស់បំណុលនឹងត្រូវបានបញ្ចូលជាក្រុមតាមប្រភេទ និងត្រូវបោះឆ្នោតស្របតាមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនតាមប្រភេទនីមួយៗដូចខាងក្រោមនេះ ៖

ROYAUME DU CAMBODGE

ក-ម្ចាស់បំណុលដែលមានបណ្តឹងទាមទារដែលមានកិច្ចធានា

ខ-ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលដែលស្ថិតនៅក្រោមមាត្រា ៥៧ ចំណុចទី ១-គ នៃច្បាប់នេះ

គ-ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលដែលស្ថិតនៅក្រោមមាត្រា ៥៧ ចំណុចទី ១-ឃ នៃច្បាប់នេះ ។

២-ផែនការសម្របសម្រួល ត្រូវតែមានការឯកភាពពី :

ក-ម្ចាស់បំណុលគ្រប់ប្រភេទ តាមរយៈការបោះឆ្នោតគាំទ្ររបស់ម្ចាស់បំណុលនៅតាមប្រភេទនីមួយៗ ដែលមានសិទ្ធិលើបំណុលមិនតិចជាង ៣/៤ (បីភាគបួន)នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ដែលមានវត្តមានក្នុងកិច្ចប្រជុំបោះឆ្នោត ឬ

ខ-យ៉ាងហោចណាស់ពីម្ចាស់បំណុលមួយប្រភេទ តាមរយៈការបោះឆ្នោតគាំទ្ររបស់ម្ចាស់បំណុលនៅក្នុងប្រភេទនោះដែលមានសិទ្ធិលើបំណុលមិនតិចជាង ៣/៤(បីភាគបួន) នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលមានវត្តមានក្នុងកិច្ចប្រជុំបោះឆ្នោត ។

មាត្រា ៧៦.-

សិទ្ធិបោះឆ្នោតរបស់ម្ចាស់បំណុលក្នុងការបោះឆ្នោតលើផែនការសម្របសម្រួលត្រូវអនុលោមតាមមាត្រា ៧៥ នៃច្បាប់នេះ និងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដូចខាងក្រោមនេះ :

១-ម្ចាស់បំណុលដែលសិទ្ធិលើបំណុលរបស់ខ្លួនមិនខូចខាត ឬរងផលប៉ះពាល់ពីផែនការសម្របសម្រួល មិនត្រូវមានសិទ្ធិបោះឆ្នោតទេ និង

២-ម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិបោះឆ្នោតចំពោះតែ :

ក-ក្នុងករណីដែលទឹកប្រាក់សរុបក្នុងសិទ្ធិលើបំណុលលើសពី :

-តម្លៃទ្រព្យដែលមានកិច្ចធានាតាមការកំណត់របស់មាត្រា ២៦ នៃច្បាប់នេះ ឬ

-លើសពីតម្លៃនៃប្រាក់ថ្លៃលក់ទ្រព្យធានា ឬ

ខ-ក្នុងករណីដែលម្ចាស់បំណុលលះបង់សិទ្ធិលើទ្រព្យដែលបានដាក់ធានា

មាត្រា ៩៧.-

១-ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីម្ចាស់បំណុលទាំងអស់បានឯកភាពលើផែនការសម្របសម្រួលតាមលក្ខខណ្ឌនៃមាត្រា ៩៥ នៃច្បាប់នេះ អភិបាលបណ្តោះអាសន្នត្រូវដាក់ពាក្យសុំឱ្យតុលាការទទួលស្គាល់ផែនការសម្របសម្រួល ។

២-តុលាការត្រូវចេញសេចក្តីសម្រេចទទួលស្គាល់ផែនការសម្របសម្រួល បើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

ក-ការបោះឆ្នោតត្រូវបានធ្វើឡើងស្របតាមលក្ខខណ្ឌនៃច្បាប់នេះ

ខ-តាមផែនការសម្របសម្រួល ម្ចាស់បំណុលគ្រប់ប្រភេទទាំងអស់នឹងត្រូវចាត់ទុកថា មានសិទ្ធិស្មើគ្នាក្នុងប្រភេទដូចគ្នា លើកលែងតែម្ចាស់បំណុលបានយល់ព្រមជាលាយលក្ខណ៍អក្សរថាស្ថិតក្នុងឋិតាប់អាទិភាពទាបជាងម្ចាស់បំណុលផ្សេងទៀត

គ-តាមផែនការសម្របសម្រួល រាល់ម្ចាស់បំណុលដែលទាមទារនឹងទទួលបានការទូទាត់ចំពោះការទាមទារតាមកម្រិត ដែលមិនតិចជាងកម្រិតដែលម្ចាស់បំណុលនេះអាចនឹងទទួលបានពីការបែងចែកក្នុងពេលជម្រះបញ្ជីដោយអនុលោមតាមមាត្រា ៩៧ នៃច្បាប់នេះ

ឃ-តាមផែនការសម្របសម្រួលនេះ គ្មានម្ចាស់បំណុលណាម្នាក់អាចទទួលបានទឹកប្រាក់ច្រើនជាងទឹកប្រាក់សរុបក្នុងបណ្តឹងទាមទាររបស់ខ្លួនឡើយ

ង-តាមផែនការសម្របសម្រួលនេះ គ្មានការទូទាត់ដែលទាក់ទិននឹងប្រាក់ចំណូលភាគលាភ ឬ ភាគទុនទៅឱ្យម្ចាស់ភាគហ៊ុន ឬ សហកម្មសិទ្ធិករនៃកូនបំណុលឡើយ រហូតទាល់តែបានបែងចែកប្រាក់ជូនអ្នកមានសិទ្ធិតាមប្រភេទនៃម្ចាស់បំណុល ដែលមានការទាមទារក្នុងផែនការសម្របសម្រួលរួចរាល់សិន

ច-តាមផែនការសម្របសម្រួលនេះ មិនត្រូវធ្វើការទូទាត់ថ្លៃថែទាំណាដែលច្រើនជាងប្រាក់ថ្លៃថែទាំដែលតុលាការបានកំណត់ចំពោះកូនបំណុលដែលជារូបវន្តបុគ្គល ឬសហកម្មសិទ្ធិករទូទៅរបស់កូនបំណុលដែលជាក្រុមហ៊ុនសហកម្មសិទ្ធិឡើយ រហូតទាល់តែបានបែងចែកប្រាក់ជូនអ្នកមានសិទ្ធិតាមថ្នាក់នៃម្ចាស់បំណុលដែលមានការទាមទារក្នុងផែនការសម្របសម្រួលរួចហើយ ។

ROYAUME DU CAMBODGE · LE MINISTRE ... PALAIS ROYAL
ព្រះបរមរាជវាំង

៣-បើផែនការសម្របសម្រួលមិនបានបំពេញតាមលក្ខខណ្ឌដែលចែងក្នុងចំណុចទី ២ នៃមាត្រានេះទេ តុលាការត្រូវសម្រេចដើម្បីចាប់ផ្តើមការជម្រះបញ្ជីលើទ្រព្យកូនបំណុល ។

៤-ការសម្រេចរបស់តុលាការតាមមាត្រានេះ ត្រូវធ្វើឡើងមិនឱ្យលើសពី ៧(ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអភិបាលបណ្តោះអាសន្នបានដាក់ពាក្យសុំឱ្យតុលាការទទួលស្គាល់លើផែនការសម្របសម្រួល ។

មាត្រា ៤៨.-

១-ការទទួលស្គាល់របស់តុលាការលើផែនការសម្របសម្រួលត្រូវមានអានុភាពបញ្ចប់សំណុំរឿងក្ស័យធន ហើយត្រូវចាប់ផ្តើមរយៈពេលនៃការអនុវត្តផែនការសម្របសម្រួលដែលបានកំណត់ ប៉ុន្តែការអនុវត្តផែនការនេះមិនត្រូវលើសពីរយៈពេលអតិបរមា ២(ពីរ) ឆ្នាំឡើយ បន្ទាប់ពីតុលាការបានទទួលស្គាល់លើផែនការសម្របសម្រួល ។

២-ផែនការសម្របសម្រួលដែលត្រូវបានទទួលស្គាល់ដោយតុលាការ ត្រូវភ្ជាប់កាតព្វកិច្ចលើម្ចាស់បំណុលទាំងអស់ ហើយរំលត់រាល់សិទ្ធិលើបំណុលដែលមិនអាចទទួលស្គាល់ក្រៅពីសិទ្ធិលើបំណុលដូចមានចែងក្នុងមាត្រា ៣៦ ចំណុចទី ៣ នៃច្បាប់នេះ ។

មាត្រា ៤៩.-

១-ក្នុងរយៈពេលអនុវត្តផែនការសម្របសម្រួល រាល់ឯកសារអាជីវកម្មដែលចេញដោយកូនបំណុល ឬ ក្នុងនាមកូនបំណុលដែលមានសរសេរឈ្មោះកូនបំណុលត្រូវមានសេចក្តីបញ្ជាក់ពិស្តារ ដើម្បីអនុញ្ញាតឱ្យផែនការសម្របសម្រួលអាចអនុវត្តចំពោះកូនបំណុលបាន ។

២-នៅពេលអនុម័តផែនការសម្របសម្រួល ឬ នៅកាលបរិច្ឆេទក្រោយពីនេះ ក្នុងគោលបំណងធានាការអនុវត្តផែនការសម្របសម្រួល តុលាការអាចបង្គាប់ឱ្យអភិបាលបណ្តោះអាសន្នបន្តការគ្រប់គ្រងតាមលក្ខខណ្ឌដែលតុលាការយល់ថា សមស្របនូវសកម្មភាពរបស់កូនបំណុល ឬ សកម្មភាពផ្នែកជាក់ចែងការងាររបស់កូនបំណុល ។ ក្នុងការធ្វើសេចក្តីសម្រេចតាមចំណុចនេះតុលាការក៏ត្រូវកំណត់ចំនួនប្រាក់ចំណាយនានាសម្រាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

អភិបាលបណ្តោះអាសន្នដែលត្រូវទូទាត់ដោយកូនបំណុលដែរ ។

មាត្រា ៥០.-

១-ក្នុងករណីដែលផែនការសម្របសម្រួល មិនត្រូវបានអនុវត្តតាមរយៈពេលដែលបានកំណត់ តុលាការត្រូវសម្រេចបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល ។

២-ការដាក់ពាក្យសុំបើកសំណុំរឿងក្ស័យធនតាមចំណុចទី ១ ខាងលើអាចធ្វើឡើងដោយកូនបំណុល ម្ចាស់បំណុល ឬ តំណាងអយ្យការ ឬ អភិបាលបណ្តោះអាសន្ន ដូចចែងក្នុងមាត្រា ៤៩ ចំណុចទី ២ នៃច្បាប់នេះ ។

៣-សំណុំរឿងក្ស័យធនដែលបើកឡើងតាមចំណុចទី ១ ខាងលើ ត្រូវចាប់ផ្តើមភ្លាមៗជាមួយ និងការជម្រះបញ្ជីកូនបំណុល ។ អានុភាពនៃផែនការសម្របសម្រួលដែលទាក់ទិននឹងសិទ្ធិលើបំណុល សិទ្ធិលើទ្រព្យធានានិងសិទ្ធិផ្សេងៗទៀតរបស់ម្ចាស់បំណុល ត្រូវរក្សាទុកដដែលក្នុងការជម្រះបញ្ជីនេះ ។

ជំពូកទី ៦
ការបើកកិច្ចប្រជុំម្ចាស់បំណុល

មាត្រា ៥១.-

ដោយមានជំនួយពីអភិបាលបណ្តោះអាសន្ន ចៅក្រមត្រូវកោះប្រជុំ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំម្ចាស់បំណុលលើកដំបូង ។

មាត្រា ៥២.-

នៅពេលបើកកិច្ចប្រជុំម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវរាយការណ៍ពីស្ថានភាពអាជីវកម្មរបស់កូនបំណុល និងមូលហេតុដែលនាំឱ្យមានស្ថានភាពអាជីវកម្មបែបនេះ ។ អភិបាលបណ្តោះអាសន្នត្រូវតែបង្ហាញថាមាន ឬ គ្មានលទ្ធភាពក្នុងការបន្តអាជីវកម្មទាំងមូល ឬ មួយផ្នែករបស់កូនបំណុល មាន ឬ គ្មានលទ្ធភាពដែលត្រូវស្នើសុំការឯកភាពលើផែនការសម្របសម្រួល និងការអនុវត្តផែនការសម្របសម្រួលព្រមទាំងបញ្ជាក់ពីផលវិបាកដែលនឹងកើតឡើងចំពោះការទូទាត់ឱ្យម្ចាស់បំណុល ។

មាត្រា ៥៣.-

នៅក្នុងកិច្ចប្រជុំម្ចាស់បំណុល ម្ចាស់បំណុលត្រូវសម្រេចលើបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោមនេះ :

១-សម្រេចលើផែនការបន្តសំណុំរឿងក្ស័យធន ដោយផ្អែកតាមរបាយការណ៍របស់អភិបាលបណ្ដោះអាសន្ន ដែលរៀបចំសម្រាប់កិច្ចប្រជុំនេះ ។

២-សម្រេចលើផែនការសម្របសម្រួល ដែលត្រូវបានស្នើឡើងដោយកូនបំណុល ។

៣-ពិនិត្យផ្ទៀងផ្ទាត់សិទ្ធិលើបំណុល

៤-សម្រេចលើបញ្ហាផ្សេងទៀតដែលទាក់ទិននឹងសំណុំរឿងក្ស័យធន ។

មាត្រា ៥៤.-

១-បន្ទាប់ពីបានពិចារណាលើរបាយការណ៍របស់អភិបាលបណ្ដោះអាសន្ន បើផែនការសម្របសម្រួលត្រូវបានឯកភាពដោយម្ចាស់បំណុល ម្ចាស់បំណុលត្រូវបោះឆ្នោតសម្រេចលើផែនការសម្របសម្រួលនេះ ។

២-ក្នុងករណីដែលគ្មានសំណើផែនការសម្របសម្រួលរបស់កូនបំណុល ឬ សំណើផែនការសម្របសម្រួលមិនត្រូវបានឯកភាពដោយម្ចាស់បំណុល ម្ចាស់បំណុលត្រូវសម្រេចដើម្បី :

ក-ផ្អាកកិច្ចប្រជុំម្ចាស់បំណុល ប៉ុន្តែមិនត្រូវផ្អាកលើសពី ៦០ (ហុកសិប) ថ្ងៃទេ ដើម្បីឱ្យកូនបំណុល អភិបាលបណ្ដោះអាសន្ន ឬ ម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ដែលកាន់កាប់ទឹកប្រាក់សរុបមិនតិចជាង ១/៥ (មួយភាគប្រាំ) នៃបណ្ដឹងទាមទារទាំងអស់លើកសំណើផែនការសម្របសម្រួល ឬ

ខ-ចាប់ផ្ដើមការជម្រះបញ្ជីទ្រព្យកូនបំណុល ។

៣-បើកិច្ចប្រជុំម្ចាស់បំណុលត្រូវបានផ្អាកដោយអនុលោមតាមចំណុចទី ២ ក ខាងលើ នៅក្នុងកិច្ចប្រជុំដែលកោះហៅសាជាថ្មី ម្ចាស់បំណុលត្រូវពិចារណា និងបោះឆ្នោតតែលើផែនការសម្របសម្រួលណាដែលបានស្នើឡើងប៉ុណ្ណោះ ។ ក្នុងករណីដែលម្ចាស់បំណុល

ROYAUME ... ROUGE * LE MINISTRE DU PALAIS ROYAL

មិនឯកភាពលើផែនការសម្របសម្រួលក្នុងកិច្ចប្រជុំដែលកោះហៅសាជាថ្មីនេះ ការជម្រះបញ្ជីទ្រព្យកូនបំណុលនឹងត្រូវចាប់ផ្តើម ។

មាត្រា ៥៥.-

១-អភិបាលបណ្តោះអាសន្ន កូនបំណុល ឬ ម្ចាស់បំណុលអាចតវ៉ា ពីសុពលភាព ចំនួនទឹកប្រាក់ ការកំណត់សិទ្ធិលើទ្រព្យធានា ឬ អាទិភាពផ្សេងទៀតនៃសិទ្ធិលើបំណុលក្នុងបញ្ជីនៃសិទ្ធិលើបំណុល ។ សិទ្ធិលើបំណុលត្រូវបានទទួលស្គាល់ដើម្បីទូទាត់ក្នុងសំណុំរឿងក្ស័យធន ប្រសិនបើក្នុងករណីដែលសិទ្ធិលើបំណុលនោះគ្មានការតវ៉ាពីអភិបាលបណ្តោះអាសន្ន ឬ ពីម្ចាស់បំណុលណាម្នាក់ក្នុងកិច្ចប្រជុំម្ចាស់បំណុល ។

២-ក្នុងករណីដែលអភិបាលបណ្តោះអាសន្ន ឬ ម្ចាស់បំណុលតវ៉ាទៅនឹងសុពលភាព ចំនួនទឹកប្រាក់ ការកំណត់សិទ្ធិលើទ្រព្យធានា ឬ អាទិភាពឯទៀតនៃសិទ្ធិលើបំណុលនេះ ម្ចាស់បំណុលត្រូវស្វែងរកសាលក្រមសម្រេចលើសិទ្ធិលើបំណុលនេះតាមផ្លូវតុលាការ ។ តុលាការត្រូវបើកសវនាការលើករណីនេះឱ្យបានឆាប់បំផុត ។

៣-បញ្ជីនៃសិទ្ធិលើបំណុល ត្រូវរៀបចំដោយអភិបាលបណ្តោះអាសន្ន និងត្រូវតម្កល់នៅតុលាការ បន្ទាប់ពីមានការកែប្រែដែលចាំបាច់តាមអានុភាពនៃសេចក្តីសម្រេចចុងក្រោយដែលចែងក្នុងចំណុចទី ២ ខាងលើនេះ ។

ជំពូកទី ៧
ការជម្រះបញ្ជី និងការទូទាត់សិទ្ធិលើបំណុល

មាត្រា ៥៦.-

១-នៅពេលចាប់ផ្តើមការជម្រះបញ្ជី អភិបាលបណ្តោះអាសន្នត្រូវប្តូរទ្រព្យសកម្មដែលមិនមែនជាសាច់ប្រាក់របស់កូនបំណុលឱ្យទៅជាសាច់ប្រាក់ឱ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីឆ្លើយតបតម្រូវការនៃការទូទាត់បណ្តឹងទាមទាររបស់ម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធន ។

២-ក្នុងការចាត់ចែងទ្រព្យសកម្មរបស់កូនបំណុល អភិបាលបណ្តោះអាសន្នត្រូវប្រើប្រាស់មធ្យោបាយពាណិជ្ជកម្មសមស្របដែលនាំឱ្យទទួលបានទិន្នផលជាសាច់ប្រាក់ខ្ពស់បំផុតសម្រាប់កូនបំណុល ។

៣-ទ្រព្យសកម្មទាំងអស់របស់កូនបំណុលដែលមិនមែនជាសាច់ប្រាក់ ដែលអភិបាលបណ្តោះអាសន្នលក់ជម្រះត្រូវតែគ្មានជាប់បន្ទុក ឬសិទ្ធិរបស់តតិយជនណាមួយឡើយ ។

មាត្រា ៥៧.-

១-ប្រាក់ដែលទទួលបានពីការជម្រះបញ្ជីទ្រព្យសម្បត្តិកូនបំណុល ត្រូវប្រើប្រាស់សម្រាប់ទូទាត់បណ្តឹងទាមទារតាមលំដាប់ដូចខាងក្រោមនេះ :

ក-ប្រាក់បៀវត្សបុគ្គលិក និងនិយោជិត ប្រាក់បំណាច់របស់អភិបាលបណ្តោះអាសន្ន សេវារដ្ឋបាល និងប្រាក់ចំណាយប្រជាប់ក្តី

ខ-បណ្តឹងទាមទារដែលមានកិច្ចធានា រហូតដល់ត្រឹមកម្រិតខ្ពស់នៃតម្លៃនៃផ្នែកដែលមានកិច្ចធានាក្នុងបណ្តឹងទាមទារដូចបានកំណត់ក្នុងមាត្រា ២៦ នៃច្បាប់នេះ ឬថ្លៃលក់សុទ្ធដែលបានមកពីការលក់ទ្រព្យធានានេះ

គ-ពន្ធដារបស់រដ្ឋ ដែលមិនបានតម្កល់លិខិតជូនដំណឹង

ឃ-បណ្តឹងទាមទារគ្មានកិច្ចធានាទាំងអស់ដែលបានទទួលស្គាល់ ។

២-ចំពោះបណ្តឹងទាមទារដែលកំណត់នៅក្នុងចំណុចទី១-ខ ចំនួនទឹកប្រាក់នៃបណ្តឹងទាមទារទាំងនេះ ដែលលើសពីកម្រិតដែលចែងក្នុងចំណុចទាំងនេះនឹងមានសិទ្ធិទទួលការទូទាត់ដូចគ្នានឹងបណ្តឹងទាមទារទូទៅ ដែលគ្មានកិច្ចធានាតាមចំណុចទី ១-ឃ ។

៣-ប្រាក់ថ្លៃលក់ដែលនៅសល់ពីការបែងចែក បន្ទាប់ពីការទូទាត់បណ្តឹងទាមទារទាំងអស់ដែលមានចែងក្នុងចំណុចទី ១ ត្រូវប្រគល់ទៅឱ្យកូនបំណុល ។

មាត្រា ៥៨.-

១-លើកលែងតែទ្រព្យសកម្មរបស់កូនបំណុលដែលមិនអាចលក់បាន អភិបាលបណ្តោះអាសន្នត្រូវអនុវត្តការជម្រះបញ្ជីចំពោះទ្រព្យរបស់កូនបំណុល ហើយបែងចែកប្រាក់បានមកពីការលក់មិនឱ្យលើសពី ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការចាប់ផ្តើមការជម្រះបញ្ជី ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

តាមពាក្យសុំជាលាយលក្ខណ៍អក្សររបស់អភិបាលបណ្តោះអាសន្ន តុលាការអាចពន្យារពេល ៦ (ប្រាំមួយ) ខែ បន្ថែមសម្រាប់ការជម្រះបញ្ជីទ្រព្យកូនបំណុល និងការបែងចែកប្រាក់ដែលបានពីការលក់ ។

២-មូលនិធិអាចត្រូវបានបែងចែកឱ្យទៅម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធនភ្លាមៗ នៅពេលមានប្រាក់គ្រប់គ្រាន់ក្នុងទ្រព្យរបស់កូនបំណុល ។

ជំពូកទី ៨
ការបញ្ចប់សំណុំរឿងក្ស័យធន បន្ទាប់ពីការជម្រះបញ្ជី

មាត្រា ៥៩.-

អភិបាលបណ្តោះអាសន្ន ត្រូវដាក់ជូនតុលាការនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីសកម្មភាពរបស់ខ្លួន ។ របាយការណ៍នេះត្រូវចែងពីគណនីចុងក្រោយនៃការបែងចែក និងបណ្តឹងទាមទារដែលមិនទាន់បានទូទាត់ ។ អភិបាលបណ្តោះអាសន្នត្រូវដាក់ជូននូវរបាយការណ៍នេះ មិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីការជម្រះឱ្យអស់នូវផ្នែកដែលអាចលក់បានទាំងអស់ក្នុងទ្រព្យរបស់កូនបំណុល ។

មាត្រា ៦០.-

តុលាការត្រូវកោះអញ្ជើញកិច្ចប្រជុំចុងក្រោយម្ចាស់បំណុលក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីខ្លួនបានទទួលរបាយការណ៍ពីអភិបាលបណ្តោះអាសន្ន អនុលោមតាមមាត្រា ៥៩ នៃច្បាប់នេះ ។ កិច្ចប្រជុំរបស់ម្ចាស់បំណុលនេះ ត្រូវអនុម័តគណនីចុងក្រោយនៃការបែងចែក និងបណ្តឹងទាមទារដែលមិនទាន់បានទូទាត់ និងត្រូវសម្រេចលើការប្រើប្រាស់ផ្នែកនៃទ្រព្យរបស់កូនបំណុលដែលមិនអាចលក់បាន ។

មាត្រា ៦១.-

១-តុលាការត្រូវចេញសេចក្តីសម្រេចបញ្ចប់សំណុំរឿងក្ស័យធនភ្លាមៗ បន្ទាប់ពីកិច្ចប្រជុំចុងក្រោយរបស់ម្ចាស់បំណុល ។

ROYAUME DU CAMBODGE

២-សេចក្ដីសម្រេចបញ្ចប់សំណុំរឿងក្ស័យធនរបស់តុលាការត្រូវផ្សព្វផ្សាយក្នុងរាជកិច្ច និងសារព័ត៌មានប្រចាំថ្ងៃនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦២.-

នៅពេលបញ្ចប់សំណុំរឿងក្ស័យធនបន្ទាប់ពីការជម្រះបញ្ជីការិយាល័យរបស់អភិបាលបណ្ដោះអាសន្ន និងការិយាល័យរបស់គណៈកម្មការម្ចាស់បំណុល ត្រូវបិទលែងមានតទៅទៀត ។ កូនបំណុលមានសិទ្ធិក្នុងការលក់ជម្រះនូវទ្រព្យសម្បត្តិដែលនៅសល់ ។

មាត្រា ៦៣.-

ក្នុងករណីដែលកូនបំណុលជាក្រុមហ៊ុនមូលធន ត្រូវចាត់ទុកថាក្រុមហ៊ុននេះបានរំលាយនៅពេលតុលាការចេញសេចក្ដីសម្រេចបញ្ចប់សំណុំរឿងក្ស័យធននៅពេលជម្រះបញ្ជី លើកលែងតែការបញ្ចប់សំណុំរឿងក្ស័យធននេះកើតឡើងពីការទូទាត់បណ្ដឹងទាមទារទាំងអស់ស្របតាមមាត្រា ៥៧ នៃច្បាប់នេះ ។

មាត្រា ៦៤.-

១-ក្នុងករណីដែលសំណុំរឿងក្ស័យធនបានបើកទល់នឹងកូនបំណុលដែលជារូបវន្តបុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានការបញ្ចប់សំណុំរឿងក្ស័យធននៅពេលជម្រះបញ្ជី កូនបំណុលអាចដាក់បណ្ដឹងសុំទៅតុលាការដើម្បីសុំឱ្យរួចខ្លួនពីបណ្ដឹងទាមទារទាំងអស់ដែលមានការទទួលស្គាល់ ហើយមិនទាន់បានទូទាត់ក្នុងសំណុំរឿងក្ស័យធន លើកលែងតែកូនបំណុលបានទទួលទ្រព្យសកម្ម ឬ ប្រាក់ដែលបែងចែកមិនអស់ តាមមាត្រា ៥៧ ចំណុចទី ៣ នៃច្បាប់នេះ ។ ទោះបីមានសេចក្ដីសម្រេចដូចចំណុចទី ១ ក៏ដោយ ក៏បណ្ដឹងទាមទារដែលគ្មានការទទួលស្គាល់ត្រូវបានចាត់ទុកជាមោឃៈនៅពេលបញ្ចប់សំណុំរឿងក្ស័យធន លើកលែងតែបណ្ដឹងទាមទារដែលមានចែងតាមមាត្រា ៣៦ ចំណុចទី ៣ នៃច្បាប់នេះ ។

២-ម្ចាស់បំណុលទាំងអស់ និងតំណាងអយ្យការមានសិទ្ធិចូលរួមក្នុងកិច្ចសវនាការស្ដីពីបណ្ដឹងសុំតាមចំណុចទី ១ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

៣-តុលាការត្រូវបដិសេធការរំដោះកូនបំណុលឱ្យរួចផុតពីបណ្តឹងទាមទារដែលមិនទាន់ទូទាត់ ប្រសិនបើ :

ក-កូនបំណុលមានពិរុទ្ធភាពពីបទព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងបទល្មើសឆបោក ឬ បទល្មើសរំលោភលើសេចក្តីទុកចិត្តទាក់ទិននឹងភាពក្ស័យធននៃអាជីវកម្មរបស់កូនបំណុល

ខ-ក្នុងរយៈពេល៣(បី)ឆ្នាំ ចុងក្រោយមុនពេលបើកសំណុំរឿងក្ស័យធនកូនបំណុលបានធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរមិនត្រឹមត្រូវ ឬ មិនគ្រប់គ្រាន់អំពីស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួនដោយចេតនា ឬ ដោយធ្វេសប្រហែស ដើម្បីទទួលបានឥណទាន ឬ ទទួលបានការទូទាត់ពីមូលនិធិសាធារណៈ ឬ ដើម្បីជៀសវាងការទូទាត់ប្រាក់ឱ្យស្ថាប័នសាធារណៈ

គ-ក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ចុងក្រោយមុនពេលបើកសំណុំរឿងក្ស័យធន កូនបំណុលត្រូវបានផ្តល់ការរំដោះឱ្យរួចពីបណ្តឹងទាមទារដែលមិនទាន់ទូទាត់ក្នុងសំណុំរឿងក្ស័យធនមួយរួចហើយ

ឃ-ក្នុងរយៈពេល ១២ (ដប់ពីរ) ខែចុងក្រោយមុនពេលបើកសំណុំរឿងក្ស័យធន កូនបំណុលមិនបានទូទាត់គ្រប់ចំនួនទៅឱ្យម្ចាស់បំណុលដោយសារការបង្កើតបំណុលមិនសមស្របធ្វើឱ្យខ្វះខាតទ្រព្យសកម្ម ឬ ការពន្យារពេលក្នុងការបើកសំណុំរឿងក្ស័យធន ឬ ម្ចាស់បំណុលគ្មានបំណងកែលំអលក្ខខណ្ឌសេដ្ឋកិច្ចរបស់កូនបំណុលទោះបីជាដោយចេតនា ឬ អចេតនាក៏ដោយ

ង-កូនបំណុលមិនបានរំលត់កាតព្វកិច្ចរបស់ខ្លួនតាមមាត្រា ៩ នៃច្បាប់នេះ ទោះបីជាដោយចេតនា ឬ អចេតនាក្តី

ច-ក្នុងកំឡុងពេលបើកសំណុំរឿងក្ស័យធន កូនបំណុលបានបំពានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន និងកាតព្វកិច្ចក្នុងការសហការនៅក្នុងសំណុំរឿងក្ស័យធន ទោះបីជាដោយចេតនា ឬ អចេតនាក្តី

ឆ-កូនបំណុលបានផ្តល់ព័ត៌មានមិនពិត ឬ ព័ត៌មានមិនគ្រប់គ្រាន់ដោយអនុលោមតាមមាត្រា ២៩ នៃច្បាប់នេះ ទោះបីជាដោយចេតនា ឬ អចេតនាក្តី ។

ROYAUME du CAMBODGE

៤-សេចក្តីសម្រេចធ្វើឡើងតាមមាត្រានេះ មិនត្រូវមានអានុភាពលើលទ្ធភាពរបស់ម្ចាស់បំណុលក្នុងការដាក់ពាក្យសុំបន្តសំណុំរឿងក្ស័យធនប្រឆាំងនឹងកូនបំណុលតាមជំពូកទី ៩ ឡើយ ។

ជំពូកទី ៩
ការបន្តសំណុំរឿងក្ស័យធន
ដែលត្រូវបានបញ្ចប់ បន្ទាប់ពីការជម្រះបញ្ជី

មាត្រា ៦៥.-

រាល់ម្ចាស់បំណុលដែលមានបណ្តឹងទាមទារក្នុងបញ្ជីបណ្តឹងទាមទារ ហើយមិនទាន់បានទូទាត់គ្រប់ចំនួនអាចដាក់បណ្តឹងសុំជាលាយលក្ខណ៍អក្សរទៅតុលាការ ដើម្បីសុំបន្តសំណុំរឿងក្ស័យធនក្នុងរយៈពេល ១(មួយ) ឆ្នាំ គិតចាប់ពីការបញ្ចប់សំណុំរឿងក្ស័យធន ។

មាត្រា ៦៦.-

១-សំណុំរឿងក្ស័យធនត្រូវចាប់ផ្តើមបន្តជាថ្មីតាមសេចក្តីសម្រេចរបស់តុលាការកាលណា :

ក-ចំនួនទឹកប្រាក់ដែលកំណត់សម្រាប់បណ្តឹងទាមទារសំណាងនេះត្រូវបានលុបចោលឱ្យរួចផុតពីបណ្តឹងទាមទារនៅក្នុងពេលបិទសំណុំរឿងក្ស័យធន ។

ខ-មានទ្រព្យសកម្មដែលអាចយកមកទូទាត់បណ្តឹងទាមទាររបស់ម្ចាស់បំណុលបាន ហើយក្នុងករណីដែលតុលាការរកឃើញថាអត្ថិភាពនៃទ្រព្យសកម្មនេះមិនត្រូវបានលើកមកពិចារណាក្នុងសំណុំរឿងក្ស័យធន ។

២-សំណុំរឿងក្ស័យធនមិនត្រូវបន្តទេ កាលណាទឹកប្រាក់ ឬ តម្លៃនៃទ្រព្យសកម្មដែលចែងក្នុងចំណុចទី ១ មិនគ្រប់គ្រាន់សម្រាប់ទូទាត់ថ្លៃចំណាយសម្រាប់បន្តសំណុំរឿងនេះ ។

មាត្រា ៦៧.-

១-សេចក្តីសម្រេចបន្តសំណុំរឿងក្ស័យធន បង្កើតសិទ្ធិរបស់អភិបាលបណ្តោះអាសន្ន ប្រតិបត្តិការ ... ណៈកម្មការម្ចាស់បំណុលឡើងវិញ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

២-សំណុំរឿងក្ស័យធនដែលបន្ត ត្រូវអនុវត្តតាមរបៀបដូចគ្នានឹងការជម្រះបញ្ជី និងបទប្បញ្ញត្តិដែលទាក់ទិននឹងច្បាប់នេះត្រូវអនុវត្តដូចគ្នានឹងសំណុំរឿងក្ស័យធនធម្មតាដែរ ។

ជំពូកទី ១០

អភិបាលបណ្តោះអាសន្ន និងម្ចាស់បំណុល

ផ្នែកទី ១

អភិបាលបណ្តោះអាសន្ន

មាត្រា ៦៨.-

១-មានតែរូបវន្តបុគ្គលទេ ដែលអាចត្រូវបានតែងតាំងជាអភិបាលបណ្តោះអាសន្នបានដោយតុលាការ ។

២-អភិបាលបណ្តោះអាសន្នមិនត្រូវ :

ក-ជាបុគ្គលដែលតុលាការបានផ្តន្ទាទោសពីបទល្មើស ដែលទាក់ទិននឹងអំពើឆបោក ឬ វិរលោភលើសេចក្តីទុកចិត្ត

ខ-ជាកូនបំណុល ម្ចាស់បំណុល ឬ បុគ្គលដែលមានការពាក់ព័ន្ធ ឬ

គ-ជាសហព័ទ្ធរបស់ម្ចាស់បំណុល ឬ កូនបំណុល ឬ ជាសាច់ញាតិរបស់កូនបំណុល ឬ ម្ចាស់បំណុលណាម្នាក់ ។

៣-ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចតម្រូវឱ្យ :

ក-អភិបាលបណ្តោះអាសន្នមានលក្ខណសម្បត្តិបន្ថែមដែលមានចែងក្នុងចំណុចទី ២

ខ-អភិបាលបណ្តោះអាសន្នទាំងអស់ត្រូវទទួលអាជ្ញាប័ណ្ណពីក្រសួងយុត្តិធម៌ដោយអនុលោមតាមលក្ខខណ្ឌដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។

មាត្រា ៦៩.-

១-តុលាការត្រូវប្រកាសដកអភិបាលបណ្តោះអាសន្ន ចេញពីសំណុំរឿងក្ស័យធនក្នុងករណីណាមួយដូចខាងក្រោម :

ក-តាមសំណើលាលែងពីតំណែងរបស់អភិបាលបណ្តោះអាសន្ន

ខ-អភិបាលបណ្តោះអាសន្ន បាត់បង់លក្ខណសម្បត្តិដូចបានចែងក្នុងមាត្រា

៦៨ នៃច្បាប់នេះ

គ-មានសំណើពីម្ចាស់បំណុលដែលមានបណ្តឹងទាមទារមានតម្លៃទឹកប្រាក់យ៉ាងតិច ៥១៖ (ហាសិបមួយភាគរយ) នៃបណ្តឹងទាមទារសរុប

ឃ-មានភស្តុតាងបញ្ជាក់ថា អភិបាលបណ្តោះអាសន្នមិនបានបំពេញភារកិច្ច ឬ បានបំពេញភារកិច្ចតាមវិធីដែលនាំឱ្យខូចផលប្រយោជន៍របស់ម្ចាស់បំណុលជាទូទៅ ។

២-តុលាការអាចប្រកាសដកអភិបាលបណ្តោះអាសន្នចេញនៅពេលណាក៏បាន តាមសេចក្តីសម្រេចរបស់ខ្លួនដោយអនុលោមតាមចំណុច ១ ខាងលើ ។

៣-តុលាការត្រូវតែងតាំងអភិបាលបណ្តោះអាសន្នថ្មី ដើម្បីជំនួសអភិបាលបណ្តោះអាសន្នដែលត្រូវបានដកចេញ ។

មាត្រា ៧០.-

១-អភិបាលបណ្តោះអាសន្នត្រូវបានចាត់ទុកថាជាមន្ត្រីរបស់តុលាការ ហើយត្រូវមានកាតព្វកិច្ចស្មោះត្រង់ចំពោះតុលាការតែប៉ុណ្ណោះ ។

២-អភិបាលបណ្តោះអាសន្នត្រូវតែផ្តល់ព័ត៌មានដែលទាក់ទិននឹងការចាត់ចែងទ្រព្យរបស់កូនបំណុល ឬ ស្ថានភាពនៃសំណុំរឿងក្ស័យធនឱ្យបានឆាប់រហ័ស តាមសំណើជាលាយលក្ខណ៍អក្សររបស់ម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ ។

មាត្រា ៧១.-

១-អភិបាលបណ្តោះអាសន្ន ត្រូវតែបំពេញមុខងារដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ប្រកបដោយវិចារណញ្ញាណតាមកាលៈទេសៈដូចគ្នានឹងអាជីវករដែរ ។

២-អភិបាលបណ្តោះអាសន្ន ត្រូវទទួលខុសត្រូវចំពោះរាល់ភាគីនៃសំណុំរឿងក្ស័យធនលើការខូចខាត ដែលបណ្តាលមកពីការមិនបានអនុវត្តមុខងារ ដោយប្រុងប្រយ័ត្ននិងខ្វះការយកចិត្តទុកដាក់ ។

មាត្រា ៧២.-

១-អភិបាលបណ្តោះអាសន្ន ត្រូវទទួលបានប្រាក់បំណាច់ និងសំណងរាល់ថ្លៃចំណាយសមស្របដែលបានធ្វើឡើងក្នុងពេលបំពេញភារកិច្ច ។ ការគណនាអត្រាប្រាក់បំណាច់នេះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

41/476

ត្រូវពិចារណាលើកត្តាមួយចំនួនដូចជាពេលវេលាដែលអភិបាលបណ្តោះអាសន្នបានចំណាយក្នុងពេលបំពេញការងារ តម្លៃសរុបនៃទ្រព្យរបស់កូនបំណុល និងវិសាលភាព និងភាពស្មុគស្មាញនៃសំណុំរឿងក្ស័យធន ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចេញប្រកាសសម្រាប់គ្រប់គ្រងអត្រាប្រាក់បំណាច់សម្រាប់អភិបាលបណ្តោះអាសន្នបានតាមសំណើរបស់ម្ចាស់បំណុល ។

ផ្នែកទី ២

ម្ចាស់បំណុល

មាត្រា ៧៣.—

១-កិច្ចប្រជុំម្ចាស់បំណុលអាចត្រូវបានកោះអញ្ជើញដោយអភិបាលបណ្តោះអាសន្ននៅពេលណាក៏បាន បើអភិបាលបណ្តោះអាសន្នយល់ថាកិច្ចប្រជុំនេះមានប្រយោជន៍ដល់ការចាត់ចែងសំណុំរឿងក្ស័យធន ។

២-រាល់ម្ចាស់បំណុល អាចធ្វើសំណើជាលាយលក្ខណ៍អក្សរទៅអភិបាលបណ្តោះអាសន្នដើម្បីកោះប្រជុំម្ចាស់បំណុល ។ សំណើជាលាយលក្ខណ៍អក្សរត្រូវបញ្ជាក់ពីបញ្ហាដែលស្នើសម្រាប់កិច្ចប្រជុំ ។

៣-កិច្ចប្រជុំម្ចាស់បំណុល ត្រូវកោះអញ្ជើញដោយអភិបាលបណ្តោះអាសន្នក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរពីម្ចាស់បំណុលដែលស្នើសុំកិច្ចប្រជុំនេះ ។

៤-រាល់កិច្ចប្រជុំម្ចាស់បំណុល ត្រូវដឹកនាំដោយអភិបាលបណ្តោះអាសន្ន ឬចៅក្រម ។

៥-មាត្រានេះមិនត្រូវអនុវត្តចំពោះកិច្ចប្រជុំដំបូងរបស់ម្ចាស់បំណុលឡើយ ។

មាត្រា ៧៤.—

១-អភិបាលបណ្តោះអាសន្ន ត្រូវជូនដំណឹងដល់ម្ចាស់បំណុលទាំងអស់ អំពីការកោះប្រជុំម្ចាស់បំណុល ដោយផ្ញើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជូនម្ចាស់បំណុលទាំង[illegible]ផ្សាយក្នុងសារព័ត៌មានប្រចាំថ្ងៃសំខាន់ៗ យ៉ាងហោចណាស់ចំនួន ២(ពីរ) នៅក្នុង[illegible]ជាណាចក្រកម្ពុជា ដោយប្រកាសអំពីព័ត៌មានដូចខាងក្រោមនេះ :

ក-ពេលវេលានៃកិច្ចប្រជុំ

ខ-ទីកន្លែងដែលត្រូវរៀបចំកិច្ចប្រជុំ

គ-បញ្ហាផ្សេងៗដែលស្នើសម្រាប់ការពិភាក្សាក្នុងកិច្ចប្រជុំ ។

២-ត្រូវជូនដំណឹងដល់ម្ចាស់បំណុលទាំងអស់អំពីការកោះប្រជុំម្ចាស់បំណុល យ៉ាងហោចណាស់ ៧ (ប្រាំពីរ) ថ្ងៃ មុនបើកកិច្ចប្រជុំ ។

៣-ការមិនគោរពតាមលក្ខខណ្ឌតម្រូវនៃមាត្រានេះ នឹងបណ្តាលឱ្យសេចក្តីសម្រេចដែលធ្វើឡើងក្នុងកិច្ចប្រជុំរបស់ម្ចាស់បំណុលនោះក្លាយជាមោឃៈ ។

៤-មាត្រានេះមិនត្រូវអនុវត្តចំពោះកិច្ចប្រជុំដំបូងរបស់ម្ចាស់បំណុលឡើយ ។

មាត្រា ៧៥.-

១-សេចក្តីសម្រេចទាំងអស់ក្នុងគ្រប់កិច្ចប្រជុំម្ចាស់បំណុល ត្រូវធ្វើឡើងដោយសំឡេងឆ្នោតគាំទ្ររបស់ម្ចាស់បំណុល ដែលកាន់កាប់ភាគច្រើននៃតម្លៃសរុបក្នុងបណ្តឹងទាមទាររបស់ម្ចាស់បំណុលដែលមានវត្តមានក្នុងកិច្ចប្រជុំ ហើយដែលមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំនេះ ។

២-មានតែម្ចាស់បំណុលដែលបណ្តឹងទាមទារមិនត្រូវបានជំទាស់ដោយអភិបាលបណ្តោះអាសន្ន ឬ ដោយម្ចាស់បំណុលផ្សេងទៀតទើបមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំម្ចាស់បំណុល ។ ម្ចាស់បំណុលដែលបណ្តឹងទាមទារត្រូវបានជំទាស់អាចបោះឆ្នោតបានតែក្នុងករណីមានការអនុញ្ញាតពីអភិបាលបណ្តោះអាសន្ន ឬ ពីម្ចាស់បំណុលផ្សេងទៀតដែលមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំ ។ ក្នុងករណីដែលភាគីទាំងនោះ មិនអាចមានកិច្ចព្រមព្រៀងលើសិទ្ធិបោះឆ្នោតរបស់ម្ចាស់បំណុលនៅក្នុងកិច្ចប្រជុំម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការ ដើម្បីសុំសេចក្តីសម្រេចលើបញ្ហានេះ ហើយកិច្ចប្រជុំរបស់ម្ចាស់បំណុលនឹងត្រូវផ្អាកត្រឹមកាលបរិច្ឆេទមួយដែលមានរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃតុលាការចេញសេចក្តីសម្រេចលើបញ្ហានេះ ។

៣-ទោះបីមានចែងក្នុងចំណុចទី ២ ខាងលើនេះក៏ដោយ ក៏ម្ចាស់បំណុលដែលមានបណ្តឹងទាមទារដែលគ្មានការទទួលស្គាល់គ្មានសិទ្ធិបោះឆ្នោតដែរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៤-ម្ចាស់បំណុលអាចចូលរួមក្នុងកិច្ចប្រជុំទាំងអស់ ហើយអាចបោះឆ្នោតជាបុគ្គល ឬ តាមរយៈអាណត្តិគាហក ។

មាត្រា ៧៦.-

កិច្ចប្រជុំម្ចាស់បំណុល អាចពិចារណា និងសម្រេចលើបញ្ហាដែលទាក់ទិននឹងសំណុំរឿងក្ស័យធនមានជាអាទិ៍ :

១-ការទទួល និងពិចារណាលើរបាយការណ៍ស្តីពីស្ថានភាពនៃសំណុំរឿងក្ស័យធនពីអភិបាលបណ្តោះអាសន្ន ។

២-ការរៀបចំផែនការសម្របសម្រួល រាប់បញ្ចូលទាំងផែនការដែលធ្វើឡើងដោយអភិបាលបណ្តោះអាសន្នផង ។

៣-ការអនុម័តលើផែនការសម្របសម្រួល ។

៤-ការសម្រេចប្តឹងទៅតុលាការ ដើម្បីបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់កូនបំណុល និងចាប់ផ្តើមការជម្រះបញ្ជីលើទ្រព្យរបស់កូនបំណុល ។

៥-ការបញ្ឈប់ និងការផ្លាស់ប្តូរអភិបាលបណ្តោះអាសន្ន ។

៦-ការធ្វើសំណើទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទាក់ទិននឹងប្រាក់បំណាច់របស់អភិបាលបណ្តោះអាសន្ន ។

៧-ការតែងតាំងគណៈកម្មការម្ចាស់បំណុល ។

៨-ការទទួលរាល់អនុសាសន៍ពីគណៈកម្មការម្ចាស់បំណុល ។

មាត្រា ៧៧.-

រាល់សេចក្តីសម្រេចដែលបានធ្វើឡើងក្នុងកិច្ចប្រជុំម្ចាស់បំណុល ត្រូវភ្ជាប់កាតព្វកិច្ចរបស់ម្ចាស់បំណុលទាំងអស់ រាប់បញ្ចូលទាំងម្ចាស់បំណុលដែលអវត្តមានក្នុងកិច្ចប្រជុំផងដែរ ។

មាត្រា ៧៨.-

១-ក្នុង[illegible]ប់កិច្ចប្រជុំម្ចាស់បំណុល ម្ចាស់បំណុលអាចជ្រើសតាំងគណៈកម្មការម្ចាស់បំណុលមានសមាជិកយ៉ាងហោចណាស់ ៣(បី) រូប ហើយមិនលើសពី ៤ (ប្រាំបួន)

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

រូប ដែលជ្រើសរើសក្នុងចំណោមតំណាងម្ចាស់បំណុលមានកិច្ចធានា និងម្ចាស់បំណុលគ្មានកិច្ចធានា ។

២-ថ្លៃចំណាយទាំងអស់ដែលម្ចាស់បំណុលបានចំណាយក្នុងការបង្កើត និងដំណើរការនៃគណៈកម្មការម្ចាស់បំណុល ត្រូវបានចាត់ទុកជាបណ្តឹងទាមទារដែលធ្វើឡើងដោយអភិបាលបណ្តោះអាសន្នក្នុងដំណើរការសំណុំរឿងក្ស័យធន ហើយត្រូវទូទាត់ករណីនេះដោយអនុលោមតាមមាត្រា ៥៧ នៃច្បាប់នេះ ។

មាត្រា ៧៩.-

១-គណៈកម្មការម្ចាស់បំណុល ត្រូវធ្វើការងារតំណាងឱ្យផលប្រយោជន៍របស់ម្ចាស់បំណុលទាំងមូល ។

២-គណៈកម្មការម្ចាស់បំណុលត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនតាមសេចក្តីសម្រេចរបស់ម្ចាស់បំណុលដែលមានទឹកប្រាក់ភាគច្រើនក្នុងបណ្តឹងទាមទារសរុបទល់នឹងកូនបំណុល ។ បើមានការស្នើសុំពីអភិបាលបណ្តោះអាសន្ន គណៈកម្មការម្ចាស់បំណុលអាចជួយអភិបាលបណ្តោះអាសន្នក្នុងការចាត់ចែងទ្រព្យរបស់កូនបំណុលបាន ។

៣-តាមការស្នើសុំពីគណៈកម្មការម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវអនុញ្ញាតឱ្យគណៈកម្មការម្ចាស់បំណុលពិនិត្យបញ្ជីគណនេយ្យ និងគណនីទាំងឡាយរបស់កូនបំណុល ។

ជំពូកទី ១១

ការបញ្ជូនឯកសារ

មាត្រា ៨០.-

១-ការបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធនទៅឱ្យក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈការប្រគល់ឯកសារនៅទីស្នាក់ការអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គលដែលបានចុះបញ្ជី ។

២-ការបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធនទៅឱ្យរូបវន្តបុគ្គលដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងតាមរយៈការប្រគល់ឯកសារនៅលំនៅឋានចុងក្រោយរបស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣-ការបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធនទៅឱ្យនីតិបុគ្គលដែលបង្កើតឡើងតាមច្បាប់បរទេស ឬរូបវន្តបុគ្គលដែលរស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងតាមរយៈការចុះផ្សាយជូនដំណឹងយ៉ាងហោចណាស់ក្នុងសារព័ត៌មានធំមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងសារព័ត៌មានធំមួយទៀតនៅក្នុងប្រទេសដែលជាកន្លែងបង្កើតនីតិបុគ្គល ឬ ជាកន្លែងរូបវន្តបុគ្គលនោះរស់នៅ ។

៤-តាមបណ្តឹងសុំរបស់ភាគីពាក់ព័ន្ធ តុលាការអាចបញ្ជាឱ្យបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធន តាមវិធីផ្សេងពីវិធីដែលបានចែងក្នុងចំណុចទី ១ រហូតដល់ចំណុចទី ៣ នៃមាត្រានេះ ប្រសិនបើតុលាការយល់ថាវិធីផ្សេងនោះមានភាពសមស្រប និងជាក់លាក់ជាង ។

ជំពូកទី ១២

ទោសប្បញ្ញត្តិ

មាត្រា ៨១.-

រាល់បទល្មើសក្នុងសំណុំរឿងក្ស័យធនត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ជំពូកទី ១៣

អន្តរប្បញ្ញត្តិ

មាត្រា ៨២.-

១-ក្នុងរយៈពេលដែលព្រះរាជាណាចក្រកម្ពុជានៅមិនទាន់មានតុលាការពាណិជ្ជកម្ម តុលាការសាមញ្ញមានសមត្ថកិច្ច លើរឿងក្តីក្ស័យធនទាំងអស់ដែលមានចែងក្នុងច្បាប់នេះ ។

ROYAUME DU CAMBODGE

២-នៅពេលដែលតុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា តុលាការសាមញ្ញត្រូវផ្ទេរសមត្ថកិច្ចលើរឿងក្តីក្ស័យធនទាំងអស់ជូនទៅតុលាការពាណិជ្ជកម្ម ។

ជំពូកទី ១៤

អវសានប្បញ្ញត្តិ

មាត្រា ៨៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨៤.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបទាប់
ប្រមុខរដ្ឋស្តីទី
នស.០៧១២.២៣ **ហត្ថលេខា និងព្រះរាជលញ្ឆករ**
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋមន្ត្រីស្តីទី
ហត្ថលេខា
គឹម ស៊ីថន

លេខៈ ៥៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៧/៦៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **នាយឧត្តមសេនីយ៍ផ្កាយមាស ៤** ជាកិច្ចបច្ឆាមរណៈជូនចំពោះសព ឯកឧត្តម ឧត្តមសេនីយ៍ឯក **យើង ម៉ារ៉ានី** អគ្គលេខ ០០៥ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខៈ ៦០៦ ច.ល

៣រល.០៧១២.៦៦៤

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៨ ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៧/៦៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកជំទាវ ឈិន អ៊ីម

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧១២.៦៧២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៧

លេខ:៥៩៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៧/៦៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ឃឹម ប៊ុនសុខ** ជាទីប្រឹក្សាឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៥៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឌុង ជិនកេន

៣រ៧.០៧១២.៦៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៧

នស/រកត/១២០៧/៦៣៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម ហ្មត ហារ៉ត់ ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧១២.៦៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៧

លេខ: ៧០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៧/៦៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ខួន នៅ ជាទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទទួលបន្ទុកការងារឧស្សាហកម្ម-សិប្បកម្ម មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១២.៦៧៧

លេខ: ៦០៤ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៧/៦៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

ក_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

-ឧត្តមសេនីយ៍ត្រី គង់ សុភា អត្តលេខ ០១៤៣៩០

ខ_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក អ៊ុច សំផន អត្តលេខ ០០២១៩៤

២-វរសេនីយ៍ឯក ឈុច សារិន អត្តលេខ ០០២១៩៥

៣-វរសេនីយ៍ឯក រស់ ចិន្តា អត្តលេខ ០០៣៤៣៩

៤-វរសេនីយ៍ឯក មោក សៀង អត្តលេខ ០០៩៥២០

៥-វរសេនីយ៍ឯក គង់ សាលី អត្តលេខ ០០៩៥៣០

៦-វរសេនីយ៍ឯក អ៊ុន ពិសិដ្ឋ អត្តលេខ ០១៤៩២៩

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៧-វរសេនីយ៍ឯក គឹម វណ្ណៈ អត្តលេខ ០៥៦២០៥

៨-វរសេនីយ៍ឯក ឡុង ឈាងអេង អត្តលេខ ២៣១៨៩២

៩-វរសេនីយ៍ឯក ងិន ឆានតាន អត្តលេខ ២៣១៥៤១

១០-វរសេនីយ៍ឯក ឃី វណ្ណវិសាល អត្តលេខ ០១០៦២៣

មាត្រា២ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០៧១២.៦៧៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៧

លេខ: ៦០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/១២០៧/៦៤៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្ដិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

ក-តម្លើងឋានន្តរស័ក្ដិថ្នាក់ឧត្ដមសេនីយ៍ទោ

-ឧត្ដមសេនីយ៍ត្រី អ៊ុក សារី អត្តលេខ ០០០៨២៤

ខ-តម្លើងឋានន្តរស័ក្ដិថ្នាក់ឧត្ដមសេនីយ៍ត្រី

១-វរសេនីយ៍ឯក	ជា	សាវ៉ាត់	អត្តលេខ ០០២២១៥
២-វរសេនីយ៍ឯក	ម៉ិត	សុភាព	អត្តលេខ ០០២២៤១
៣-វរសេនីយ៍ឯក	គឹម	ជេត	អត្តលេខ ០០២២២៤
៤-វរសេនីយ៍ឯក	នេត្រ	ណារា	អត្តលេខ ០០០៤៩៨
៥-វរសេនីយ៍ឯក	ឆេង	សុខឿន	អត្តលេខ ០០២២៤៧
៦-វរសេនីយ៍ឯក	ប្រាក់	ម៉ុនថន	អត្តលេខ ០០២៥៥៣
៧-វរសេនីយ៍ឯក	ពេជ្រ	សំអុន	អត្តលេខ ០០២២៣៥

មាត្រា២ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

៣រល.០៧១២.៦៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៧

លេខៈ ៧០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០០៧
អគ្គលេខាធិការ...រដ្ឋាភិបាល
ជិនកេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២០១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២.១០០ លានរៀល (ពីរពាន់មួយរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១៦ (ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល) ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ទូទាត់សងប្រាក់ដើម រហូតដល់ដំណាច់ឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគទីតាំងសាលាស្រុកកំពង់ត្របែក ទីតាំងដីមួយផ្នែករបស់ស្នងការដ្ឋាននគរបាលខេត្តកំពត និង ទីតាំងការិយាល័យចរាចរជើងគោករបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-របាយការណ៍ស្តីពីការអង្កេតជាសាធារណៈលើទីតាំងសាលាស្រុកកំពង់ត្របែក លេខ៤៦៨ សរសណ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ

-របាយការណ៍ស្តីពីការអង្កេតជាសាធារណៈលើទីតាំងការិយាល័យចរាចរជើងគោក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ លេខ៤៦៩ សរសណ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ

-របាយការណ៍ស្តីពីការអង្កេតជាសាធារណៈ លើទីតាំងដីមួយផ្នែកនៃស្នងការដ្ឋាននគរបាល ខេត្តកំពត លេខ ១៤៩៤ លស ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងសាលាស្រុកកំពង់ត្របែក ដែលមានទំហំដី៥.២៨៩ម៉ែត្រក្រឡា ទីតាំងការិយាល័យចរាចរជើងគោកនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺទំហំដី១.៣២៤.៣០ម៉ែត្រក្រឡា និង ទីតាំងដីមួយផ្នែករបស់ស្នងការដ្ឋាននគរបាលខេត្តកំពតមានទំហំដី១៤.៤៧១ម៉ែត្រក្រឡា ដើម្បីធ្វើការផ្លាស់ប្តូរជាមួយផ្ទះរបស់ភាគីឯកជន ។

មាត្រា ២.-

ការកត់ត្រាផ្ទេរទ្រព្យសម្បត្តិថ្មី ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ សាលាខេត្តព្រៃវែង សាលាខេត្តកំពង់ស្ពឺ សាលាខេត្តកំពត និង មន្ទីរជំនាញពាក់ព័ន្ធ ស្របតាមគោលការណ៍រាជរដ្ឋាភិបាល ។

មាត្រា ៣.-

ការបំពេញបែបបទធ្វើកម្មសិទ្ធិរបស់ភាគីឯកជននៅលើទីតាំងរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អគ្គលេខាធិការ រាជរដ្ឋាភិបាល
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤០៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ , ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១ : ឥណទានចំណូលនៃថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដែលមានប្រភពចំណូល និង តាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានក្នុងតារាងជូនភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

មាត្រា២ : ចំណូលទាំងអស់នេះ ត្រូវបានប្រមូលដើម្បីគុណប្រយោជន៍ ដល់ថវិកាទូទៅរបស់រដ្ឋ និង ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការបែងចែកចំណូលនៃជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

ជំពូក	បរិយាយ	ចំនួនទឹកប្រាក់
	០១. ព្រះបរមរាជវាំង	1.157,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.157,0
	០៥. គណៈរដ្ឋមន្ត្រី	177.359,3
	ផ្នែក ១-ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់	124.843,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	2.420,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	122.423,0
	ផ្នែក ៣-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	51.886,3
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	55,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	51.831,3
	ផ្នែក ៤-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	630,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	630,0
	០៦. ក្រសួងការពារជាតិ	798,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	125,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	673,0
	០៧. ក្រសួងមហាផ្ទៃ	91.576,0
	ផ្នែក ១- សន្តិសុខសាធារណៈ	84.165,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	121,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	84.044,0
	ផ្នែក ៥- សាលាខេត្ត-ក្រុង	7.411,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	1.894,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	5.517,0
	០៩. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	49.740,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	1.025,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	48.715,0
	១០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	4.997.074,0
	១.១ ទីចាត់ការគយ និង រដ្ឋាករ	2.044.818,0
70	ចំណូលសារពើពន្ធក្នុងប្រទេស	1.181.976,0
71	ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	858.024,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	4.818,0

តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

ជំពូក	បរិយាយ	ចំនួនទឹកប្រាក់
	១.២ នាយកដ្ឋានពន្ធដារ	1.101.500,0
70	ចំណូលសារពើពន្ធក្នុងប្រទេស	1.100.000,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.500,0
	១.៣ ទីស្តីការក្រសួង	1.850.544,0
	-ចំណូលចរន្ត	129.144,0
70	ចំណូលសារពើពន្ធក្នុងប្រទេស	76.044,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	100,0
76	ផលហិរញ្ញវត្ថុ	13.000,0
77	ផលផ្សេងៗ និង ផលពិសេស	40.000,0
	-ចំណូលមូលធន	1.721.400,0
27	អចលកម្មហិរញ្ញវត្ថុ	100.000,0
13	ឧបត្ថម្ភធន	883.250,0
16	ការខ្ចី និង ចំណូលប្រហាក់ប្រហែល	738.150,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	212,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	87,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	125,0
	១១. ក្រសួងព័ត៌មាន	1.407,1
	ផ្នែក ១-ក្រសួង	1.308,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.308,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	99,1
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	42,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	57,1
	១២. ក្រសួងសុខាភិបាល	1.655,0
	ផ្នែក ១-ក្រសួង	1.435,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.435,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	220,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	220,0

តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

ជំពូក	អធិប្បាយ	ចំនួនឥណទាន
	១៣. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	27.509,4
	ផ្នែក ១-ក្រសួង	24.690,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	1.300,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	6.107,0
77	ផលផ្សេងៗ និង ផលពិសេស	17.283,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	2.819,4
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	1.226,9
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.592,5
	១៥. ក្រសួងពាណិជ្ជកម្ម	114.362,5
	ផ្នែក ១-ក្រសួង	114.139,5
71	ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	90.000,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	524,8
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	23.614,7
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	223,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	19,6
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	203,4
	១៦. ក្រសួងអប់រំ យុវជន និងកីឡា	967,0
	ផ្នែក ១-អប់រំ	717,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	214,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	503,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	250,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	250,0
	១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	25.222,7
	ផ្នែក ១-ក្រសួង	24.532,2
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	22.625,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.457,2
74	ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម	450,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	690,5
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	2,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	688,5

តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

ជំពូក	បរិយាយ	ចំនួនឥណទាន
	១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	2.217,5
	ផ្នែក ១-ក្រសួង	2.217,5
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	2.217,5
	១៩. ក្រសួងបរិស្ថាន	542,0
	ផ្នែក ១-ក្រសួង	510,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	330,0
74	ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម	180,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	32,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	32,0
	២២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	60.645,5
	ផ្នែក ១-ក្រសួង	59.528,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	59.528,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	1.117,5
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.117,5
	២៥. ក្រសួងសាធារណការ និងដឹកជញ្ជូន	11.042,4
	ផ្នែក ១-ក្រសួង	10.921,6
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	8.750,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	2.071,6
74	ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម	100,0
	ផ្នែក ៥-មន្ទីរជំនាញខេត្ត-ក្រុង	120,8
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	5,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	115,8
	២៦. ក្រសួងយុត្តិធម៌	463,0
	ផ្នែក ១-យុត្តិធម៌	75,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	75,0
	ផ្នែក ២-តុលាការកំពូល	130,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	130,0
	ផ្នែក ៣-សាលាឧទ្ធរណ៍	90,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	90,0

តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

ជំពូក	បរិយាយ	ចំនួនទឹកប្រាក់
	ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង	168,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	168,0
	២៧. ក្រសួងទេសចរណ៍	4.188,3
	ផ្នែក ១-ក្រសួង	4.109,2
70	ចំណូលសារពើពន្ធក្នុងប្រទេស	776,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	916,2
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	2.417,0
	ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង	79,1
70	ចំណូលសារពើពន្ធក្នុងប្រទេស	26,4
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	6,5
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	46,2
	២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	3.298,0
	ផ្នែក ១-ក្រសួង	542,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	542,0
	ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង	2.756,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	2.756,0
	៣២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	2.092,0
	ផ្នែក ១-ក្រសួង	1.900,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	1.880,0
74	ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម	20,0
	ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង	192,0
73	ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា	192,0
	ធនាគារជាតិនៃកម្ពុជា	35.000,0
72	ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	35.000,0
	សរុបចំណូលចរន្ត	3.886.916,7
	រដ្ឋបាលកណ្តាល	3.870.526,3
	មន្ទីរជំនាញខេត្ត-ក្រុង	16.390,4
	សរុបចំណូលមូលធន	1.721.400,0
	សរុបចំណូលថវិកាទូទៅរបស់រដ្ឋ	5.608.316,7

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

សម្រេច

មាត្រា១ :ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រី កងកំលាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ៦១ រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ក្នុងការចូលរួមជួយកសាងអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទ :

១- ឧត្តមសេនីយ៍ទោ RASYID Q. AQUARI
២- ឯកឧត្តម សំ សារ៉ែន
៣- លោកជំទាវ សែ ផារ៉ុម
៤- ឧត្តមសេនីយ៍ត្រី ឈឹម សុផា
៥- ឧត្តមសេនីយ៍ត្រី ឌី ផេន
៦- ឧត្តមសេនីយ៍ត្រី ថោង សារ៉ាត់
៧- វរសេនីយ៍ឯក យ៉ន្ត នឹម
៨- វរសេនីយឯក ជេត សាម៉េត
៩- វរសេនីយ៍ឯក ចាន់ សោភ័ណ្ឌភា
១០- វរសេនីយ៍ទោ គីត ធឿ
១១- វរសេនីយ៍ទោ សុខ សាគន្ធ
១២- វរសេនីយ៍ទោ ហាយ, ចណ្ឌី
១៣- វរសេនីយ៍ទោ សុខ សំណាង
១៤- លោក យ៉ន្ត ដឹក
១៥- លោក ម៉ាត់ អាល់មីន
១៦- លោក អ៊ុំ ម៉ារ៉េត
១៧- លោក កែវ ចំរ
១៨- លោក ទ៉ាង ទិធី
១៩- លោក ភាង ទីម៉ុង
២០- លោក អឿង គឹមហាក់
២១- លោក ហូច ប៉ាច
២២- លោក ចាន់ លាង
២៣- លោកស្រី គៀង កេសី
២៤- លោក យ៉ាំង ហុងលីន
២៥- លោក នួន សាន
២៦- លោក គឹម ពិសិដ្ឋ
២៧- លោក ប៉ាង ចាន់ថន
២៨- លោក យន កុសល
២៩- លោក នួច ឡឿន
៣០- លោក យី ឈុន

៣១- លោក	ឆៀង សុម៉េត	៤៣- លោក	ព្រាប សេរីវុត្ថា
៣២- លោក	គីម ខួន	៤៤- លោក	ឆ្លក់ វេស្សា
៣៣- លោក	អ៊ិន ម៉ាណូរិទ្ធ	៤៥- លោក	គួច ចំរើន
៣៤- លោក	នុត ស	៤៦- លោក	ឃួច ស្រេង
៣៥- លោក	ធូ ផុន	៤៧- លោក	ប្រ៊ីក ច័ន្ទណា
៣៦- លោក	ផាង ពៅ	៤៨- លោក	ហោ ទិដ្ឋា
៣៧- លោក	សរ សុផាន់ណា	៤៩- លោក	ANDREW TAY TENGYEW
៣៨- លោក	គង់ សំ	៥០- លោក	នី សៀន
៣៩- លោក	ស្រី សុវណ្ណ	៥១- លោក	នួន ឡុន
៤០- លោក	អ៊ឹម គួត	៥២- លោក	ឈុំ ប៊ុនហេង
៤១- លោក	ប៉ាង លីផា	៥៣- លោក	ឈេង ឈិ
៤២- លោក	អ៊ុំ ប៊ុនលី	៥៤- លោក	គិត សុផា

ខ-មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនា ៖

១- ឯកឧត្តម	អ៊ំ សារ៉ាត	៥- លោក	ឃុន សារឿន
២- លោក	ចាន់ ម៉ាន់ឡឿន	៦- លោក	អៀង សារូ
៣- លោកស្រី	ម៉ម ប៊ុនថា	៧- លោក	ប្រាក់ ហុងលន់
៤- លោក	អន ចណ្ណាខុន		

មាត្រា២៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...[illegible] អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ទោ លី ស៊ីហ៊ីង អត្តលេខ ១៣៨៦១៦ នាយសេនាធិការរង កងពលតូចលេខ៧០

២-វរសេនីយ៍ទោ ស្រី សរុ អត្តលេខ ០០៤២៤៨ នាយសេនាធិការរង កងពលតូចលេខ៧០

៣-វរសេនីយ៍ទោ គិន សំណា អត្តលេខ ២១៤០៦២ នាយសេនាធិការរង កងពលតូចលេខ៧០

៤-វរសេនីយ៍ទោ គង់ ម៉ុនឆាន អត្តលេខ ០១១៤៤៥ នាយសេនាធិការរង និងជានាយការិយាល័យបច្ចេកទេស កងពលតូចលេខ៧០

៥-វរសេនីយ៍ទោ ម៉ុន ចាន់នី អត្តលេខ ០០៨៨៣២ នាយសេនាធិការរង កងពលតូចលេខ៧០

៦-វរសេនីយ៍ទោ ឡោ គិន អត្តលេខ ០៣៩៣១៧ នាយសេនាធិការរង កងពលតូចលេខ៧០

៧-វរសេនីយ៍ទោ ខែ ណារិន អត្តលេខ ០៤៣៨៣៨ នាយសេនាធិការរង កងពលតូចលេខ៧០

៨-វរសេនីយ៍ទោ គង់ សុខហួច អត្តលេខ ២៣២០៣២ នាយសេនាធិការរង កងពលតូចលេខ៧០

៩-វរសេនីយ៍ទោ ទូ ដា អត្តលេខ ២៣១៥១៨ នាយសេនាធិការរង និងជានាយការិយាល័យ ទី៥ កងពលតូចលេខ៧០

១០-វរសេនីយ៍ទោ ញឹក ចំរើន អត្តលេខ ០០៣៣៨២ មេបញ្ជាការ វរៈសេនាតូចលេខ៣ កងពលតូចលេខ៧០

១១-វរសេនីយ៍ទោ ឆាក់ ឡៅ អត្តលេខ ០០៤៨៤០ មេបញ្ជាការ វរៈសេនាតូចលេខ៥ កងពលតូចលេខ៧០

១២-វរសេនីយ៍ទោ យ៉ា ពៅ អត្តលេខ ០១៩៧១៥ នាយសេនាធិការរង កងពលតូចលេខ៧០

១៣-វរសេនីយ៍ទោ ម៉ៃ គុណណេន អត្តលេខ ០១១៥៤៦ នាយសេនាធិការរង កងពលតូចលេខ៧០

១៤-វរសេនីយ៍ទោ នី លី អត្តលេខ ០០៩០៥១ អនុប្រធានទទួលបន្ទុកជំនាញភស្តុភារ ហិរញ្ញវត្ថុ មជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

១៥-វរសេនីយ៍ទោ កែវ សារឿន អត្តលេខ ០១១៤៣៦ ប្រធានគ្រប់គ្រងគ្រឿងផ្ទុះប្រឆាំងភេរវកម្ម ទំនាក់ទំនងសាធារណៈនិងរក្សាសន្តិភាព មជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

១៦-វរសេនីយ៍ទោ លី ចន្ធារ៉ា អត្តលេខ ០០៩៥១៨ អនុប្រធានទទួលបន្ទុកជំនាញសំភារៈ បច្ចេកទេស មជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

១៧-វរសេនីយ៍ទោ ហួត ចាន់ជាតិ អត្តលេខ ០០៩៥០៥ អនុប្រធានទទួលបន្ទុកជំនាញផែនការសិក្សា ស្រាវជ្រាវប្លង់បោះផ្លាកសញ្ញាទិន្នន័យ និងត្រួតពិនិត្យ មជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

១៨-វរសេនីយ៍ទោ សន គឹមផុន អត្តលេខ ០០៩៥៧៣ អនុប្រធានទទួលបន្ទុកជំនាញភស្តុភារ ហិរញ្ញវត្ថុ មជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ... ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គ... តេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤, ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ជនជាតិសឹង្ហបុរី ចំនួន ០២ រូប បានជួយឧបត្ថម្ភជាក្រណាត់សំរាប់កាត់ដេរឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ ចំណុះក្រសួងការពារជាតិ ចំនួន ៣.៨១៦.៥០ ម៉ែត្រ គិតជាទឹកប្រាក់ សរុបចំនួន ២៦.៧១៥ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ÷

១-លោក	ANG YONG SING	នាយកក្រុមហ៊ុន FIST WEILI CAPITAL ទឹកប្រាក់ចំនួន ១៣.៣៥៧.៥ ដុល្លារ
២-លោកស្រី	ZHANG JIAN RONG	នាយិកាក្រុមហ៊ុន RONG YUA INTERNATIONAL SINGAPORE ទឹកប្រាក់ចំនួន ១៣.៣៥៧.៥ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយសហមេត្រីថ្នាក់ អស្សឫទ្ធិ** ចំនួន ០៤ គ្រឿង ជូននាយទាហាន នៃសាធារណរដ្ឋប្រជាមានិតចិន ដែលមានស្នាដៃល្អក្នុងការលើកស្ទួយ ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ ជួយបង្ហាត់បង្រៀនអ្នកឯកទេស កម្ពុជា នៅមន្ទីរពេទ្យព្រះកេតុមាលា រវាង កងយោធពលខេមរភូមិន្ទ នៃព្រះរាជាណាចក្រកម្ពុជា និង កងទ័ពរំដោះប្រជាជនចិន ដូចមានរាយនាមខាងក្រោម ÷

១-វរសេនីយ៍ឯកពិសេស **ស៊ី ហៃឈិន** (Sr.Col. SI HAICHEN) វិស្វករ ផ្នែកជួសជុលសំភារៈ
២-វរសេនីយ៍ឯក **នាគ យ៉ុងខាង** (Col. NIE YONGKANG) ផ្នែក CT-scan ថ្នាក់បណ្ឌិត
៣-វរសេនីយ៍ទោ **ចាង អ៊ូស៊ុញ** (Lt Col. ZHANG WUXING) ផ្នែកលាងឈាម ថ្នាក់បណ្ឌិត
៤-វរសេនីយ៍ត្រី **លីវ កាំង** (Maj. LIU GANG) ផ្នែកកាំរស្មីអ៊ិច ថ្នាក់អនុបណ្ឌិត

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៧

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៦០០០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ៖ ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១- លោកវរសេនីយ៍ទោ ជា ម៉ុនឌុល អត្តលេខ ០៦៣៧
46	តម្លៃគិតពន្ធគយ	ចាំបាច់	ប្រអប់នេះបរិយាយពីតម្លៃគិតពន្ធគយ។ ប្រអប់នេះនឹងត្រូវបានបំពេញតម្លៃជាលុយរៀលនៃទំនិញដែលបានបរិយាយក្នុងប្រអប់៣១ ផ្អែកតាមវិធានតម្លៃគិតពន្ធគយក្រោមច្បាប់ស្តីពីគយ។ តម្លៃនេះ គឺជាថ្លៃទំនិញដែលបានកែតម្រូវអោយត្រូវតាមកត្តាតម្លៃគិតជា FOB។
47	ការគណនាពន្ធ	ចាំបាច់	ប្រអប់នេះរួមមានកត្តាពាក់ព័ន្ធទៅនឹងការគណនាពន្ធ ដូចមានក្នុងចំណុចខាងក្រោម៖ i) ប្រភេទ ប្រភេទពន្ធ ឬអាករ ដែលអាចអនុវត្តក្រោមច្បាប់កម្ពុជាដូចជាពន្ធនាំចូល ពន្ធនាំចេញ អាករ អាករលើតម្លៃបន្ថែម។ល។ ii) មូលដ្ឋានពន្ធ មូលដ្ឋានពន្ធ គឺជាតម្លៃគិតពន្ធគយនៅពេលដែលចំនួនប្រាក់ពន្ធ/អាករកំណត់ដោយគយផ្អែកតាមមូលដ្ឋាននៃការគណនា។ iii) អត្រា អត្រាពន្ធ/អាករត្រូវផ្អែកលើមូលដ្ឋានកូដតារាងពន្ធគយសំរាប់មុខទំនិញជាក់លាក់ណាមួយ។ iv) ចំនួនប្រាក់ពន្ធ សរុបចំនួនប្រាក់ពន្ធ/អាករ ត្រូវបានគណនា [illegible] ផ្អែកតាមអត្រាពន្ធ/អាករ។

			v) បែបផែនទូទាត់ ប្រអប់នេះបង្ហាញថាពន្ធត្រូវបង់(១) ត្រូវបានធានា(៣) ឬ ត្រូវបានគណនាសំរាប់តែជាព័ត៌មាន(០)។
48	ការទូទាត់ជាក្រោយ	ជម្រើស	ប្រសិនបើការទូទាត់ជាក្រោយត្រូវបានប្រើប្រាស់ ប្រអប់នេះត្រូវបានបំពេញជាមួយលេខគណនីឥណទាន ឬលេខគណនីទូទាត់ជាមុន។
49	អត្តសញ្ញាណឃ្លាំងទំនិញ		ប្រអប់នេះសំដៅលើនីតិវិធីព្យួរពន្ធ។ ប្រសិនបើនីតិវិធីគយមិនមែនជានីតិវិធីព្យួរពន្ធ ប្រអប់នេះមិនត្រូវបានប្រើ។ ប្រអប់នេះមានពីរផ្នែក: ផ្នែកទី១- គឺបញ្ចូលកូដឃ្លាំង ឧ. អត្តសញ្ញាណឃ្លាំងដែលទំនិញនឹងត្រូវបានដាក់បញ្ចូល។ ចាំបាច់សម្រាប់តែរបបព្យួរពន្ធ និងមិនចាំបាច់សម្រាប់ករណីផ្សេងពីនេះ។ ផ្នែកទី២- គឺបញ្ចូលរយៈពេល (ចំនួនថ្ងៃ) ដែលទំនិញត្រូវបានអនុញ្ញាតអោយស្តុកទុកក្នុងឃ្លាំងណាមួយ។ ចាំបាច់សម្រាប់តែរបបព្យួរពន្ធ និងមិនចាំបាច់សម្រាប់ករណីផ្សេងពីនេះ។
B.	គណនេយ្យលំអិត	ចាំបាច់	ប្រអប់នេះត្រូវបានប្រើប្រាស់សំរាប់ព័ត៌មានដែលទាក់ទងនឹងគណនេយ្យ ដូចជាបែបបផែនទូទាត់ លេខវាយតម្លៃ លេខបង្កាន់ដៃ និងការធានា ដូចខាងក្រោម: **i) បែបផែនទូទាត់** បែបផែនទូទាត់ (ប្រអប់ B) ត្រូវប្រើភ្ជាប់នឹងប្រអប់ 48។ ប្រសិនបើប្រអប់ 48 មិនបានបំពេញ មាននឹយថាប្រាក់ពន្ធ និងអាករត្រូវបានទូទាត់ភ្លាមៗ (ឬ បង់សាច់ប្រាក់)។ ប្រសិនបើប្រអប់ 48 ត្រូវបានបំពេញដោយលេខមូលបទានប័ត្រ ឬលេខគណនី មាននឹយថាពន្ធ និងអាករត្រូវបានទូទាត់ជាក្រោយ។ **ii) លេខវាយតម្លៃ** ប្រព័ន្ធ ASYCUDA នឹងផ្តល់លេខវាយតម្លៃដោយស្វ័យប្រវត្តិនៅលើប្រតិវេទន៍ក្រោយពីបញ្ចប់ការវាយតម្លៃ។ ចំពោះការបំពេញប្រតិវេទន៍ដោយដៃមិនមានលេខវាយតម្លៃនេះទេ។ **iii) លេខបង្កាន់ដៃ** ប្រព័ន្ធ ASYCUDA នឹងផ្តល់លេខបង្កាន់ដៃដោយស្វ័យប្រវត្តិនៅលើប្រតិវេទន៍ក្រោយពីការទូទាត់ពន្ធនិងអាកររួច។ ចំពោះការបំពេញប្រតិវេទន៍ [illegible] ត្រូវសរសេរលេខបង្កាន់ដៃពន្ធនៅលើប្រតិវេទន៍ [illegible] **iv) ការធានា**

			ប្រព័ន្ធ ASYCUDA នឹងបង្ហាញចំនួនប្រាក់ពន្ធ និងអាករសរុប ដែលជានានៅលើប្រតិវេទន៍។ ការប្រើ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញនូវចំនួនប្រាក់ពន្ធ និងអាករដែលជានានៅលើប្រតិវេទន៍។ v) តម្លៃសរុប បើសិនជាមានតម្លៃដែលត្រូវទូទាត់ច្រើនប្រភេទ(តម្លៃPSI + តម្លៃពីការលក់ប្រតិវេទន៍)ប្រអប់ Bត្រូវបំពេញនូវតម្លៃសរុបដែលត្រូវទូទាត់។ ចំពោះការប្រើប្រព័ន្ធ តម្លៃនីមួយៗត្រូវបានបង្ហាញនៅលើប័ណ្ណវាយតម្លៃ។ ការប្រើ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញនូវតម្លៃនីមួយៗនៅក្រោមប្រអប់ D។ vi) ប្រាក់ពន្ធសរុបលើប្រតិវេទន៍ សរុបចំនួនប្រាក់ពន្ធ អាករ និងតម្លៃផ្សេងៗ ត្រូវបង់សំរាប់ប្រតិវេទន៍នេះ: (សរុបពន្ធ / អាករ + សរុបតម្លៃ)
54	ហត្ថលេខា និងឈ្មោះប្រតិវេទនករ/អ្នកតំណាង	ចាំបាច់	ឈ្មោះ កាលបរិច្ឆេទ និងហត្ថលេខាប្រតិវេទនករ/អ្នកតំណាងៗ
50 51 52 53 C D			បំរុងទុកសំរាប់ប្រើនាពេលអនាគត

ឧបសម្ព័ន្ធ ខ

បញ្ញត្ត និងល័ក្ខខ័ណ្ឌ នានាសម្រាប់ការដាក់ប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ "SAD") តាមមធ្យោបាយអេឡិចត្រូនិក

ការដាក់ឲ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ASYCUDA ផ្តល់លទ្ធភាពឲ្យដាក់ប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមមធ្យោបាយអេឡិចត្រូនិក។

នីតិវិធីទូទៅដែលអ្នកនាំចូល អ្នកនាំចេញ និងអ្នកតំណាង ត្រូវអនុវត្តតាមសម្រាប់ការដាក់ប្រតិវេទន៍គយតាមមធ្យោបាយអេឡិចត្រូនិក មានចែងក្នុងឧបសម្ព័ន្ធនេះ។ នាយកទីចាត់ការគយនិងរដ្ឋាករ ត្រូវចេញនូវនីតិវិធី និងសេចក្តីណែនាំលំអិតនានាសម្រាប់បំរើឲ្យការអនុវត្តនូវឧបសម្ព័ន្ធនេះ។

១. ការរៀបចំ និងការបោះពុម្ពប្រតិវេទន៍គយ

ជើងសារគយ ឬប្រតិវេទករ ត្រូវបំពេញប្រតិវេទន៍គយដោយផ្ទាល់ទៅក្នុងប្រព័ន្ធ ASYCUDA។ ប្រព័ន្ធនេះនឹងឆែកពិនិត្យប្រតិវេទន៍ ផ្ទៀងផ្ទាត់ទៅនឹងឯកសារយោងដែលមាននៅក្នុងប្រព័ន្ធ និងដំណើរការត្រួតពិនិត្យមួយចំនួន។ ប្រព័ន្ធនឹងអនុញ្ញាតឲ្យចុះបញ្ជិកា តែនៅពេលដែលទិន្នន័យទាំងអស់មានភាពគ្រប់គ្រាន់ និងមានសុពលភាព។ ប្រតិវេទន៍ដែលចុះបញ្ជិការួច អាចទុកជាមោឃៈបាន បន្ទាប់ពីមានការអនុញ្ញាតពីទីចាត់ការគយនិងរដ្ឋាករ។ មានតែប្រតិវេទន៍ដែលចុះបញ្ជិការួចប៉ុណ្ណោះ ត្រូវបានចាត់ទុកជាឯកសារគតិយុត្តិ។

បន្ទាប់ពីចុះបញ្ជិការួច ជើងសារគយ ឬប្រតិវេទករត្រូវបោះពុម្ព និងចុះហត្ថលេខាលើប្រតិវេទន៍ចុះបញ្ជិការួច ចំនួនពីរ(២)ច្បាប់ ដាក់ជូនមន្ត្រីគយមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយនូវឯកសារយោងទាំងអស់ដែលតម្រូវ។

ប្រព័ន្ធនឹងដំណើរការដោយស្វ័យប្រវត្តិ ជូនជាព័ត៌មានដល់ជើងសារគយ ឬប្រតិវេទករ ពីស្ថានភាពនៃដំណើរការប្រតិវេទន៍។

២. ការដាក់ប្រតិវេទន៍គយ

មន្ត្រីគយនៅផ្នែកទទួលការដាក់ឯកសារ ឆែកពិនិត្យមើលប្រតិវេទន៍គយចុះបញ្ជិការួចទម្រង់ជាក្រដាសនិងឯកសារយោងនានា ជាមួយទិន្នន័យក្នុងប្រព័ន្ធ ដើម្បីឲ្យប្រាកដថា ប្រតិវេទន៍គយត្រូវបានបំពេញត្រឹមត្រូវ បានបោះពុម្ពច្បាស់និងអាចអានបាន មានចុះហត្ថលេខាដោយជើងសារគយ ឬប្រតិវេទករ-និងមានឯកសារភ្ជាប់ចាំបាច់នានាត្រូវបានដាក់ជាមួយនឹងប្រតិវេទន៍

មន្ត្រីគយអាចបដិសេធប្រតិវេទន៍ណាមួយដែលមិនស្របតាមតម្រូវការ

៣. ច្រកដំណើរការប្រតិវេទន៍គយ

នៅពេលប្រតិវេទន៍គយត្រូវបានឆែកពិនិត្យគ្រប់គ្រាន់និងត្រឹមត្រូវ មន្ត្រីគយបញ្ជាប្រព័ន្ធឲ្យវាយតំលៃប្រតិវេទន៍គយ។ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យគ្រប់គ្រងហានិភ័យ ប្រព័ន្ធនឹងកំណត់ច្រកដំណើរការប្រតិវេទន៍ ដូចខាងក្រោម៖

-**ច្រកក្រហម៖** ប្រតិវេទន៍គយនឹងត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយឯកសារ ហើយទំនិញនឹងត្រូវធ្វើអធិការកិច្ចជារូបវ័ន្ត មុនពេលធ្វើការប្តូរច្រកប្រតិវេទន៍គយទៅ **ច្រកបៃតង** និងវាយតំលៃដោយមន្ត្រីគយ។

-**ច្រកលឿង៖** ប្រតិវេទន៍គយនឹងត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយឯកសារ មុនពេលធ្វើការប្តូរច្រកប្រតិវេទន៍គយទៅ **ច្រកបៃតង** និងវាយតម្លៃដោយមន្ត្រីគយ។

-**ច្រកបៃតង៖** ប្រតិវេទន៍គយត្រូវបានវាយតម្លៃដោយស្វ័យប្រវត្តិ ហើយចេញឯកសារបញ្ចេញទំនិញ។ ប្រតិវេទន៍គយទម្រង់ជាក្រដាស អាចជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញ។

-**ច្រកខៀវ៖** ប្រតិវេទន៍គយត្រូវបានផ្តល់ប្រព្រឹត្តកម្មដូចគ្នាទៅនឹងច្រកបៃតង និងជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញជាមួយហេតុផលជាក់លាក់។

ក្នុងករណីដែលប្រតិវេទន៍ត្រូវបានជ្រើសរើសឲ្យដំណើរការតាមច្រកក្រហម និងលឿង មន្ត្រីគយផ្ទៀងផ្ទាត់ លក្ខណៈវិនិច្ឆ័យជ្រើសរើសដែលបណ្តាលឲ្យប្រតិវេទន៍ត្រូវបានជ្រើសរើសដាក់បញ្ចូលក្នុងច្រកនេះ។ ប្រព័ន្ធ នឹងបង្ហាញពីតម្រូវការពិសេសដែលត្រូវឆែកពិនិត្យ ដូចជាការតម្រូវឲ្យមានអាជ្ញាប័ណ្ណនាំចូល ឲ្យដកទំនិញគំរូ ប្រវត្តិនៃការរត់គេចពន្ធ ។ល។

៤. កន្លែងសាកសួរ

ប្រតិវេទន៍គយដែលត្រូវបានរកឃើញកំហុសឆ្គង ឬភាពមិនប្រក្រតីនានា នាពេលត្រួតពិនិត្យឯកសារ ឬពេលត្រួតពិនិត្យទំនិញជារូបវ័ន្ត ត្រូវបញ្ជូនទៅកន្លែងសាកសួរ។ ជើងសារគយ ឬប្រតិវេទករនឹងត្រូវបានជូនដំណឹងថាប្រតិវេទន៍គយបានបញ្ជូនទៅ "កន្លែងសាកសួរ" និងហេតុផលដែលនាំឲ្យមានការបញ្ជូនករណីនេះទៅ "កន្លែងសាកសួរ"។

នៅពេលទទួលបានការជូនដំណឹង ជើងសារគយ ឬប្រតិវេទករ ត្រូវបង្ហាញខ្លួននៅ "កន្លែងសាកសួរ"។ ការកែតម្រូវណាមួយលើប្រតិវេទន៍គយ នឹងត្រូវពិភាក្សារវាងមន្ត្រីគយផ្នែកសាកសួរ និងជើងសារគយ ឬប្រតិវេទករ។ ប្រសិនបើមិនមានការព្រមព្រៀង មន្ត្រីគយត្រូវរៀបចំរបាយការណ៍ ឬកំណត់ហេតុបញ្ជូនទៅទីចាត់ការគយនិងរដ្ឋាករ ដើម្បីមានវិធានការបន្ត។

នៅពេលដែលសកម្មភាពខាងលើត្រូវបានបំពេញរួចនិងមានការព្រមព្រៀង មន្ត្រីគយនឹងចុះហត្ថលេខាលើប្រតិវេទន៍ដែលកែតម្រូវរួច ហើយធ្វើបច្ចុប្បន្នភាពនូវឯកសារលទ្ធផលនៃការត្រួតពិនិត្យ

តាមលទ្ធផលនៃដំណោះស្រាយនៅកន្លែងសាគស្នារ ឬតាមសេចក្តីសម្រេចរបស់ទីចាត់ការគយ និងរដ្ឋាករ រួចប្តូរច្រកប្រតិវេទន៍ទៅច្រកបៃតង។

៥. ការស្កេនកុងតឺន័រ

ការស្កេនកុងតឺន័រ ត្រូវបានធ្វើឡើងដាច់ដោយឡែកពីដំណើរការប្រតិវេទន៍ ។

ប្រព័ន្ធ នឹងមានប្រើប្រាស់នៅក្នុងការិយាល័យស្កេន ដែលអាចជួយដល់មន្ត្រីផ្នែកស្កេន ធ្វើការប្រៀបធៀបទំនិញដែលបានប្រកាសលើប្រតិវេទន៍គយ ជាមួយនឹងអ្វីដែលបានឃើញនៅលើរូបភាពស្កេន ឬព័ត៌មានស្កេន ។

ភាពមិនប្រក្រតីណាមួយបានរកឃើញ ត្រូវកត់ត្រាបញ្ចូលទៅក្នុងទម្រង់លទ្ធផលត្រួតពិនិត្យដោយគយ។

៦.ការជូនដំណឹងវាយតំលៃ

នៅពេលដែលប្រតិវេទន៍គយត្រូវបានវាយតម្លៃដោយប្រព័ន្ធ ការជូនដំណឹងវាយតម្លៃត្រូវបានបង្ហាញ ដែលមានរៀបរាប់ពីចំនួនប្រាក់ពន្ធគយនិងអាករត្រូវបង់។ ការជូនដំណឹងនេះ ត្រូវបានប្រើប្រាស់ជាឯកសារយោងដើម្បីបង់ពន្ធ អាករ និងកម្រៃនានា។

៧. គណនេយ្យ

ពន្ធ អាករ និងកំរៃនានា ត្រូវបង់ស្របតាមបទប្បញ្ញត្តិជាធរមាន។ ប្រសិនបើត្រូវបង់នៅធនាគារជាតិនៃកម្ពុជា ឬនៅស្ថាប័នហិរញ្ញវត្ថុដែលមានការអនុញ្ញាតផ្សេងទៀត សក្ខីបត្ររបស់ស្ថាប័នទាំងនេះត្រូវជូនដល់មន្ត្រីគយមានសមត្ថកិច្ច ហើយប្រព័ន្ធនឹងចេញនូវបង្កាន់ដៃគយ។

៨. ការអនុញ្ញាតឲ្យយកទំនិញចេញពីគយ

ក្រោយពីការបង់ពន្ធ អាករ បន្ទុក និងកម្រៃនានា មន្ត្រីគយមានសមត្ថកិច្ច ចេញប័ណ្ណអនុញ្ញាតឲ្យយកទំនិញចេញ។ ប័ណ្ណនេះមានចែងលំអិតព័ត៌មានពីពន្ធ អាករ និងកម្រៃនានាដែលពាក់ព័ន្ធទៅនឹងប្រតិវេទន៍ហើយត្រូវបានប្រើប្រាស់ដើម្បីអនុញ្ញាតឲ្យយកទំនិញចេញពីគយ។

៩. សវនកម្មក្រោយពេលបញ្ចេញទំនិញ

ប្រតិវេទន៍ដែលត្រូវបានជ្រើសរើសតាមច្រកខៀវ និងច្រកបៃតង ត្រូវធ្វើសវនកម្មជាសំខាន់លើមូលដ្ឋានក្រោយពេលបញ្ចេញទំនិញពីគយ។

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ឯកសាររដ្ឋបាលតែមួយ SINGLE ADMINISTRATIVE DOCUMENT

ប្រតិវេទន៍គយ CUSTOMS DECLARATION

COPY1

2 Exporter/Consignor — Code No.:

1 TYPE OF DECLARATION

3 Forms — 4 xxxx

A OFFICE OF LODGEMENT

Office Code:

Manifest:

Customs Registration:

Number: — Date:

5 Items — 6 Tot. Pack. — 7 Declarant Reference Number

8 Importer/Consignee — Code No.:

9 Occasional Consignee / Exporter:

Name:

ID:

Address:

10 Country LC/FD Code — 11 xx — 12 Value Details — 13 PSI

14 Declarant / Representative — Code No.:

15 Country of Export — 15 C.E. Code — 17 C.D. Code XX

16 Country of Origin — 17 Country of Destination

18 Ident. & Nat. of MOT at Arrival/Departure — 19 Ctr.

20 Delivery Terms — XX

21 Ident. & Nat. of MOT Crossing the Border

22 Cur. & Tot. Invoice Amount — 23 Exch. Rate — 24 Nature of Transaction

25 Mode of Trsp. at Border — 26 Inland Mode of Trsp. — 27 Place of Loading/ Discharge

28 Bank Code:

Terms of Payment:

29 Office of Entry / Exit — 30 Location of Goods

Bank Name:

Branch: — File No:

31 DESCRIPTION OF GOODS

Marks on Packages:

a)

b)

Number and Type:

Container Identifier:

Goods Description as Per Tariff:

Commercial Description:

32 Item No. — 33 Commodity Code

34 C.O. Code — 35 Gross Mass kg — 36 Preference

37 Procedure — 38 Net Mass kg — 39 xxxx

40 Transport Doc. / Previous Declaration

41 Suppl. Units — 42 Item Price — 43 Valuation Method

44 License No.: — DV: — DQ:

Value Details:

Attached Doc.:

Other Additional Information:

45 Adjustment

46 Customs Value

47 CALCUL. OF TAXES

Type	Tax Base	Rate	Amount	MP
		Total :		

48 Deferred Payment — 49 Identification of Warehouse

B ACCOUNTING DETAILS

Mode of Payment:

Assessment No.: — Date:

Receipt No.: — Date:

Guarantee: — Date:

Total Fees: — in Riels

Total Declaration: — in Riels

50 Principal — No.: — Signature

C OFFICE OF DEPARTURE

51

52 Guarantee

Not Valid for:

Code

53 Office of Destination (and Country)

D CONTROL BY OFFICE OF DESTINATION

Result:

Signature:

Stamp:

54 Place and Date

Signature and Name of Declarant / Representative

E ការត្រួតពិនិត្យទំនិញរបស់មន្ត្រីគយ Inspection Act by Customs Officers

I. បរិយាយពីការត្រួតពិនិត្យ Description of Inspection:

II. ភាពមិនប្រក្រតី បើមាន Irregularity, if any:

1. បរិមាណ Quantity ☐
2. ទម្ងន់ Weight ☐
3. តម្លៃ Value ☐
4. ដើមកំណើត Origin ☐
5. ចំណាត់ថ្នាក់ Classification ☐
6. បរិយាយតាមវិក្កយបត្រពាណិជ្ជកម្ម Commercial Description ☐
7. ក្លែងបន្លំ Counterfeit / Fake ☐
8. ជាប់ហាមឃាត់/មានកំរិតកំណត់ Prohibited / Restricted ☐
9. ផ្សេងទៀត Other..

....

ឈ្មោះ ហត្ថលេខា និងកាលបរិច្ឆេទ
Name, Signature and Date

F សេចក្តីសន្និដ្ឋានលើការត្រួតពិនិត្យ Conclusion of Inspection

ឈ្មោះ ហត្ថលេខា និងត្រា
Name, Signature and Stamp

ប័ណ្ណបញ្ចេញលេខ......................ចុះថ្ងៃទី..........ខែ.......... ឆ្នាំ..........អនុញ្ញាតដោយ:
Release Note No. .... Date DD.........MM.........YY..........Authorized by:

G ការត្រួតពិនិត្យក្រោយពីការយកទំនិញចេញពីគយ Post Clearance Review

ឈ្មោះ ហត្ថលេខា និងកាលបរិច្ឆេទ
Name, Signature and Date

H ការពិន័យ Penalties	
យោងកំណត់ហេតុលេខ Reference to Offence Record No.:	ឈ្មោះ ហត្ថលេខា និងកាលបរិច្ឆេទ Name, Signature and Date
ចំនួនសរុបការគិតពន្ធនិងអាករបន្ថែម Amount of Additional Duty and Taxes :	
លេខបង្កាន់ដៃ Receipt No. :	
ចំនួនសរុបនៃការពិន័យ Amount of Penalties :	
លេខបង្កាន់ដៃ Receipt No. :	

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ឯកសាររដ្ឋបាលតែមួយ SINGLE ADMINISTRATIVE DOCUMENT

ប្រតិវេទន៍គយ CUSTOMS DECLARATION

COPY2	2 អ្នកនាំចេញ ឬ អ្នកនាំចូល Exporter/Importer — លេខកូដ Code No.:	1 ប្រភេទប្រតិវេទន៍ TYPE OF DECLARATION	3 ទម្រង់ Forms	4 xxxx	A ការិយាល័យដាក់ប្រតិវេទន៍ OFFICE OF LODGEMENT; លេខកូដការិយាល័យ Office Code:; និងលេខបញ្ជី Manifest:; បញ្ជិកាគយ Customs Registration:; លេខ Number; កាលបរិច្ឆេទ Date:

31 DESCRIPTION OF GOODS (បរិយាយមុខទំនិញ)

- សញ្ញាសម្គាល់កញ្ចប់ Marks on Packages:
  - a)
  - b)
- ចំនួននិងប្រភេទ Number and Type:
- អត្តសញ្ញាណកុងតឺន័រ Container Identifier:
- បរិយាយមុខទំនិញតាមពិកន្ទ Goods Description as Per Tariff:
- បរិយាយពាណិជ្ជកម្ម Commercial Description:

32 ទំនិញទី Item No.	33 លេខកូដទំនិញ Commodity Code		
34 កូដប្រទេសកំណើត C.O. Code	35 ទម្ងន់សរុប Gross Mass kg	36 ករុអនុគ្រោះ Preference	
37 នីតិវិធី Procedure	38 ទម្ងន់សុទ្ធ Net Mass kg	39 xxxx	
40 ឯកសារដឹកជញ្ជូន ឬ ប្រតិវេទន៍មុន Transport Doc. / Previous Declaration			
41 ឯកតាបន្ថែម Suppl. Units	42 តម្លៃមុខទំនិញ Item Price	43 វិធីកំណត់តម្លៃ Valuation Method	

44 AD. INFO (ព័ត៌មានបន្ថែម)

- លេខអាជ្ញាប័ណ្ណ License No.: — តម្លៃបន្ទុយ DV: — បរិមាណបន្ទុយ DQ:
- តម្លៃលំអិត Value Details:
- ឯកសារភ្ជាប់ Attached Doc.:
- ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

45 កែតម្រូវ Adjustment

46 តម្លៃគិតពន្ធគយ Customs Value

31 DESCRIPTION OF GOODS (បរិយាយមុខទំនិញ)

- សញ្ញាសម្គាល់កញ្ចប់ Marks on Packages:
  - a)
  - b)
- ចំនួននិងប្រភេទ Number and Type:
- អត្តសញ្ញាណកុងតឺន័រ Container Identifier:
- បរិយាយមុខទំនិញតាមពិកន្ទ Goods Description as Per Tariff:
- បរិយាយពាណិជ្ជកម្ម Commercial Description:

32 ទំនិញទី Item No.	33 លេខកូដទំនិញ Commodity Code		
34 កូដប្រទេសកំណើត C.O. Code	35 ទម្ងន់សរុប Gross Mass kg	36 ករុអនុគ្រោះ Preference	
37 នីតិវិធី Procedure	38 ទម្ងន់សុទ្ធ Net Mass kg	39 xxxx	
40 ឯកសារដឹកជញ្ជូន ឬ ប្រតិវេទន៍មុន Transport Doc. / Previous Declaration			
41 ឯកតាបន្ថែម Suppl. Units	42 តម្លៃមុខទំនិញ Item Price	43 វិធីកំណត់តម្លៃ Valuation Method	

44 AD. INFO (ព័ត៌មានបន្ថែម)

- លេខអាជ្ញាប័ណ្ណ License No.: — តម្លៃបន្ទុយ DV: — បរិមាណបន្ទុយ DQ:
- តម្លៃលំអិត Value Details:
- ឯកសារភ្ជាប់ Attached Doc.:
- ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

45 កែតម្រូវ Adjustment

46 តម្លៃគិតពន្ធគយ Customs Value

31 DESCRIPTION OF GOODS (បរិយាយមុខទំនិញ)

- សញ្ញាសម្គាល់កញ្ចប់ Marks on Packages:
  - a)
  - b)
- ចំនួននិងប្រភេទ Number and Type:
- អត្តសញ្ញាណកុងតឺន័រ Container Identifier:
- បរិយាយមុខទំនិញតាមពិកន្ទ Goods Description as Per Tariff:
- បរិយាយពាណិជ្ជកម្ម Commercial Description:

32 ទំនិញទី Item No.	33 លេខកូដទំនិញ Commodity Code		
34 កូដប្រទេសកំណើត C.O. Code	35 ទម្ងន់សរុប Gross Mass kg	36 ករុអនុគ្រោះ Preference	
37 នីតិវិធី Procedure	38 ទម្ងន់សុទ្ធ Net Mass kg	39 xxxx	
40 ឯកសារដឹកជញ្ជូន ឬ ប្រតិវេទន៍មុន Transport Doc. / Previous Declaration			
41 ឯកតាបន្ថែម Suppl. Units	42 តម្លៃមុខទំនិញ Item Price	43 វិធីកំណត់តម្លៃ Valuation Method	

44 AD. INFO (ព័ត៌មានបន្ថែម)

- លេខអាជ្ញាប័ណ្ណ License No.: — តម្លៃបន្ទុយ DV: — បរិមាណបន្ទុយ DQ:
- តម្លៃលំអិត Value Details:
- ឯកសារភ្ជាប់ Attached Doc.:
- ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

45 កែតម្រូវ Adjustment

46 តម្លៃគិតពន្ធគយ Customs Value

47 CALCUL. OF TAXES (ការគណនាពន្ធ និងអាករ)

ប្រភេទ Type	មូលដ្ឋានពន្ធ Tax base	អត្រា Rate	ប្រាក់ពន្ធ Amount	ប.ទ.ទ MP	ប្រភេទ Type	មូលដ្ឋានពន្ធ Tax base	អត្រា Rate	ប្រាក់ពន្ធ Amount	ប.ទ.ទ MP
សរុបមុខទំនិញទី Total Item No. :					សរុបមុខទំនិញទី Total Item No. :				

សរុបនិទ្ទេស RECAPITULATION

ប្រភេទ Type	មូលដ្ឋានពន្ធ Tax base	អត្រា Rate	ប្រាក់ពន្ធ Amount	ប.ទ.ទ MP	ប្រភេទ Type	ប្រាក់ពន្ធ Amount	ប.ទ.ទ MP
សរុបមុខទំនិញទី Total Item No. :					សរុប G. Total		

C ការិយាល័យចេញដំណើរ Office of Departure

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ឯកសាររដ្ឋបាលតែមួយ SINGLE ADMINISTRATIVE DOCUMENT

1 ប្រភេទប្រតិវេទន៍ TYPE OF DECLARATION

3 ទម្រង់ Forms | 4 xxxx

ប្រតិវេទន៍គយ CUSTOMS DECLARATION

A ការិយាល័យដាក់ប្រតិវេទន៍ OFFICE OF LODGEMENT

កូដការិយាល័យ Office Code :

និវេទនប័ណ្ណ Manifest :

បញ្ជិកាគយ Customs Registration :

លេខ Number: | កាលបរិច្ឆេទ Date:

COPY1

2 អ្នកនាំចេញ ឬ អ្នកនាំចូល Exporter/ Importer: | លេខកូដ Code No. :

31 | DESCRIPTION OF GOODS

ស្លាកសញ្ញាលើកញ្ចប់ Marks on Packages:
a)
b)

ចំនួននិងប្រភេទ Number and Type:

អត្តសញ្ញាណកុងតឺន័រ Container Identifier:

បរិយាយមុខទំនិញតាមពិកាគន្ធ Goods Description as Per Tariff :

បរិយាយតាមបែបពាណិជ្ជកម្ម Commercial Description:

32 ទំនិញទី Item No.

33 លេខកូដទំនិញ Commodity Code

34 កូដប្រទេសកំណើត C.O. Code | 35 ទម្ងន់សរុប Gross Mass kg | 36 អនុគ្រោះ Preference

37 របបគយ Procedure | 38 ទម្ងន់សុទ្ធ Net Mass kg | 39 xxxx

40 ឯកសារ ដឹកជញ្ជូន ឬ ប្រតិវេទន៍មុន Transport Doc. / Previous Declaration

41 ឯកតារង Suppl. Units | 42 តម្លៃមុខទំនិញ Item Price | 43 វិធីកំណត់តម្លៃ Valuation Method

44 | AD.INFO

លេខអាជ្ញាប័ណ្ណ License No. : | តម្លៃបន្ថយ DV: | បរិមាណបន្ថយ DQ:

តម្លៃលំអិត Value Details:

ឯកសារភ្ជាប់ Attached Doc. :

ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

45 កែតម្រូវ Adjustment

46 តម្លៃគិតពន្ធគយ Customs Value

31 | DESCRIPTION OF GOODS

ស្លាកសញ្ញាលើកញ្ចប់ Marks on Packages:
a)
b)

ចំនួននិងប្រភេទ Number and Type:

អត្តសញ្ញាណកុងតឺន័រ Container Identifier:

បរិយាយមុខទំនិញតាមពិកាគន្ធ Goods Description as Per Tariff :

បរិយាយតាមបែបពាណិជ្ជកម្ម Commercial Description:

32 ទំនិញទី Item No.

33 លេខកូដទំនិញ Commodity Code

34 កូដប្រទេសកំណើត C.O. Code | 35 ទម្ងន់សរុប Gross Mass kg | 36 អនុគ្រោះ Preference

37 របបគយ Procedure | 38 ទម្ងន់សុទ្ធ Net Mass kg | 39 xxxx

40 ឯកសារ ដឹកជញ្ជូន ឬ ប្រតិវេទន៍មុន Transport Doc. / Previous Declaration

41 ឯកតារង Suppl. Units | 42 តម្លៃមុខទំនិញ Item Price | 43 វិធីកំណត់តម្លៃ Valuation Method

44 | AD.INFO

លេខអាជ្ញាប័ណ្ណ License No. : | តម្លៃបន្ថយ DV: | បរិមាណបន្ថយ DQ:

តម្លៃលំអិត Value Details:

ឯកសារភ្ជាប់ Attached Doc. :

ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

45 កែតម្រូវ Adjustment

46 តម្លៃគិតពន្ធគយ Customs Value

DESCRIPTION OF GOODS

ស្លាកសញ្ញាលើកញ្ចប់ Marks on Packages:
a)
b)

ចំនួននិងប្រភេទ Number and Type:

អត្តសញ្ញាណកុងតឺន័រ Container Identifier:

បរិយាយមុខទំនិញតាមពិកាគន្ធ Goods Description as Per Tariff :

បរិយាយតាមបែបពាណិជ្ជកម្ម Commercial Description:

32 ទំនិញទី Item No.

33 លេខកូដទំនិញ Commodity Code

34 កូដប្រទេសកំណើត C.O. Code | 35 ទម្ងន់សរុប Gross Mass kg | 36 អនុគ្រោះ Preference

37 របបគយ Procedure | 38 ទម្ងន់សុទ្ធ Net Mass kg | 39 xxxx

40 ឯកសារ ដឹកជញ្ជូន ឬ ប្រតិវេទន៍មុន Transport Doc. / Previous Declaration

41 ឯកតារង Suppl. Units | 42 តម្លៃមុខទំនិញ Item Price | 43 វិធីកំណត់តម្លៃ Valuation Method

44 | AD.INFO

លេខអាជ្ញាប័ណ្ណ License No. : | តម្លៃបន្ថយ DV: | បរិមាណបន្ថយ DQ:

តម្លៃលំអិត Value Details:

ឯកសារភ្ជាប់ Attached Doc. :

ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

45 កែតម្រូវ Adjustment

46 តម្លៃគិតពន្ធគយ Customs Value

47

ប្រភេទ Type	មូលដ្ឋានពន្ធ Tax base	អត្រា Rate	ប្រាក់ពន្ធ Amount	ប.ទ.ទ MP	ប្រភេទ Type	មូលដ្ឋានពន្ធ Tax base	អត្រា Rate	ប្រាក់ពន្ធ Amount	ប.ទ.ទ MP
	សរុបមុខទំនិញទី Total Item No. :					សរុបមុខទំនិញទី Total Item No.			

ប្រភេទ Type	មូលដ្ឋានពន្ធ Tax base	អត្រា Rate	ប្រាក់ពន្ធ Amount	ប.ទ.ទ MP	ប្រភេទ Type	ប្រាក់ពន្ធ Amount	ប.ទ.ទ MP
	សរុបមុខទំនិញទី Total Item No. :				សរុប G. Total		

សរុបនិទ្ទេស RECAPITULATION

C ការិយាល័យចេញដំណើរ Office of Departure

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ឯកសាររដ្ឋបាលតែមួយ SINGLE ADMINISTRATIVE DOCUMENT

ប្រតិវេទន៍គយ CUSTOMS DECLARATION

1 ប្រភេទប្រតិវេទន៍ TYPE OF DECLARATION

A ការិយាល័យដាក់ប្រតិវេទន៍ OFFICE OF LODGEMENT
ក្រមការិយាល័យ Office Code :
និវេទន៍បញ្ជី Manifest :
បញ្ជីការគយ Customs Registration :
លេខ Number:
កាលបរិច្ឆេទ Date:

COPY2

2 អ្នកនាំចេញ ឬ អ្នកផ្ញើទំនិញ Exporter/Consignor
លេខកូដ Code No. :

3 ទម្រង់ Forms
4 xxxx
5 មុខទំនិញ Items
6 កញ្ចប់សរុប Tot. Pack.
7 លេខយោងប្រតិវេទក Declarant Reference Number

8 អ្នកនាំចូល ឬ អ្នកទទួលទំនិញ Importer/Consignee
លេខកូដ Code No. :

9 អ្នកទទួលទំនិញ / អ្នកនាំចេញម្តងម្កាល Occasional Consignee / Exporter :
ឈ្មោះ Name:
អត្តសញ្ញាណ ID:
អាសយដ្ឋាន Address:

10 កូដប្រ.ទ.មកពី / ទៅដល់ Country
LC / FD Code
11 xx
12 តម្លៃលំអិត Value Details
13 អ.ទ.មុ.ជ PSI

14 ប្រតិវេទករ ឬ អ្នកតំណាង Declarant / Representative
លេខកូដ Code No. :

15 ប្រទេសនាំចេញ Country of Export
15 កូដប្រ.នាំចេញ C.E. Code
17 កូដប្រ.គ.ដ្ឋាន C. D. Code
XX

16 ប្រទេសកំណើត Country of Origin
17 ប្រទេសគោលដៅ Country of Destination

18 អត្តសញ្ញាណនិងសញ្ជាតិ ម.ដ.ជ. មកដល់ / ចេញដំណើរ Ident. & Nat. of MOT at Arrival/ Departure
19 កុងតឺន័រ Ctr.
20 លក្ខខណ្ឌប្រគល់ទំនិញ Delivery Terms
XX

21 អត្តសញ្ញាណនិងសញ្ជាតិ ម.ដ.ជ. ឆ្លងកាត់ព្រំដែន Ident. & Nat. of MOT Crossing the Border
22 រូបិយប័ណ្ណ & តំលៃវិក្កយបត្រសរុប Cur. & Tot. Invoice Amount
23 អត្រាប្តូរប្រាក់ Exch. Rate
24 ប្រភេទប្រតិបត្តិការ Nature of Transaction

25 របៀបដឹកជញ្ជូន នៅព្រំដែន Mode of Trsp. at Border
26 របៀបដឹកជញ្ជូនក្នុងប្រទេស Inland Mode of Trsp.
27 កន្លែងផ្ទុក / ធ្លាក់ Place of Loading/ Discharge
28 កូដធនាគារ Bank Code :
លក្ខខណ្ឌទូទាត់ Terms of Payment:

29 ការិយាល័យចូល / ចេញ Office of Entry / Exit
30 ទីតាំងនៃទំនិញ Location of Goods
ឈ្មោះធនាគារ Bank Name:
សាខា Branch:
ឯកសារលេខ File No:

31 ស្លាកសញ្ញាលើកញ្ចប់ Marks on Packages :
a)
b)
ចំនួននិងប្រភេទ Number and Type:
អត្តសញ្ញាណកុងតឺន័រ Container Identifier:
ពិពណ៌នាទំនិញតាមតារាងពន្ធ Goods Description as Per Tariff :
ពិពណ៌នាតាមបែបពាណិជ្ជកម្ម Commercial Description:

ពិពណ៌នាមុខទំនិញ DESCRIPTION OF GOODS

32 ទំនិញទី Item No.
33 លេខកូដទំនិញ Commodity Code
34 កូដប្រទេសកំណើត C.O. Code
35 ទម្ងន់សរុប Gross Mass kg
36 ការអនុគ្រោះ Preference
37 នីតិវិធី Procedure
38 ទម្ងន់សុទ្ធ Net Mass kg
39 xxxx
40 ឯកសារដឹកជញ្ជូន/ប្រតិវេទន៍មុន Transport Doc. / Previous Declaration
41 ឯកតាបន្ថែម Suppl. Units
42 តម្លៃមុខទំនិញ Item Price
43 វិធីកំណត់តម្លៃ Valuation Method

44 លេខអាជ្ញាប័ណ្ណ License No. :
តម្លៃបន្ថយ DV:
បរិមាណបន្ថយ DQ:
តម្លៃលំអិត Value Details:
ឯកសារភ្ជាប់ Attached Doc. :
ព័ត៌មានបន្ថែមផ្សេងទៀត Other Additional Information:

ព័ត៌មានបន្ថែម ADD INFO

45 កែតម្រូវ Adjustment
46 តម្លៃគិតពន្ធគយ Customs Value

47 ការគណនាពន្ធ CALCUL OF TAXES

ប្រភេទ Type	មូលដ្ឋានពន្ធ Tax Base	អត្រា Rate	ប្រាក់ពន្ធ Amount	ម.ទ.ទ MP
	សរុប Total :			

48 ទូទាត់ពន្យារពេល Deferred Payment
49 អត្តសញ្ញាណឃ្លាំង Identification of Warehouse

B ពត៌មានគណនេយ្យលំអិត ACCOUNTING DETAILS
របៀបនៃការទូទាត់ Mode of Payment:
លេខវាយតម្លៃ Assessment No. :
កាលបរិច្ឆេទ Date :
លេខបង្កាន់ដៃ Receipt No. :
កាលបរិច្ឆេទ Date :
ការធានា Guarantee :
កាលបរិច្ឆេទ Date :
សរុបពន្ធ Total Fees :
ជារៀល In Riels
សរុបលើប្រតិវេទន៍ Total Declaration :
ជារៀល In Riels

50 ភារធុរៈទាយក Principal
លេខ No.:
ហត្ថលេខា Signature

C ការិយាល័យចេញដំណើរ OFFICE OF DEPARTURE

51

52 ការធានា Guarantee
គ្មានសុពលភាពសំរាប់ Not Valid for:
Code

53 ការិយាល័យគោលដៅ (និងប្រទេស) Office of Destination (and Country)

D ត្រួតពិនិត្យដោយការិយាល័យគោលដៅ CONTROL BY OFFICE OF DESTINATION
លទ្ធផល Result:
Stamp
ហត្ថលេខា Signature:

54 ទីកន្លែងនិងកាលបរិច្ឆេទ Place and Date
ហត្ថលេខា និង ឈ្មោះប្រតិវេទករ / អ្នកតំណាង
Signature and Name of Declarant / Representative

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០០៧-១៧៦ ប្រ.ក

ប្រ កា ស

ស្តីពី

ក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ធនាគារជាតិនៃកម្ពុជា

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៩៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤០អនក្រ-បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ
- យោងតាមប្រកាសលេខ ធ៨.០៥-២០៨ ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ស្តីពីរចនាសម្ព័ន្ធ និងមុខងារ-ភារកិច្ចរបស់អគ្គាធិការដ្ឋានធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់អគ្គាធិការដ្ឋានធនាគារជាតិនៃកម្ពុជា
- តាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ។

ស ម្រេ ច

ប្រការ ១.- ដាក់ឱ្យអនុវត្តនូវក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋានធនាគារជាតិនៃកម្ពុជា ដែលមានខ្លឹមសារដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ២. មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ដែលទទួលខុសត្រូវធ្វើសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់ធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមគោលការណ៍ និងវិធាននៃការប្រព្រឹត្តទៅទាំងឡាយ ដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ។

ប្រការ ៣. អគ្គាធិការដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន គ្រប់សាខាធនាគារជាតិនៃកម្ពុជា និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាព្រមទាំងសាមីមន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៤. ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៧

ទេសាភិបាល

ជា_ចាន់តូ

កន្លែងទទួល :
- ដូចប្រការ ៣
  " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

ចម្លងជូន
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
  " ដើម្បីជូនជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..

ឧបសម្ព័ន្ធ

នៃប្រកាសលេខ ធ៧-០៧-១៧៦ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៧

ក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ធនាគារជាតិនៃកម្ពុជា

១- សេចក្តីផ្តើម

ធនាគារជាតិនៃកម្ពុជា ដាក់ចេញនូវក្រមសីលធម៌នេះ សម្រាប់ឱ្យមន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ប្រតិបត្តិតាមក្នុងការបំពេញភារកិច្ចរបស់ខ្លួនជាសវនករផ្ទៃក្នុងនិងជាមន្ត្រីអធិការកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ។

សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច គឺជាសកម្មភាពឯករាជ្យនិងមិនលំអៀង និងជាសកម្មភាពពិគ្រោះយោបល់ក្នុងគោលបំណងលើកតម្លៃ និងបង្កើននូវប្រសិទ្ធភាពការងារ ។ សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ជួយធនាគារជាតិនៃកម្ពុជា ឱ្យសម្រេចទិសដៅដោយនាំមកនូវវិធីសាស្ត្រជាប្រព័ន្ធ និងមានរបៀបរៀបរយ ដើម្បីវាយតម្លៃ និងធ្វើឱ្យមានប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ។

ក្រមសីលធម៌មានលក្ខណៈចាំបាច់ និងសមស្របសម្រាប់វិជ្ជាជីវៈសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ដែលជាមូលដ្ឋាននៃភាពជឿជាក់ក្នុងការធានាឱ្យសម្រេចបានតាមទិសដៅក្នុងការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ។ ក្រមសីលធម៌មានអត្ថន័យទូលំទូលាយជាងនិយមន័យនៃសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ដោយរាប់បញ្ចូលនូវសមាសធាតុសំខាន់ចំនួនពីរគឺ ៖

១- គោលការណ៍ដែលទាក់ទងទៅនឹងវិជ្ជាជីវៈ និងការប្រតិបត្តិនៃសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ។

២- វិធានដែលចែងអំពីបទដ្ឋាននៃអាកប្បកិរិយារបស់សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច។ វិធានទាំងនេះជួយក្នុងការអនុវត្តគោលការណ៍ និងមានគោលបំណងណែនាំដល់សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ចក្នុងការប្រតិបត្តិតាមត្រឹមត្រូវនូវក្រមសីលធម៌ ។

២. គោលការណ៍

សវនករផ្ទៃក្នុងនិងមន្ត្រីអធិការកិច្ចត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ ដូចខាងក្រោម ៖

ក- ភាពសុចរិត

ភាពសុចរិតរបស់សវនករផ្ទៃក្នុងនិងមន្ត្រីអធិការកិច្ចបង្កើតឱ្យមានភាពជឿជាក់ និង ជាមូលដ្ឋាននៃជំនឿទុកចិត្តលើការវិនិច្ឆ័យរបស់សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច។

ខ- ភាពមិនលំអៀង

សវនករផ្ទៃក្នុងនិងមន្ត្រីអធិការកិច្ច ត្រូវមានភាពមិនលំអៀងលើវិជ្ជាជីវៈខ្ពស់ក្នុងការប្រមូលការវាយតម្លៃ និងការផ្តល់ព័ត៌មានស្តីពីសកម្មភាព ឬដំណើរការដែលកំពុងត្រួតពិនិត្យ។ សវនករផ្ទៃក្នុងនិងមន្ត្រីអធិការកិច្ច ត្រូវវាយតម្លៃឱ្យបានសមស្របគ្រប់ជ្រុងជ្រោយចំពោះគ្រប់ហេតុការណ៍ដែលពាក់ព័ន្ធ និងមិនត្រូវទទួលរងឥទ្ធិពលមិនល្អដោយផលប្រយោជន៍ផ្ទាល់ខ្លួន ឬដោយអ្នកដទៃក្នុងការវិនិច្ឆ័យឡើយ។

គ- ការសម្ងាត់វិជ្ជាជីវៈ

សវនករផ្ទៃក្នុងនិងមន្ត្រីអធិការកិច្ច ត្រូវគោរពនូវតម្លៃ និងភាពជាម្ចាស់កម្មសិទ្ធិលើព័ត៌មានដែលខ្លួនទទួលបាន ហើយមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងនោះដោយគ្មានការអនុញ្ញាតត្រឹមត្រូវឡើយ លើកលែងតែមានកាតព្វកិច្ចខាងផ្លូវច្បាប់ ឬវិជ្ជាជីវៈឱ្យផ្តល់ព័ត៌មានទាំងនោះ ។

ឃ- សមត្ថភាពវិជ្ជាជីវៈ

សវនករផ្ទៃក្នុងនិងមន្ត្រីអធិការកិច្ច ត្រូវប្រើប្រាស់ចំណេះដឹង ជំនាញ និងបទពិសោធន៍ដែលខ្លួនមាន ដើម្បីអនុវត្តការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ។

៣. វិធាន

ក- ភាពសុចរិត

សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច ៖

១ -ត្រូវបំពេញការងារដោយស្មោះត្រង់ យកចិត្តទុកដាក់ និងទទួលខុសត្រូវ ។

២- ត្រូវប្រតិបត្តិតាមច្បាប់ និងធ្វើការផ្សព្វផ្សាយព័ត៌មាន តាមកាតព្វកិច្ចខាងផ្លូវច្បាប់ ឬវិជ្ជាជីវៈ ។

៣- ត្រូវគោរព និងចូលរួមក្នុងការអនុវត្តនូវគោលដៅស្របច្បាប់ និងត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

៤- មិនត្រូវចូលរួមដោយចេតនាក្នុងសកម្មភាពទាំងឡាយណាដែលខុសច្បាប់ ឬប្រព្រឹត្តនូវអំពើណាមួយដែលប៉ះពាល់កិត្តិយសវិជ្ជាជីវៈសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ឬធនាគារជាតិនៃកម្ពុជាឡើយ ។

ខ- ភាពមិនលំអៀង

សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច ៖

១- មិនត្រូវចូលរួមក្នុងសកម្មភាព ឬទំនាក់ទំនងណាដែលធ្វើឱ្យ ឬនឹងអាចធ្វើឱ្យអាប់ឱនដល់ការវាយតម្លៃដោយមិនលំអៀងរបស់ខ្លួន ។ ការចូលរួមនេះរាប់បញ្ចូលនូវរាល់សកម្មភាព ឬទំនាក់ទំនងដែលមានទំនាស់ជាមួយផលប្រយោជន៍របស់ធនាគារជាតិនៃកម្ពុជាទៀតផង ។

២- មិនត្រូវទទួលយកនូវអ្វីៗដែលធ្វើឱ្យ ឬនឹងអាចធ្វើឱ្យអាប់ឱនដល់ការវិនិច្ឆ័យក្នុងវិជ្ជាជីវៈរបស់ខ្លួនឡើយ ។

៣- ត្រូវជូនដំណឹងពីហេតុការណ៍សំខាន់ៗដល់សវនករនិងមន្ត្រីអធិការកិច្ចផងគ្នា ដើម្បីជៀសវាងការបកស្រាយខុសលើរបាយការណ៍ស្តីពីសកម្មភាពដែលបានធ្វើការពិនិត្យឡើងវិញ ។

គ- ការសម្ងាត់វិជ្ជាជីវៈ

សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច ៖

១- ត្រូវប្រើប្រាស់ និងការពារយ៉ាងប្រុងប្រយ័ត្ននូវព័ត៌មាន និងឯកសារដែលទទួលបានក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ។

២- មិនត្រូវប្រើប្រាស់ព័ត៌មាន ឬឯកសារទាំងនោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬក្នុងលក្ខណៈណាមួយដែលផ្ទុយនឹងច្បាប់ ឬធ្វើអ្វីដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃគោលដៅស្របច្បាប់និងត្រឹមត្រូវរបស់ធនាគារជាតិនៃកម្ពុជាឡើយ ។

ឃ -សមត្ថភាពវិជ្ជាជីវៈ

សវនករផ្ទៃក្នុង និងមន្ត្រីអធិការកិច្ច ៖

១- ត្រូវបំពេញតែភារកិច្ចដែលទាក់ទងទៅនឹងចំណេះដឹង ជំនាញ និងបទពិសោធន៍ដែលខ្លួនមាន ។

២- ត្រូវបំពេញការងារសវនកម្មផ្ទៃក្នុងដោយអនុលោមទៅតាមស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ដែលចេញឱ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
ត្រូវបំពេញការងារអធិការកិច្ច ដោយអនុលោមតាមបទបញ្ជា និងសេចក្តីណែនាំស្តីពីការធ្វើអធិការកិច្ច ដែលចេញឱ្យប្រើប្រាស់ដោយធនាគារជាតិនៃកម្ពុជា ។

៣- ត្រូវបន្តធ្វើឱ្យប្រសើរឡើងនូវភាពស្ទាត់ជំនាញ ប្រសិទ្ធភាព និងគុណភាពនៃការងាររបស់ខ្លួន ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ : ៧៤៥ ពណ.ចបព ប្រ

ទទួលលិខិតចូល
ថ្ងៃទី ៣១ ខែ ៨ ឆ្នាំ 2007

ប្រកាស

ស្តីពី

ការធ្វើវិមជ្ឈការ ការចុះបញ្ជីពាណិជ្ជកម្មនៅមណ្ឌលសាខាខេត្ត-ក្រុង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ប្រកាសអោយប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥១អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ។
- បានឃើញសេចក្តីជូនដំណឹងអំពីការអនុវត្តន៍ផែនការ កំណែទំរង់ការចុះបញ្ជីពាណិជ្ជកម្មលេខ ២១០៦ ពណ.នគក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។
- បានឃើញផែនការសំរាប់ការកែទម្រង់ប្រព័ន្ធចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។

សំរេច

ប្រការ១ : សំរេចធ្វើវិមជ្ឈការ ការចុះបញ្ជីពាណិជ្ជកម្មនៅតាមមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម នៃបណ្តាខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ២ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មស្ថិតនៅក្រោមការដឹកនាំ និង គ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម និងត្រូវបានប្រមូលផ្តុំបណ្តាខេត្ត-ក្រុងមួយចំនួន ដែលមានវង្វង់ដែនដីជិតគ្នា អាស្រ័យទៅលើស្ថានភាពសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ និង អាស្រ័យដោយការកំណត់របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ប្រការ៣ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មនៃបណ្តាខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

៣.១ : មជ្ឈមណ្ឌលចុះបញ្ជីពាណិជ្ជកម្ម មានទីតាំងនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។ មជ្ឈមណ្ឌលចុះបញ្ជីពាណិជ្ជកម្មរួមមាន : នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និង ខេត្តកំពង់ឆ្នាំង ។

៣.២ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីមួយ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលក្រុងព្រះសីហនុ នឹងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មក្រុងព្រះសីហនុ ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីពីរ រួមមាន : ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកំពត និងខេត្តកោះកុង ។

៣.៣ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីពីរ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តសៀមរាប នឹងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបីរួមមាន : ខេត្តសៀមរាប និង ខេត្តឧត្តរមានជ័យ ។

៣.៤ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបី ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តកំពង់ចាម នឹងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបីរួមមាន : ខេត្តកំពង់ចាម ខេត្តកំពង់ធំ និង ខេត្តព្រះវិហារ ។

៣.៥ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបួន ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តក្រចេះ នឹងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តក្រចេះ ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំរួមមាន : ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និង ខេត្តរតនគិរី ។

៣.៦ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តស្វាយរៀង នឹងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំមួយ រួមមាន : ខេត្តស្វាយរៀង និង ខេត្តព្រៃវែង ។

៣.៧ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំមួយ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តបាត់ដំបង នឹងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំពីររួមមាន : ខេត្តបាត់ដំបង ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ និង ក្រុងប៉ៃលិន ។

<u>ប្រការ៤</u> : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ដូចមានចែងក្នុងប្រការ ១ ត្រូវបានដឹកនាំ ដោយមន្ត្រីតំណាងនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ០១រូប ជាប្រធានសាខា និង មន្ត្រីមួយចំនួននៃមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ជាជំនួយការ ។

<u>ប្រការ៥</u>: ផ្ទេរប្រតិភូកម្មអំណាចពីក្រសួងពាណិជ្ជកម្ម ជូនដល់មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង ក្នុងក្របខ័ណ្ឌទទួលពាក្យសុំចុះបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសគ្រប់ប្រភេទទាំងអស់ លើកលែងតែសហគ្រាសវិនិយោគទុនដែលត្រូវចុះបញ្ជី នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

<u>ប្រការ៦</u> : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង ប្រើប្រាស់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ទៅតាមទំរង់តែមួយដូចគ្នានឹងទំរង់ដែលប្រើប្រាស់នៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

<u>ប្រការ៧</u> : ក្រោយពីបានទទួលសំណុំលិខិត និង ឯកសារសុំចុះបញ្ជីពាណិជ្ជកម្មគ្រប់គ្រាន់តាមច្បាប់ត្រឹមត្រូវ ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដែលមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មតាំងនៅ ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីបណ្តោះអាសន្ន ជូនដល់សាមីសហគ្រាស និង ក្រុមហ៊ុន ដែលមានសុពលភាពសំរាប់ប្រើប្រាស់កំណត់ចំនួនត្រឹម ៣០ ថ្ងៃ ។ វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មជាផ្លូវការដែលសំរេចដោយថ្នាក់ដឹកនាំក្រសួង និង ត្រូវបញ្ជូនមកមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង ដើម្បីប្រគល់ជូនដល់សាមីសហគ្រាសក្រុមហ៊ុនដែលជាអ្នកស្នើសុំ ។

ប្រការ៨ : នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ត្រូវចេញសេចក្តីណែនាំអំពីបែបបទ និង នីតិវិធីស្តីពីការអនុវត្តន៍ការចុះបញ្ជីពាណិជ្ជកម្ម នៅតាមបណ្តាមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ។

ប្រការ៩ : តួនាទី និង ភារកិច្ចរបស់មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម មានដូចតទៅ :

- ពិគ្រោះ និង ផ្តល់យោបល់ ជូនអតិថិជន សហគ្រិន ពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម ។
- ផ្តល់ពត៌មានពីការសំរេចចិត្ត របស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អំពីការអនុញ្ញាតអោយប្រើប្រាស់នាមករណ៏ក្រុមហ៊ុនដែលអតិថិជន និង សហគ្រិនបានស្នើឡើងមក ។
- ទទួលពាក្យស្នើសុំ និង សំណុំលិខិតដែលច្បាប់តំរូវ ដើម្បីសុំចុះបញ្ជីពាណិជ្ជកម្ម ហើយបញ្ជូនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម សុំការសំរេចជាផ្លូវការអំពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ។
- ប្រគល់សំណុំឯកសារ និង វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ដែលបានទទួលការសំរេចជាផ្លូវការរួចហើយជូនដល់សាមីសហគ្រាស ក្រុមហ៊ុនអ្នកស្នើសុំ ។
- គ្រប់គ្រង និង ថែរក្សាសំណុំឯកសារទាំងឡាយ របស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅតាមមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុងនិមួយ១ ហើយធ្វើរបាយការណ៍ និង ផ្តល់ស្ថិតិប្រចាំខែ ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលមានទីស្នាក់ការតាំងនៅក្នុងមណ្ឌលនិមួយ១ផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។
- ដោះស្រាយបញ្ហាដែលកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្ម ឬ បញ្ជូនឯកសារ ទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ក្នុងករណីចាំបាច់ដែលមានបញ្ហាកើតឡើង ។
- ធ្វើការផ្សព្វផ្សាយខ្លឹមសារច្បាប់ និង លិខិតបទដ្ឋាននានា ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម និង ជំរុញការអនុវត្តន៍អោយមានប្រសិទ្ធភាព ។

ប្រការ១០ : អគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នាយិកាខុទ្ទកាល័យ ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និង ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គឹម ស៊ីថន

ចម្លងជូន :

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខាំអន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត-ក្រុង
- មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ADB TA 4786-CAM
- អគ្គនាយកដ្ឋានរាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី០៣.ខែ[illegible].ឆ្នាំ២០០៧

ជ. ប្រធាននាយកដ្ឋានរដ្ឋបាល

វង្ស ចន្ទតារា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ : ២៧៦៨ ពណ. ចបព

ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧

សេចក្តីជូនដំណឹង
ស្តីពី
បែបបទ និងនិតិវិធីសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម នៅមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ខេត្ត-ក្រុង

ទីតាំង

ការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម មានទីតាំងនៅក្នុងមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ឬនៅទីកន្លែងដទៃទៀតក្នុងរង្វង់ដែនដីខេត្តក្រុង អាស្រ័យដោយការកំណត់របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ការចុះបញ្ជីនៅមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង

គ្រប់ក្រុមហ៊ុនសហកម្មសិទ្ធិ, ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត, សហគ្រាសឯកបុគ្គល សាខា, ការិយាល័យ តំណាងក្រុមហ៊ុនដែលមានទីស្នាក់ការតាំងនៅរង្វង់ដែនដី អាចទទួលការចុះបញ្ជីដោយពេញលេញពីក្រសួងពាណិជ្ជកម្ម ដោយបង្ហាញពាក្យសុំចុះបញ្ជីនៅការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ។

អ្នកសុំចុះបញ្ជីពាណិជ្ជកម្មអាចសំរេចចិត្តថា តើគេចង់ចុះឈ្មោះតាមទំរង់សហគ្រាសបែបណា ។

ជំរើសនៃទំរង់សហគ្រាសមានដូចខាងក្រោមនេះ

- សហគ្រាសឯកបុគ្គល
- សហគ្រាសសហកម្មសិទ្ធិ
- សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត
- សាខានៃក្រុមហ៊ុនបរទេស
- ការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស
- សាខានៃក្រុមហ៊ុនខ្មែរ

ជាដំបូងសហគ្រាសទាំងអស់ ត្រូវទៅយកទំរង់បែបបទពាក្យសុំដែលត្រឹមត្រូវពីការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ដែលនៅទីនោះ គេនឹងផ្តល់ពត៌មានពីបែបបទនៃការចុះបញ្ជីសហគ្រាស ។

ការរៀបចំចេញសហគ្រាសធុនតូច

សហគ្រាសធុនតូចដែលប្រតិបត្តិការមិនស្ថិតនៅក្នុងរបបពិត (យោង: ប្រកាសលេខ ៧៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីចំនួនកំណត់) ប៉ុន្តែនៅក្នុងរបបម៉ៅការ (យោង: សេចក្តីណែនាំលេខ 006 SCN.SHV.PD ចុះថ្ងៃទី ២០ មិនា ២០០៧) ត្រូវការសុំលិខិតអនុញ្ញាតនៅមន្ទីរពាណិជ្ជកម្មខេត្ត ឬប្រកចេញចូលតែមួយ (មិនត្រូវការចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម) ប្រសិនបើអាជីវកម្មរបស់គេស្ថិតនៅក្នុងរង្វង់ខេត្ត-ក្រុង ។

បែបបទនៃការត្រួតពិនិត្យឈ្មោះ

សហគ្រាសទាំអស់ដែលមកសុំចុះបញ្ជីពាណិជ្ជកម្មត្រូវធ្វើការពិនិត្យដើម្បីអោយប្រាកដថា ឈ្មោះដែលគេជ្រើសរើស មិនមានប្រើ ឬមិនស្រដៀងគ្នានឹងឈ្មោះដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្មរួចហើយ ឬ មិនមានក្នុងបញ្ជីឈ្មោះបំរុងដែលគេរក្សាទុក ។

ការពិនិត្យឈ្មោះអាចប្រព្រឹត្តទៅតាមទូរស័ព្ទ ឬ បញ្ជូនសារពីការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ទៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

ការពិនិត្យចុងក្រោយនឹងប្រព្រឹត្តទៅនៅពេលដែលឯកសារដើមទាំងអស់ បានមកដល់ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

ទំរង់ពាក្យសុំ និង គំរូផ្សេងៗ

បន្ទាប់ពីការពិនិត្យឈ្មោះ សហគ្រាសត្រូវបានគេប្រគល់អោយនូវទំរង់ពាក្យសុំសំរាប់ប្រភេទសហគ្រាសនោះ ។ ទំរង់ពាក្យសុំត្រូវតែដូចគ្នានឹងទំរង់ដែលបានប្រើនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម ។

ក្នុងករណីនៃការសុំរបស់ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត មន្ត្រីនៃការិយាល័យមណ្ឌលសាខាចុះបញ្ជីនឹងផ្តល់អោយសហគ្រាស នូវគំរូលក្ខន្តិកៈពាណិជ្ជកម្មជាច្បាប់ថតចំលង ឬអេឡិចត្រូនិច (តាមពត៌មានអ្នកសុំ) ហើយពន្យល់ពីបែបបទទាក់ទិននឹងឯកសារនេះផង ។

បែបបទឯកសារសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម

សំរាប់ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បែបបទនៃការចុះបញ្ជីត្រូវស្ថិតក្នុងរង្វង់ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ច្បាប់សហគ្រាសពាណិជ្ជកម្ម ប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៧ ស្តីពីកំរៃ

រដ្ឋបាលក្នុងការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងសេចក្តីជូនដំណឹងលេខ ១៤១៤ MOC/SM 2006 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីឯកសារតំរូវការសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម ។

សហគ្រាសត្រូវយកឯកសារទាក់ទិនទាំងអស់ជូនទៅការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ។

អនុលោមតាមមាត្រា ២៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម, ប្រសិនបើឯកសារមិនគ្រាប់គ្រាន់ទេ សហគ្រាសនឹងត្រូវបានទុកពេលអោយដប់ប្រាំ (១៥) ថ្ងៃ ដើម្បីកែតំរូវ និងបំពេញបន្ថែម ហើយបញ្ជូនឯកសារមកវិញអោយបានគ្រប់គ្រាន់ ។

មន្ត្រីចុះបញ្ជីត្រួតពិនិត្យមើលលក្ខន្តិកៈរបស់ក្រុមហ៊ុន និងសំណុំលិខិតស្នើសុំ ហើយនៅពេលយល់ឃើញថា ឯកសារគ្រប់គ្រាន់ ត្រូវអញ្ជើញអ្នកស្នើសុំអោយទៅការិយាល័យនាយក ដើម្បីបង់កំរៃរដ្ឋបាលចុះបញ្ជីតាមតម្លៃត្រឹមត្រូវ ។

កំរៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម

នៅពេលបង់ប្រាក់ ឈ្មោះអ្នកស្នើសុំចុះបញ្ជីនិងកំណត់ត្រានៃការបង់លុយរបស់គេត្រូវកត់បញ្ចូលទៅក្នុងសៀវភៅបង់លុយ ហើយមន្ត្រីចុះបញ្ជីត្រូវប្រាប់ទៅអ្នកស្នើសុំពីពេលដែលត្រូវត្រឡប់មកយកវិញ្ញាបនប័ត្រចុះបញ្ជី និងលិខិតអនុញ្ញាត ។

អ្នកសុំត្រូវទទួលបង្កាន់ដៃសំរាប់ការបង់ប្រាក់របស់គេ ទុកជាភ័ស្តុតាងថាគេបានបង់កំរៃរដ្ឋបាលចំពោះការ ចុះបញ្ជីគ្រប់ចំនួនហើយ ។

សហគ្រាសត្រូវបង់កំរៃចុះបញ្ជី ស្របតាមប្រកាសអន្តរក្រសួង លេខ ៦៧៥ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ ។

កំរៃរដ្ឋបាលក្នុងការចុះបញ្ជីដែលបានប្រមូលនៃមណ្ឌលសាខាចុះបញ្ជី ត្រូវបញ្ជូនមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីបង់ចូលថវិការដ្ឋ ។

ហត្ថលេខានៃការទទួលសំរាប់ទុកជាឯកសារ

ជាបន្ថែមទៀតអ្នកស្នើសុំត្រូវចុះហត្ថលេខាទទួល សំរាប់ផ្នែកទុកដាក់ឯកសារនៃទំរង់ពាក្យសុំ ។ ប្រសិនបើអ្នកស្នើសុំជាអ្នកសម្របសំរួលសំរាប់សហគ្រាស នាយក ឬម្ចាស់ភាគហ៊ុន (សំរាប់ក្រុមហ៊ុន) ឬសហកម្មសិទ្ធិករទូទៅ (សំរាប់សហកម្មសិទ្ធិ) ឬអ្នកគ្រប់គ្រង (ប្រសិនបើជាការិយាល័យតំណាង ឬសាខា) ត្រូវមកកាន់ការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីមួយ (១) ថ្ងៃ ក្រោយពីបានបង់កំរៃរដ្ឋបាលចុះបញ្ជី និងប្រគល់ឯកសារទាំងអស់រួចហើយ ។

បង្កាន់ដៃសំរាប់ការទុកឯកសារត្រូវបានចុះហត្ថលេខាអមដោយប្រធានការិយាល័យនៃមណ្ឌលសាខាចុះបញ្ជី ។ បន្ទាប់មកបេឡាកររបស់នាយកបោះត្រា, ចុះហត្ថលេខា, ចុះថ្ងៃខែ ហើយបញ្ជូនចូលទៅក្នុងថវិការដ្ឋ ។

ការដាក់លេខចុះបញ្ជីពាណិជ្ជកម្ម និងលេខកាលបរិច្ឆេទ

សំណុំឯកសារពេញលេញត្រូវបានបញ្ជូនទៅមន្ត្រីចុះបញ្ជីដើម្បីបញ្ចប់ការត្រួតពិនិត្យ។ នៅពេលពិនិត្យរួចហើយ មន្ត្រីចុះបញ្ជីកំណត់លេខកាលប្បវត្តិ និង អត្តលេខចុះបញ្ជីដោយដៃ។ ការធ្វើនេះប្រព្រឹត្តទៅដោយទំនាក់ទំនងតាមទូរស័ព្ទ ឬអ៊ីម៉ែលជាមួយនឹងការិយាល័យចុះបញ្ជី នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។ លេខទាំងនេះចេញដោយមន្ត្រី នៅកន្លែងចុះបញ្ជីនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ហើយសរសេរលើសៀវភៅដែលរក្សាទុកនៅការិយាល័យនេះ។ លេខកាលប្បវត្តិគ្រាន់តែលេខរៀងបន្តក្នុងសៀវភៅ ហើយអត្តលេខចុះបញ្ជីក្រុមហ៊ុនបន្តលេខរៀង ប្រើតាមប្រភេទនៃសហគ្រាស។

លេខកាលប្បវត្តិនៃការចុះឈ្មោះ

លេខនេះមានទំរង់ XXX/YY, ដែល XXX ជាលេខរៀងនៃការចុះឈ្មោះក្នុងឆ្នាំ។ លេខ YY សំគាល់ឆ្នាំ ឧទាហរណ៍ ០៧ តាងអោយឆ្នាំ ២០០៧។

អត្តលេខចុះបញ្ជីឈ្មោះពាណិជ្ជកម្ម

លេខនេះមានទំរង់ WWWW/ZZQ, ដែល WWWW ជាលេខរៀងដែលតាងអោយលេខនៃប្រភេទនៃការចុះឈ្មោះក្នុងឆ្នាំ។ លេខនេះសំរាប់ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត (ទាំងក្រុមហ៊ុនឯកជន និងសាធារណៈទទួលខុសត្រូវមានកំរិត), មានលេខរៀងមួយ សំរាប់ការិយាល័យតំណាង ឬសាខាក្រុមហ៊ុន, មានលេខមួយទៀតសំរាប់សហគ្រាស ឯកបុគ្គល។ ចំពោះផ្នែក ZZQ វិញ, ZZ មាន លេខ ២ខ្ទង់តាងអោយឆ្នាំដូចជា ០៧ តាងអោយឆ្នាំ ២០០៧ ហើយផ្នែក Q វិញគឺជាលេខសំគាល់កូដការិយាល័យចុះបញ្ជីពាណិជ្ជកម្ម តែមួយក្នុងចំណោមខាងក្រោមនេះ :

ប្រភេទ (ដូចផ្នែក ៤ នៃពាក្យសុំ)	កូដដែលប្រើក្នុងលេខចុះបញ្ជីសហគ្រាស
សហកម្មសិទ្ធិទូទៅ	P= សញ្ជាតិខ្មែរ E= សញ្ជាតិបរទេស
ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត	
សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត	
ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត	
សហគ្រាសឯកបុគ្គល	I= សញ្ជាតិខ្មែរ IE= សញ្ជាតិបរទេស
សាខា / ការិយាល័យតំណាង	B

លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន

នៅពេលដែលលេខកាលប្បវត្តិ និងអត្តលេខចុះបញ្ជីពាណិជ្ជកម្ម បានចេញនិងសរសេរលើឯកសារពាក្យសុំហើយ, មន្ត្រីចុះបញ្ជី ត្រូវបញ្ចូលពត៌មានរបស់សហគ្រាសដែលបានផ្តល់នៅលើឯកសារពាក្យសុំទៅក្នុង MS Excel macro ដែលអាចចេញលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន ជាទ្រង់ទ្រាយអាចបោះពុម្ពបាន ដែលចែងពីចំណុចសំខាន់ៗរបស់ពាក្យសុំ សំរាប់ការចុះបញ្ជីក្រុមហ៊ុន។ ពង្រាងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ននេះ ត្រូវបញ្ជូនជាមួយនឹងឯកសារច្បាប់ដើមផ្សេងៗមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ហើយថែមទាំងបញ្ជូនតាមរយៈអ៊ីម៉ែលទៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

ការឯកភាពយល់ព្រមដោយប្រធានមន្ទីរពាណិជ្ជកម្មខេត្ត

លិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន មានសុពលភាពមួយខែ និង ត្រូវបានចុះហត្ថលេខានិងប្រថាប់ត្រាដោយប្រធានមន្ទីរពាណិជ្ជកម្មខេត្ត មុននឹងឯកសារត្រូវបញ្ជូនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

ការបញ្ជូនឯកសារ និង កំរៃរដ្ឋបាលទៅក្រសួងពាណិជ្ជកម្ម

មធ្យោបាយដែលធ្វើការបញ្ជូនឯកសារ និងកំរៃរដ្ឋបាលចុះបញ្ជីទៅកាន់ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នឹងអាចតាមលទ្ធភាពផ្សេងៗគ្នានៃការដឹកជញ្ជូន ឬតាមមន្ត្រីចុះបញ្ជីដែលធ្វើដំណើរមកភ្នំពេញ ។ ការបញ្ជូនពត៌មានពីមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មអាចធ្វើទៅបានតាមរយៈបណ្តាញ Internet ដូចជា Scan ឯកសារ និងផ្ញើ E-mail ។

ឯកសារទាំងអស់ ត្រូវផ្ញើទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម និងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម

វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មជាមួយនឹងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម ពីក្រសួងពាណិជ្ជកម្ម ត្រូវតែប្រមូល ហើយបញ្ជូនតាមលទ្ធភាពផ្សេងៗគ្នានៃការដឹកជញ្ជូន ឬតាមមន្ត្រីចុះពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្មទៅកាន់មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ។

ការជូនដំណឹងទៅសហគ្រាស

សហគ្រាសអាចត្រឡប់មកយកវិញតាមកាលបរិច្ឆេទដែលបានព្រមព្រៀង ឬអាចជាជំរើសមួយទៀតតាមទូរស័ព្ទ ពីការអាចមកយកវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មនិងលិខិតអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មបាន។

ប្រតិបត្តិការឯទៀតនៅការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម

ការចុះឈ្មោះបន្ទាប់ទៀត ជាទូទៅដែលធ្លាប់តែធ្វើនៅការិយាល័យចុះឈ្មោះពាណិជ្ជកម្មនៅភ្នំពេញ, ក៏អាចធ្វើនៅការិយាល័យនៃមណ្ឌលសាខាចុះបញ្ជីខេត្ត-ក្រុងបានដែរ ។ និតិវិធីមានចែងដូចខាងក្រោមនេះ :

វិសោធនកម្មលើលក្ខន្តិកៈក្រុមហ៊ុន

នៅពេលដែលក្រុមហ៊ុនទទួលខុសត្រូវមានកំរិត ត្រូវការធ្វើវិសោធនកម្មលើលក្ខន្តិកៈពាណិជ្ជកម្មរបស់គេ ក្រុមហ៊ុននោះ ត្រូវទៅការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ដាក់ឯកសារដែលត្រូវ ហើយបង់កំរៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម តាមការកំណត់ដូចចែងក្នុងប្រកាសអន្តរក្រសួងលេខ ៦៧៩ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ ។

ការរំលាយសហគ្រាស

នៅពេលដែលសហគ្រាសចង់លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម គេត្រូវទៅការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ហើយដាក់ពាក្យសុំលុបឈ្មោះសហគ្រាសចេញពីបញ្ជីពាណិជ្ជកម្ម ។ គេត្រូវប្រើឯកសារទំរង់ ឥ ។

ប្រតិវេទនីប្រចាំឆ្នាំនៃក្រុមហ៊ុន

ទំរង់ប្រើប្រាស់នៃប្រតិវេទនីប្រចាំឆ្នាំសំរាប់សហគ្រាសពាណិជ្ជកម្ម ដូចគ្នានឹងទំរង់ប្រតិវេទនីដែលប្រើប្រាស់នៅការិយាល័យប្រតិវេទនី នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

អនុលោមតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម លេខ ១៤៩ ចុះថ្ងៃទី ៩ កក្កដា ២០០៦ ក្រុមហ៊ុនទាំងអស់ ដែលបានចុះ ឈ្មោះជាមួយក្រសួងពាណិជ្ជកម្មត្រូវធ្វើប្រតិវេទនីប្រចាំឆ្នាំ។

ប្រតិវេទនីប្រចាំឆ្នាំនេះ ត្រូវដាក់ជូនការិយាល័យ នៃមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ឬការិយាល័យប្រតិវេទនី នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកាឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

គិម ស៊ីថន

<u>ចម្លងជូន :</u>

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត-ក្រុង
- មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ADB TA 4786-CAM
- អគ្គនាយកដ្ឋានរាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ.ថ្ងៃទី.៣០.ខែវិច្ឆិកា.ឆ្នាំ២០០៧
ត. ប្រធាននាយកដ្ឋានរដ្ឋបាល

វង្ស មន្ទធារា

ឧបសម្ព័ន្ធ
នៃ
បែបបទ និង នីតិវិធីសំរាប់ការ
ចុះបញ្ជីពាណិជ្ជកម្មនៅមណ្ឌល
សាខាខេត្ត-ក្រុង

បែបបទទំនាក់ទំនង ចុះបញ្ជីពាណិជ្ជកម្ម នៅសាខា ចុះបញ្ជីពាណិជ្ជកម្ម មណ្ឌលខេត្ត-ក្រុង